មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍ប្រចាំឆមាសលើកទី៤

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

## ២០០៩ - ២០១១

សីហា ២០១២

ឧបត្ថម្ភគាំទ្រដោយសប្បុរសពីសំណាក់៖

USAID
ជំនួយពីពលរដ្ឋអាមេរិក

EAST . WEST MANAGEMENT INSTITUTE
Program on Rights and Justice (PRAJ)
កម្មសិទ្ធិ និង យុត្តិធម៌ (ប្រាជ្ញ)

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

របាយការណ៍ស្ដីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ជាលទ្ធផលនៃការអនុវត្តគម្រោងសង្កេតការណ៍សវនាការ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សាដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋានមានសិទ្ធិស្មើគ្នា និងទទួលបានអំណាចដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យព្រមទាំងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេស។ ម.ស.ម.ក មានគោលបំណងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព-ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមសេរីពហុបក្សដែលក្នុងនោះភាពចម្រុះត្រូវបានគេទទួលយក និងសាទរជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបព្រាបសកំពុងហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវ បញ្ជាក់អំពីការទាមទារសេរីភាពនៅកម្ពុជា។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ម.ស.ម.ក ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យព្រមទាំងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមសូមទស្សនាគេហទំព័រ www.cchrcambodia.org

## សេចក្ដីថ្លែងអំណរគុណ

របាយការណ៍នេះកើតចេញពីកិច្ចឧបត្ថម្ភគាំទ្រដោយសប្បុរសអំពីសំណាក់ ប្រជាពលរដ្ឋអាមេរិកាំងតាមរយៈទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក (ទ.អ.អ.ស.អ) តាមរយៈវិទ្យាស្ថានគ្រប់គ្រងបូព៌ាបច្ចឹម និងការិយាល័យឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ ខ្លឹមសារនៃរបាយការណ៍នេះគឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ ទ.អ.អ.ស.អ រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬវិទ្យាស្ថានគ្រប់គ្រងបូព៌ាបច្ចឹមឡើយ។

## សំណួរនិងការឆ្លើយតប

ប្រសិនបើលោកអ្នកមានសំណួរឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើលោកអ្នកចង់ផ្ដល់យោបល់តបសូមផ្ញើអ៊ីមែលមកកាន់ ម.ស.ម.កតាមរយៈអាស័យដ្ឋាន info@cchrcambodia.org។

លោកអ្នកអាចស្វែងរករបាយការណ៍នេះ ក៏ដូចជារបាយការណ៍ផ្សេងទៀតដែលបោះផ្សាយដោយ ម.ស.ម.ក បាននៅលើគេហទំព័រ www.cchrcambodia.org និងនៅលើគេហទំព័រសិទ្ធិមនុស្ស www.sithi.org

(cc)២០១២មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)
ផ្ទះលេខ៧៩៨ផ្លូវលេខ៩៩សង្កាត់បឹងត្របែក
ខណ្ឌចំការមនរាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

# មាតិកា


**តារាងតួលេខ** ---------- 5

**ការពន្យល់អត្ថន័យ** ---------- 6

**ខ្លឹមសារសង្ខេប** ---------- 7

**១.សេចក្តីផ្តើម** ---------- 11

ក្របខណ្ឌច្បាប់ ---------- 11

បរិបទនយោបាយ ---------- 12

គោលបំណងក្រុមគោលដៅ និងវិសាលភាពនៃរបាយការណ៍ ---------- 12

**២. វិធីសាស្រ្ត** ---------- 14

រយៈពេល និងទីតាំង ---------- 14

សិទ្ធិសំខាន់ៗដែលជ្រើសរើសសម្រាប់សង្កេតសវនាការ ---------- 14

រចនាសម្ព័ន្ធ ---------- 15

បុគ្គលិក និងការបណ្តុះបណ្តាល ---------- 16

នីតិវិធីសង្កេតការណ៍សវនាការ ---------- 16

ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ---------- 17

ការវិភាគ និងកិច្ចពិភាក្សា ---------- 17

**៣. ទិន្នន័យ និងការវិភាគ** ---------- 19

សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ---------- 20

សិទ្ធិមានសេរីភាព និងទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ---------- 21

សិទ្ធិយល់ពីបទចោទប្រកាន់ ---------- 25

ការពន្យល់ប្រាប់សិទ្ធិ ---------- 27

សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការការពារក្តី ---------- 29

សិទ្ធិទទួលបានជំនួយពីមេធាវី និងមានវត្តមានក្នុងសវនាការ ---------- 30

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ---------- 32

ភាពឯករាជ្យភាពមិនលំអៀងនិងវិជ្ជាជីវៈរបស់ចៅក្រម ---------- 35

សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាក្សី) ---------- 37

សិទ្ធិទទួលដឹងឮភស្តុតាង ---------- 40

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព ---------- 40

ការហាមឃាត់ចំពោះការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ---------- 42

សវនាការពាក់ព័ន្ធនឹងអនីតិជន ---------- 43

អនីតិជន–ភាពឯកជន .......... 44

អនីតិជន – ការឃុំខ្លួនបណ្តោះអាសន្ន ........................................................................ 46
អនីតិជននិងការផ្តន្ទាទោស ........................................................................ 49
**៤សេចក្តីសន្និដ្ឋាន និងអនុសាសន៍** .------------------------------------------------------------ 51
**៥.គន្លនិទ្ទេស**------------------------------------------------------------ 56
**៦ឧបសម្ព័ន្ធ** . ------------------------------------------------------------ 62
ឧបសម្ព័ន្ធទី១៖ តារាងសង្កេតការណ៍សវនាការ ------------------------------------------------------------ 62
ឧបសម្ព័ន្ធទី២៖ បញ្ជីច្បាប់ជាមូលដ្ឋាន ------------------------------------------------------------ 79
ឧបសម្ព័ន្ធទី៣៖ ក្រមសីលធម៌មន្ត្រីសង្កេតការណ៍សវនាការ ------------------------------------------------------------ 99

# តារាងតួលេខ

តួលេខទី១ ៖ សវនាការដែលបានសង្កេត ----------------------------------------------------------------------------១៥
តួលេខទី២ ៖ សិទ្ធិទទួលបានសវនាការជាសាធារណៈ ------------------------------------------------------------១៦
តួលេខទី៣ ៖ ការឃុំខ្លួនបណ្តោះអាសន្ន--------------------------------------------------------------------------------១៧
តួលេខទី៤ ៖ ការឃុំខ្លួនបណ្តោះអាសន្នដែលលើសរយៈពេលកំណត់ដោយច្បាប់---------------------------១៨
តួលេខទី៥ ៖ សិទ្ធិយល់ដឹងពីបទចោទប្រកាន់ ---------------------------------------------------------------------២០
តួលេខទី៦ ៖ ការពន្យល់ប្រាប់ពីសិទ្ធិ -------------------------------------------------------------------------------២២
តួលេខទី៧ ៖ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការការពារក្តី ---------------------------------២៤
តួលេខទី៨ ៖ សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ------------------------------------------------២៥
តួលេខទី៩ ៖ ការសន្មតទុកជាមុនថាគ្មានទោស----------------------------------------------------------------------២៦
តួលេខទី១០ ៖ ភាពឯករាជ្យ និងមិនលំអៀងរបស់ចៅក្រម ---------------------------------------------------២៨
តួលេខទី១១ ៖ ចៅក្រមប្រើទូរស័ព្ទដៃនៅក្នុងសវនាការ-------------------------------------------------------២៩
តួលេខទី១២ ៖ ភស្តុតាង-----------------------------------------------------------------------------------------------៣១
តួលេខទី១៣ ៖ សិទ្ធិហៅ និងសាកសួរសាក្សី-------------------------------------------------------------------------៣១
តួលេខទី១៤ ៖ សិទ្ធិទទួលដឹងឮភស្តុតាង--------------------------------------------------------------------------៣៣
តួលេខទី១៥ ៖ សិទ្ធិមិនត្រូវបានបង្ខំឲ្យសារភាព----------------------------------------------------------------៣៣
តួលេខទី១៦ ៖ ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ---------------------៣៥
តួលេខទី១៧ ៖ សវនាការដែលមានជនជាប់ចោទជាអនីតិជន ---------------------------------------------------៣៦
តួលេខទី១៨ ៖ អនីតិជន និងភាពឯកជន-----------------------------------------------------------------------------៣៧
តួលេខទី១៩ ៖ អនីតិជន និងការឃុំខ្លួនបណ្តោះអាសន្ន -------------------------------------------------------៣៨
តួលេខទី២០ ៖ អនីតិជន និងការផ្តន្ទាទោស ---------------------------------------------------------------------៤០
តួលេខទី២១ ៖ ការឃុំខ្លួនបណ្តោះអាសន្នលើសពេលកំណត់ --------------------------------------------------៤៣
តួលេខទី២២ ៖ ទំនាក់ទំនងរវាងការពន្យល់អំពីសិទ្ធិ និងកង្វះខាតមេធាវី---------------------------------------៥២
តួលេខទី២៣ ៖ ការសន្ទនាក្នុងអំឡុងពេលពិភាក្សាសម្រេច ------------------------------------------------------៥៧

# ការពន្យល់អត្ថន័យ

| | |
|---|---|
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| គម្រោង | គម្រោងសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| តុលាការរាជធានីភ្នំពេញ | សាលាដំបូងរាជធានីភ្នំពេញ |
| តុលាការខេត្តកណ្តាល | សាលាដំបូងខេត្តកណ្តាល |
| អំឡុងរបាយការណ៍ទី១ | អំឡុងរបាយការណ៍ទី១ ចាប់ពីថ្ងៃទី១០ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ |
| អំឡុងរបាយការណ៍ទី២ | អំឡុងរបាយការណ៍ទី២ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ |
| អំឡុងរបាយការណ៍ទី៣ | អំឡុងរបាយការណ៍ទី៣ ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ |
| អំឡុងរបាយការណ៍ទី៤ | អំឡុងរបាយការណ៍ទី៤ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១១ |
| របាយការណ៍ | របាយការណ៍ប្រចាំឆមាសលើកទី៤ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា |
| របាយការណ៍ទី១ | របាយការណ៍ប្រចាំឆមាសលើកទី១ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា បោះពុម្ពផ្សាយនៅខែកក្កដា ឆ្នាំ២០១០ |
| របាយការណ៍ទី២ | របាយការណ៍ប្រចាំឆមាសលើកទី២ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា បោះពុម្ពផ្សាយនៅខែមីនា ឆ្នាំ២០១១ |
| របាយការណ៍ទី៣ | របាយការណ៍ប្រចាំឆមាសលើកទី៣ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា - ការវិវឌ្ឍក្នុងរយៈពេលមួយឆ្នាំ បោះពុម្ពផ្សាយនៅខែមករាឆ្នាំ២០១២ |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ |
| មន្ត្រីសង្កេតការណ៍ | មន្ត្រីសង្កេតការណ៍នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ជាប្រព័ន្ធដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាប្រើសម្រាប់ផ្ទុកទិន្នន័យដែលប្រមូលបានពីការសង្កេតការណ៍សវនាការ |

# ខ្លឹមសារសង្ខេប

របាយការណ៍ប្រចាំឆមាសស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជានេះ (របាយ-ការណ៍) គឺជាលទ្ធផលមួយនៃគម្រោងសង្កេតការណ៍សវនាការនៅកម្ពុជា (គម្រោង) ដែលអនុវត្តដោយ ម.ស.ម.ក។ របាយការណ៍នេះបង្ហាញ និងវិភាគនូវទិន្នន័យដែលប្រមូលបានពីការសង្កេតការណ៍សវនាការចំនួន៣៩៨ដែលរួមមានជនជាប់ចោទចំនួន៦៨៨នៅសាលាដំបូងរាជធានីភ្នំពេញ(តុលាការរាជធានីភ្នំពេញ) និងសាលាដំបូងខេត្តកណ្តាល(តុលាការខេត្តកណ្តាល) ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ (អំឡុងពេលរបាយការណ៍ទី៤)។ នេះគឺជារបាយការណ៍ប្រចាំឆមាសលើកទី៤នៃគម្រោង។

## ក្របខ័ណ្ឌច្បាប់

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) ធានាភាពឯករាជ្យរបស់តុលាការ ព្រមទាំងសិទ្ធិសន្មតទុកមុនថាគ្មានទោសរហូតដល់ពេលពិរុទ្ធភាពត្រូវបានរកឃើញ។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌ) បានចែងពីនីតិវិធីនៃការស៊ើបសួរ និងនីតិវិធីសវនាការបទល្មើសព្រហ្មទណ្ឌ ព្រមទាំងបទប្បញ្ញត្តិមួយចំនួនទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជា-ណាចក្រកម្ពុជា (ក្រមព្រហ្មទណ្ឌ) ដែលត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ២០០៩ និងចូលជាធរមាននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ បានចែងអំពីប្រភេទបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។ ប្រទេសកម្ពុជាក៏ត្រូវបានចងភ្ជាប់ដោយកិច្ចព្រមព្រៀងអន្តរជាតិដែលខ្លួនជាភាគីផងដែរ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយសុទ្ធតែធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយតុលាការមួយឯករាជ្យ និងមិនលំអៀង។

## វិធីសាស្រ្ត

មន្ត្រីសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ចូលរួមសវនាការលើរឿងបទល្មើសព្រហ្មទណ្ឌនៅតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តកណ្តាលជារៀងរាល់ថ្ងៃដោយប្រើតារាងសង្កេតការណ៍សវនា-ការ ដែលមានសំណួរប្រមាណជាង៧០ជាឧបករណ៍សម្រាប់វាស់ស្ទង់នូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសវនាការនីមួយៗ និងចំពោះជនជាប់ចោទនីមួយៗ។

បច្ចុប្បន្ននេះ ម.ស.ម.ក បានចេញផ្សាយរបាយការណ៍ប្រចាំឆមាសបានចំនួន៣លើករួចមកហើយ។ បន្ទាប់ពីរបាយការណ៍ប្រចាំឆមាសនីមួយៗត្រូវបានបោះពុម្ពផ្សាយ បុគ្គលិកគម្រោងនឹងធ្វើការណាត់ជួបជាមួយតំណាងតុលាការដែលបានសង្កេត ព្រមទាំងអង្គការ អង្គភាព ស្ថាប័នផ្នែកយុត្តិធម៌ដទៃទៀត ដើម្បីពិភាក្សាអំពីអនុសាសន៍ផ្តល់ដោយរបាយការណ៍។ កិច្ចប្រជុំនេះជាមូលដ្ឋានផ្លាស់ប្តូរគំនិត និងផ្តល់លទ្ធភាពឲ្យយល់កាន់តែច្បាស់អំពីបញ្ហាប្រឈមដែលបានជួបប្រទះដោយស្ថាប័នដែលធ្វើការពង្រឹងប្រព័ន្ធយុត្តិធម៌។ កិច្ចប្រជុំពិភាក្សានេះមានគោលបំណងលើកកម្ពស់ការអនុវត្តអនុសាសន៍ ដែលបានផ្តល់ឲ្យដោយរបាយ-ការណ៍ប្រចាំឆមាស។

ទិន្នន័យក្នុងរបាយការណ៍នេះ ត្រូវបានយកទៅប្រៀបធៀបជាមួយនឹងទិន្នន័យដែលប្រមូលបាននៅក្នុងអំឡុងពេលរបាយការណ៍ទី១ ចាប់ពីថ្ងៃទី១០ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ (អំឡុងពេលរបាយ-ការណ៍ទី១) អំឡុងរបាយការណ៍ទី២ ចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ (អំឡុងពេលរបាយការណ៍ទី២) និងអំឡុងរបាយការណ៍ទី៣ចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ (អំឡុងពេលរបាយការណ៍ទី៣) ក្នុងគោលបំណងកំណត់អំពីភាពផ្លាស់ប្តូរនៃការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងតុលាការទាំងពីរដែលបានអង្កេត។ កិច្ចពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធបន្ទាប់ពីការបោះពុម្ព

ផ្សាយរបាយការណ៍ប្រចាំឆមាសលើកទី១ បានបង្ហាញនូវឥរិយាបថវិជ្ជមាន និងបែបស្ថាបនាពីស្ថាប័នភាគច្រើន និងឆន្ទៈក្នុងការពិចារណាទៅលើអនុសាសន៍ដែលបានផ្តល់ឲ្យ។

## ទិន្នន័យសង្ខេប

ចៅក្រមនៅតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តកណ្តាល បានបំពេញការងារបានល្អ ទាក់ទងនឹងការគោរពបទដ្ឋាននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមួយនឹងសម្មិទ្ធិផលជាវិជ្ជមានមួយចំនួន។ ចំនួនសវនាការដែលមេធាវីចុងចោទបានលើកឡើងអំពីបញ្ហាពេលវេលា និងសម្ភារៈរូបវន្តមិនគ្រប់គ្រាន់មានការថយចុះ។ ទិន្នន័យក៏បានបង្ហាញផងដែរ អំពីចំណាត់ការវិជ្ជមានរបស់តុលាការទៅលើភស្តុតាង និងសាក្សី។ ការគោរពសិទ្ធិក្នុងការទទួលបានសវនាការជាសាធារណៈក៏មានការកើនឡើងផងដែរដោយសារតែព័ត៌មានពាក់ព័ន្ធនឹងសវនាការដែលបានសង្កេតចំនួនជិតពាក់កណ្តាល ត្រូវបានបិទផ្សាយជាសាធារណៈនៅលើក្តារខៀនព័ត៌មាន។

ភាពមិនលំអៀង ឯករាជ្យភាព និងវិជ្ជាជីវៈរបស់ចៅក្រមក៏មានការរីកចំរើនគួរឲ្យកត់សំគាល់។ មិនមានករណីដែលបានសង្កេតការណ៍បង្ហាញថា ចៅក្រមមានចំណាប់អារម្មណ៍លើករណីមុនពេលមានសវនាការលើសពីតួនាទីរបស់ខ្លួនទេ។ លើសពីនេះទៅទៀតចំនួននៃករណីដែលចៅក្រមនិយាយទៅកាន់ភាគីក្នុងអំឡុងពេលពិភាក្សាសម្រេចមានការថយចុះដោយមានតែ៥%ប៉ុណ្ណោះ នៃចំនួនសវនាការទាំងអស់ដែលបានសង្កេត។ នេះជាការរីកចម្រើនពីអំឡុងពេលរបាយការណ៍មុន។ ក៏ប៉ុន្តែករណីដែលមានការពិភាក្សារវាងចៅក្រម និងភាគីក្នុងអំឡុងពេលពិភាក្សាសម្រេចសេចក្តីនៅតែជាបញ្ហាដូចជាការចូលរួមរបស់ក្រឡាបញ្ជី និងភាគីដទៃទៀតទៅក្នុងបន្ទប់ពិភាក្សាសម្រេច ដោយមិនមានហេតុផលច្បាស់លាស់ក្លាយជាបញ្ហាទាក់ទងនឹងឯករាជ្យភាព និងភាពមិនលំអៀងរបស់ចៅក្រម។ វាមានការធ្លាក់ចុះបន្តិចបន្តួចនូវភាគរយនៃចំនួនសវនាការ ដែលចៅក្រមបានប្រើប្រាស់ទូរស័ព្ទនៅពេល សវនាការកំពុងដំណើរការនីតិវិធីពី២២% នៅក្នុងអំឡុងពេលរបាយការណ៍ទី៣ ទៅ១៨%នៅក្នុងអំឡុងពេលរបាយការណ៍ទី៤។ ៤០%នៃករណីទាំងនោះបង្ហាញថាចៅក្រមបានធ្វើការសន្ទនាតាមទូរស័ព្ទ។ វាជាការកើនឡើងចាប់តាំងពីអំឡុងពេលរបាយការណ៍ទី៣។ នៅខណៈដែលការសន្ទនាភាគច្រើនត្រូវបានធ្វើឡើងដោយសង្ខេប - ៦០% នៃចៅក្រមបានសន្ទនាតាមទូរស័ព្ទដោយសង្ខេប និងដាក់ទូរស័ព្ទចុះ - វាជាការបន្ទាបតម្លៃនៃដំណើរការនីតិវិធីសវនាការ។ ការធ្វើការសន្ទនាតាមទូរស័ព្ទអំឡុងពេលសវនាការធ្វើឲ្យរំខានដល់អង្គសវនាការ និងបង្កើតជាសំនួរថាតើចៅក្រមមានបានចូលរួម និងស្តាប់នៅក្នុងសវនាការឬទេ។

ថ្វីបើមានការរីកចម្រើនមួយចំនួនទៅលើការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ប្រសិនបើប្រៀបធៀបទៅនឹងអំឡុងពេលរបាយការណ៍មុនក៏ដោយ ក៏នៅតែមានចំនុចព្រួយបារម្ភមួយចំនួននៅសេសសល់នៅឡើយ។ ជនជាប់ចោទនៅតែស្ថិតក្នុងសវនាការដោយមានសំលៀកបំពាក់ជាអ្នកទោសហើយទឡ្ហីករណ៍នៃកិរិយាមិនត្រឹមត្រូវរបស់មន្ត្រីនគរបាលក៏ត្រូវបានកំណត់សំគាល់ផងដែរ ដូចជាការគំរាមកំហែង ការប្រើអំពើហិង្សា និងការធ្វើទារុណកម្មដើម្បីទទួលបាននូវចម្លើយសារភាព។ ភាគរយនៃករណីនៃការគំរាមកំហែង ប្រើអំពើហិង្សាទៅលើរូបរាងកាយ និងការធ្វើទារុណកម្មលើជនជាប់ចោទដើម្បីទទួលបានចម្លើយសារភាពគឺមានការធ្លាក់ចុះពី៣% ទៅ៦% នៅគ្រប់សវនាការដែលបានសង្កេត។ មន្ត្រីនគរបាលត្រូវតែជៀសវាងប្រព្រឹត្តនូវការគំរាមកំហែង ឬការប្រើអំពើហិង្សាប្រឆាំងនឹងជនសង្ស័យ ឬជនជាប់ចោទនោះឡើយ។ វាជាការសំខាន់ណាស់សម្រាប់ចៅក្រមដោយយោងតាមរដ្ឋធម្មនុញ្ញ និងក្រមនីតិវិធីព្រហ្មទណ្ឌត្រូវមានការប្រយ័ត្នប្រយែងខ្ពស់នៅពេលធ្វើការពិចារណាលើចម្លើយសារភាពណាមួយ ដែលត្រូវបានត្រៀមទុកជាស្រេចដោយការបង្ខិតបង្ខំមិនត្រឹមត្រូវ។

អត្រាសរុបនៃការឃុំខ្លួនបណ្តោះអាសន្ននៅតែមានកម្រិតខ្ពស់ ជាពិសេសនៅក្នុងករណីបទល្មើសមជ្ឈិម។ ចំនួននៃសវនាការដែលមានការឃុំខ្លួនបណ្តោះអាសន្នមានការកើនឡើងបន្តិចបន្តួចដោយកើនពី៨០%នៃសវនាការដែលបានសង្កេតនៅក្នុងអំឡុងពេលសង្កេតទី៣ទៅ៨៣% នៅក្នុងអំឡុងពេលសង្កេតទី៤ ទោះជាចំនួននេះនៅតិចជាងអំឡុងពេលសង្កេតទី១ក៏ដោយ(៨៨%)។ ប្រសិនបើពិនិត្យមើលជនជាប់ចោទម្នាក់ៗវិញ៦៤% នៃជនជាប់ចោទត្រូវបានតុលាការអនុវត្តការឃុំខ្លួនបណ្តោះអាសន្ន។ ចំនួននៃជនជាប់ចោទដែលចោទប្រកាន់ពីបទមជ្ឈិមហើយដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នមានការកើនឡើងពី៤៦% នៅក្នុងអំឡុងពេលសង្កេតទី៣ ដល់៥៧,៤%ក្នុងអំឡុងពេលសង្កេតទី៤។ វាជាកត្តាសំខាន់សម្រាប់ចៅក្រមដោយត្រូវមានការប្រុងប្រយ័ត្នខ្ពស់នៅពេលអនុវត្តច្បាប់ ដូច្នេះទើបការឃុំខ្លួនបណ្តោះអាសន្នត្រូវបានអនុវត្តតែនៅក្នុងស្ថានភាពជាក់លាក់ណាមួយ ហើយករណីដែលមានការឃុំខ្លួនបណ្តោះអាសន្ននោះគឺជាករណីលើកលែងជាជាងវិធានទូទៅ។

ដោយយោងទៅលើសិទ្ធិមានមេធាវីតំណាងមន្ត្រីសង្កេតការណ៍សវនាការបង្ហាញថា៦០% នៃសវនាការជនជាប់ចោទមានមេធាវីតំណាងខ្លួន។ នៅពេលដែលក្រឡេកទៅមើលជនជាប់ចោទម្នាក់ៗវិញ ទិន្នន័យបានបង្ហាញថា ច្រើនជាងពាក់កណ្តាលនៃជនជាប់ចោទចំនួន៦៨៨ គឺជនជាប់ចោទចំនួន៣៨១នាក់ (ស្មើនឹង៥៥%) មានមេធាវីតំណាងឲ្យខ្លួនក្នុងអង្គសវនាការ។ នេះជាការអត្រាធ្លាក់ចុះពីអំឡុងពេលសង្កេតទី៣ដែលក្នុងចំណោមជនជាប់ចោទចំនួន១,០២៩នាក់មានជនជាប់ចោទចំនួន៦៣៣នាក់ (ស្មើនឹង៦២%) មានមេធាវីតំណាងក្នុងអង្គសវនាការ។ មន្ត្រីសង្កេតការណ៍សវនាការក៏បានបង្ហាញទៀតថា នៅក្នុង១០០% នៃសវនាការពាក់ព័ន្ធនឹងបទឧក្រិដ្ឋ សុទ្ធតែមានមេធាវីការពារទាំងអស់។ ក៏ប៉ុន្តែប្រសិនបើក្រឡេកមើលជនជាប់ចោទម្នាក់ៗក្នុងករណីបទឧក្រិដ្ឋវិញគឺមានតែ៩០% ប៉ុណ្ណោះនៃចំនួនជនជាប់ចោទដែលមានមេធាវីតំណាង។ អត្រានៃការមានមេធាវីតំណាងជនជាប់ចោទក្នុងករណីបទមជ្ឈិមនៅតែមានកម្រិតទាបគឺ៣២%នៃចំនួនជនជាប់ចោទម្នាក់ៗប៉ុណ្ណោះដែលមានមេធាវីការពារ។ នៅខណៈដែលច្បាប់មិនបានតម្រូវឲ្យត្រូវតែមានមេធាវីចំពោះជនជាប់ចោទក្នុងករណីបទមជ្ឈិម លុះត្រាតែជាអនីតិជន នោះការមានត្រឹមតែច្រើនជាងមួយភាគបួននៃជនជាប់ចោទដែលមានមេធាវីបែបនេះ បង្កើតឲ្យមាននូវការព្រួយបារម្ភអំពីគោលការណ៍ស្មើភាពគ្នា។

ទាក់ទងនឹងសវនាការរឿងអនីតិជន វិធានការណ៍ដែលបានដាក់ចេញដើម្បីការពារភាពឯកជនរបស់ជនជាប់ជាអនីតិជនមានភាពប្រសើរឡើង។ ក៏ប៉ុន្តែអត្រានៃការឃុំខ្លួនបណ្តោះអាសន្នទៅលើជនជាប់ចោទជាអនីតិជននៅតែមានកម្រិតខ្ពស់។ មន្ត្រីសង្កេតសវនាការបានកត់សម្គាល់ឃើញថាប្រព័ន្ធយុត្តិធម៌សម្រាប់អនីតិជននៅតែបន្តអនុវត្តការការដាក់ទោសពន្ធនាគារទៅលើអនីតិជន ជាជាងការដាក់ទោសមិនមែនពន្ធនាគារ ទោះបីជាមានមាត្រា៣៩នៃក្រមព្រហ្មទណ្ឌក៏ដោយ ដែលនេះបង្កើតឲ្យមានសច្ចធារណ៍គតិយុត្តិប្រឆាំងនឹងការឃុំខ្លួនអនីតិជន។

## សេចក្តីសន្និដ្ឋាន

ទិន្នន័យដែលបានមកពីសវនាការចំនួន៣៩៨ ដែលបានសង្កេតអំឡុងពេលរបាយការណ៍ទី៤ រួមទាំងជនជាប់ចោទម្នាក់ៗចំនួន៦៨៨ បានបង្ហាញនូវចំនុចមួយចំនួនដែលត្រូវបានកែប្រែដើម្បីឲ្យមានការគោរពនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ការផ្សព្វផ្សាយជាសាធារណៈអំពីពេលវេលាសវនាការត្រូវបានធ្វើឲ្យកាន់តែប្រសើរឡើងជាងមុន។ ករណីដែលចៅក្រមបានពោលពាក្យដែលបង្ហាញនូវការយល់ដឹងមិនពេញលេញអំពីគោលការណ៍សន្មតជាមុនថាគ្មានទោសនៅក្នុងសវនាការមានចំនួនតិចតួចប៉ុណ្ណោះ។
ចំណាត់ការ របស់តុលាការលើភស្តុតាង និងសាក្សី នៅតែជាចំណុចវិជ្ជមាន ដោយបានផ្តល់ឱកាសស្មើគ្នាដល់ភាគីនៃរឿងក្តី ក្នុងការបង្ហាញ និងត្រួតពិនិត្យភស្តុតាង។ ប៉ុន្តែ នៅតែមានការព្រួយបារម្ភចំពោះការឃុំខ្លួន

បណ្តោះអាសន្នដែលមានកម្រិតខ្ពស់ និងកម្រិតទាបនៃការមានមេធាវីនៅក្នុងបទមជ្ឈិម។ ចៅក្រមនៅតែបន្ត ប្រើប្រាស់ទូរស័ព្ទដៃនៅក្នុងពេលជំនុំជម្រះ។

អនុសាសន៍ក្នុងរបាយការណ៍នេះត្រូវបានផ្តល់ជូនទៅអង្គភាព និងស្ថាប័នមួយចំនួន ដោយបង្ហាញអំពី ភាពជាប់ពាក់ព័ន្ធនៃស្ថាប័នទាំងនោះ នៅក្នុងប្រព័ន្ធយុត្តិធម៌។ ទោះបីជាការសង្កេតការណ៍សវនាការកើត ឡើងតែនៅក្នុងបន្ទប់តុលាការ ការបង្កើនការគោរពសិទ្ធិមួយចំនួនដែលបានវិភាគក្នុងរបាយការណ៍នេះតម្រូវ ឲ្យមានកិច្ចសហប្រតិបត្តិការ ការគាំទ្រ និងការដឹកនាំពីតួអង្គមួយចំនួនរួមមានដូចជា រាជរដ្ឋាភិបាល កម្ពុជាក្រសួងយុត្តិធម៌ភ្នាក់ងារអនុវត្តច្បាប់ អាជ្ញាធរពន្ធនាគារ និងអង្គការមិនមែនរដ្ឋាភិបាលនានានិងអង្គការ ផ្សេងទៀតដែលពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ការឃុំខ្លួនបណ្តោះអាសន្ន និងសិទ្ធិមាន មេធាវី ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ គឺជាចំណុចពីរ ដែលតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការ បន្ថែមដើម្បីបង្កើនការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ យើងសង្ឃឹមទុកថា ទិន្នន័យ និង អនុសាសន៍ដែលមាននៅក្នុងរបាយការណ៍នេះ នឹងអាចជួយបង្កើននូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌ និងគាំទ្រការងារទាំងនោះដើម្បីធានាថា ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាអាចផ្តល់យុត្តិធម៌ និងសម ភាពដល់បុគ្គលគ្រប់រូប។

# ១.សេចក្តីផ្តើម

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាសិទ្ធិដែលត្រូវបានទទួលស្គាល់ជាសកល និងស្ថិតនៅកម្រិតខ្ពស់បំផុតក្នុងច្បាប់អន្តរជាតិ ទាំងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស[1] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[2] សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានធានាដោយច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ)[3] និងត្រូវបានធានាដោយបទប្បញ្ញត្តិមួយចំនួនក្នុងច្បាប់ជាតិ។[4] សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ កើតឡើងចេញពីសិទ្ធិជាក់លាក់មួយចំនួន រួមទាំងសិទ្ធិនៅក្នុងដំណាក់កាលមុនសវនាការ ដែលត្រូវបានទទួលស្គាល់ និងផ្តល់ឲ្យនៅក្នុងពេលនោះ ដើម្បីធានាថា បុគ្គលណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ទទួលបានការយកចិត្តទុកដាក់យ៉ាងសមគួរ នៅក្នុងខណៈដែលរដ្ឋកំណត់អំពីភាពមាន ឬគ្មានទោសរបស់បុគ្គលនោះ។

## ក្របខណ្ឌច្បាប់

នៅក្នុងច្បាប់អន្តរជាតិសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានធានាថា បុគ្គលដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបាននូវការជំនុំជម្រះមួយដោយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្តីមួយឯករាជ្យ និងមិនលំអៀង[5] និងមានសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស រហូតដល់ពេលដែលពិរុទ្ធភាពត្រូវបានរកឃើញតាមច្បាប់។[6] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ត្រូវបានដាក់បញ្ចូលផងដែរ ទៅក្នុងប្រព័ន្ធច្បាប់ជាតិ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញបានចែងថាកម្ពុជា *"ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុង [...] កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស"*។ ចំណុចនេះត្រូវបានបញ្ជាក់បន្ថែម ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ដែលបញ្ជាក់ថា *"អនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់"* ជាផ្នែកមួយនៃច្បាប់ ដែលចៅក្រមជំនុំជម្រះត្រូវយកមកពិចារណា។[7]

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក៏ត្រូវបានបញ្ញត្តិដោយច្បាប់ក្នុងស្រុកផងដែរ ដូចជាមាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធានាថា *"ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់"* រីឯមាត្រា១២៨ ចែងថា *"អំណាចតុលាការជាអំណាចឯករាជ្យ។ តុលាការត្រូវតែធានារក្សាអនាគតិ*

---

[1]មហាសន្និបាតអង្គការសហប្រជាជាតិ- មាត្រា១០នៃ*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*ចុះថ្ងៃទី១០ខែធ្នូឆ្នាំ១៩៤៨។

[2]មហាសន្និបាតអង្គការសហប្រជាជាតិ- មាត្រា១៤នៃ*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ* ចុះថ្ងៃទី១៦ខែធ្នូឆ្នាំ១៩៦៦។

[3]មាត្រា៣១នៃរដ្ឋធម្មនុញ្ញធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមរយៈការរួមបញ្ចូលសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអនុសញ្ញាអន្តរជាតិដទៃទៀត រួមទាំង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយទៅក្នុងអត្ថបទរបស់ខ្លួន។ មាត្រា៣៨ និងមាត្រា១២៨នៃរដ្ឋធម្មនុញ្ញក៏បានធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដទៃទៀតផងដែរ។

[4]ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងអំពីសិទ្ធិមួយចំនួននៅក្នុងនីតិវិធីដែលជួយធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។ ឧទាហរណ៍មាត្រា៣០០ចែងថាជនជាប់ចោទត្រូវអមដោយមេធាវីដែលខ្លួនបានជ្រើសរើស។

[5]មាត្រា១០នៃសេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស។ មាត្រា១៤(១)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

[6]មាត្រា១១ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។មាត្រា១៤ (២)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

[7]សេចក្តីសម្រេចលេខ០៩២/០០៣/២០០៧នៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី១០ខែកក្កដាឆ្នាំ២០០៧។

*និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។* ច្បាប់ក្នុងស្រុកដទៃទៀតក៏បានបញ្ញត្តិនូវការធានានេះផងដែរ ដូចជានីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាត្រូវបានចងក្រងក្នុងឆ្នាំ២០០៧ ជាក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលជំនួសបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ១៩៩២ (ច្បាប់អ៊ុនតាក់)។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាងលំអិតអំពីនីតិវិធីច្បាប់សម្រាប់ការស៊ើបសួរ និងការជំនុំជម្រះករណីបទល្មើសព្រហ្មទណ្ឌ ព្រមទាំងសិទ្ធិរបស់ជនរងគ្រោះ និងសិទ្ធិជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ក្រមព្រហ្មទណ្ឌ) ដែលត្រូវបានប្រកាសឲ្យប្រើនៅឆ្នាំ ២០០៩ ជាច្បាប់មួយដ៏ទូលំទូលាយ ដែលកំណត់ចំណាត់ថ្នាក់នៃបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ គោលការណ៍នៃការផ្តន្ទាទោស ដែនយុត្តាធិការនៃតុលាការ និងបទល្មើសព្រហ្មទណ្ឌថ្មីៗជាច្រើនទៀត។ ក្រមព្រហ្មទណ្ឌបានចូលជាធរមាននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០នៅរាជធានីភ្នំពេញ និងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០នៅទូទាំងប្រទេស។ ហេតុដូច្នេះហើយអំឡុងរបាយការណ៍ទី៤គឺជាឱកាសដំបូងសម្រាប់ ម.ស.ម.ក ក្នុងការធ្វើការសង្កេតការណ៍ទៅលើការអនុវត្តក្រមព្រហ្មទណ្ឌដោយតុលាការ។

## បរិបទនយោបាយ

រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) បានទទួលស្គាល់នូវសារៈសំខាន់នៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ថាជាមូលដ្ឋាននៃការអភិវឌ្ឍន៍ សមភាព និងប្រសិទ្ធភាពនៅកម្ពុជា។[8] កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ត្រូវបានធ្វើឡើងស្របតាមយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (យុទ្ធសាស្ត្រ) ដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣។[9] យុទ្ធ-សាស្ត្រនេះបានកំណត់នូវគោលការណ៍ណែនាំចំនួន៤ ដែលដកស្រង់ចេញពីបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ដើម្បីដឹកនាំកំណែទម្រង់នោះ មានដូចជា សិទ្ធិបុគ្គល ប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។[10] យុទ្ធសាស្ត្របានដាក់ចេញនូវគោលដៅចំនួន៧ ដែលបង្កើតជាមូលដ្ឋានផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ អនុម័តនៅឆ្នាំ ២០០៥។[11]

គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក (គម្រោង) ជាការសង្កេតការណ៍សវនាការមួយឯករាជ្យ និងមិនលំអៀងនៅកម្ពុជា ដែលដំណើរការអស់រយៈពេលជាងពីរឆ្នាំមកហើយ។ ក្នុងតួនាទីជាអ្នកសង្កេតការណ៍ដោយឯករាជ្យ និងមិនលំអៀងនេះ គម្រោងមានគោលបំណងប្រមូលទិន្នន័យដែលអាចយកមកវិភាគបាន ដើម្បីកំណត់ពីភាពខ្លាំង និងភាពខ្សោយរបស់ប្រព័ន្ធតុលាការ។ តាមរយៈការទាញចំណាប់អារម្មណ៍ទៅលើផ្នែកពាក់ព័ន្ធនឹងដំណើរការជំនុំជម្រះ ដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្លាំង និងផ្តល់ជាអនុសាសន៍ជាក់ស្តែងដល់ស្ថាប័ននានាដែលពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ ម.ស.ម.ក គាំទ្រនូវកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹង និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌សម្រាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងអស់។

---

[8] សុន្ទរកថារបស់សម្តេចហ៊ុនសែនស្តីពីយុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌និងប្រសិទ្ធិភាពក្នុងដំណាក់កាលទី២ថ្លែងនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកដំបូងក្នុងនីតិកាលទី៤នៅទីស្តីការគណៈរដ្ឋមន្ត្រីរាជធានីភ្នំពេញថ្ងៃទី២៦ខែកញ្ញាឆ្នាំ២០០៨។

[9] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ -*យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌* អនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងសម័យប្រជុំពេញអង្គនៅថ្ងៃទី២០ខែមិថុនាឆ្នាំ២០០៣។

[10] ដូចខាងលើទំព័រទី ៣។

[11] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ -*ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌*អនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងសម័យប្រជុំពេញអង្គនៅថ្ងៃទី២៩ខែមេសាឆ្នាំ២០០៥។

## គោលបំណងក្រុមគោលដៅនិងវិសាលភាពនៃរបាយការណ៍

របាយការណ៍នេះជារបាយការណ៍ប្រចាំឆមាសលើកទី៤ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជាដែលចងក្រងដោយគម្រោង។ មុនពេលដែលរបាយការណ៍នេះត្រូវបានបោះពុម្ពផ្សាយ សេចក្តីព្រាងរបាយការណ៍ត្រូវបានផ្ញើជូនប្រធានសាលាដំបូងរាជធានីភ្នំពេញ និងប្រធានសាលាដំបូងខេត្តកណ្តាល ដើម្បីផ្តល់ឱកាសឲ្យតុលាការដែលបានសង្កេត ផ្តល់មតិកែលម្អ យោបល់ និងអនុសាសន៍បន្ថែម។

របាយការណ៍ប្រចាំឆមាសទី១ ត្រូវបានចេញផ្សាយនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១០(របាយការណ៍ប្រចាំឆមាសទី១) របាយការណ៍ប្រចាំឆមាសទី២ បានចេញផ្សាយនៅថ្ងៃទី២២ ខែមិនា ឆ្នាំ២០១១(របាយការណ៍ប្រចាំឆមាសទី២) និងរបាយការណ៍ប្រចាំឆមាសទី៣បានចេញផ្សាយនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ (របាយការណ៍ប្រចាំឆមាសទី៣)។

រចនាសម្ព័ន្ធនៃរបាយការណ៍នេះមានលក្ខណៈដូចតទៅ៖ ផ្នែកទី២ បង្ហាញអំពីវិធីសាស្ត្រដែលនឹងត្រូវអនុវត្តនៅពេលប្រមូលទិន្នន័យ និងរៀបចំរបាយការណ៍នេះ។ ផ្នែកទី៣ "ទិន្នន័យ និងការពន្យល់"បង្ហាញអំពីទិន្នន័យដែលប្រមូលបានពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ (អំឡុងពេលរបាយការណ៍ទី៤) និងវិភាគស្របជាមួយទិន្នន័យដែលប្រមូលបានពីថ្ងៃទី១០ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩(អំឡុងពេលរបាយការណ៍ទី១) និងទិន្នន័យដែលប្រមូលបានពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ (អំឡុងពេលរបាយការណ៍ទី២) ព្រមទាំងទិន្នន័យដែលប្រមូលបានពីថ្ងៃទី០១ ខែសីហាដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ (អំឡុងរបាយការណ៍ទី៣) ក្នុងគោលបំណងកំណត់អំពីការផ្លាស់ប្តូរនៃការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ក្នុងផ្នែកទី៤ "សេចក្តីសន្និដ្ឋាននិងអនុសាសន៍" គឺការផ្តល់នូវអនុសាសន៍លើបញ្ហាដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌។

# ២. វិធីសាស្ត្រ

គម្រោងនេះត្រូវបានអនុវត្តដោយ ម.ស.ម.ក នៅក្នុងក្របខ័ណ្ឌកម្មវិធី គោលនយោបាយ និងការតស៊ូមតិ។ គម្រោងត្រូវបានអនុវត្ត ហើយរបាយការណ៍ត្រូវបានរៀបរៀង ស្របតាមវិធីសាស្ត្រដែលត្រូវបានរៀបរាប់នៅក្នុងជំពូកនេះ។ យើងសង្ឃឹមថា វិធីសាស្ត្រនេះអាចនឹងត្រូវបានចែករំលែក និងដាក់ក្នុងកិច្ចពិភាក្សាជាមួយអង្គការដទៃទៀត ដែលមានបំណងចង់ធ្វើការសង្កេតការណ៍សវនាការនៅកម្ពុជា ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យនេះ និងសម្រួលដល់កិច្ចពិភាក្សាក្នុងន័យស្ថាបនារវាងអ្នកពាក់ព័ន្ធទាំងអស់ដែលមានបំណងបង្កើនការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា។

## រយៈពេលនិងទីតាំង

របាយការណ៍នេះបង្ហាញ និងវិភាគទិន្នន័យបានមកពីសវនាការរឿងក្តីព្រហ្មទណ្ឌចំនួន៣៩៨ ដែលមានជនជាប់ចោទចំនួន៦៨៨ ហើយដែលបានសង្កេតនៅតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តកណ្តាលក្នុងអំឡុងពេលរបាយការណ៍ទី៤(ថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១)។ តុលាការរាជធានីភ្នំពេញត្រូវបានជ្រើសរើសជាគោលដៅនៃគម្រោងព្រោះជាតុលាការដែលស្ថិតនៅក្នុងរាជធានី និងមានវិសាលភាពធំ និងជាតំបន់ដែលមានប្រជាជនច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា។ តុលាការនេះមានសកម្មភាពច្រើន ហើយការប្រព្រឹត្តទៅរបស់តុលាការនេះត្រូវបានរាយការណ៍យ៉ាងទូលាយ និងមានឥទ្ធិពលខ្លាំងជាងសាលាដំបូងដទៃទៀតនៅកម្ពុជា។ តុលាការខេត្តកណ្តាលត្រូវបានជ្រើសរើសដោយសារតែតុលាការនេះមានទីតាំងនៅជិតរាជធានីភ្នំពេញ មានចៅក្រមភាគច្រើនធ្វើជាប្រធាននៅទីនោះ និងមានបន្ទប់សវនាការចំនួន៣ សម្រាប់សង្កេតសវនាការ។

## សិទ្ធិសំខាន់ៗដែលជ្រើសរើសសម្រាប់សង្កេតសវនាការ

ការសង្កេតការណ៍សវនាការ ផ្តោតលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាក់លាក់មួយចំនួនដែលត្រូវបានយកមកអនុវត្តក្នុងបរិបទប្រទេសកម្ពុជា។ ដើម្បីកំណត់ថាសិទ្ធិណាខ្លះត្រូវបានលើកយកមកថ្លឹងថ្លែង ម.ស.ម.ក ពឹងផ្អែកលើធនធានខាងក្រៅ ដូចជារបាយការណ៍ និងការសិក្សាស្រាវជ្រាវផ្សេងៗអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា និងអំពីប្រព័ន្ធតុលាការកម្ពុជា។[12] ដូច្នេះ គ្មានការសន្និដ្ឋានវិជ្ជមាន ឬអវិជ្ជមានណាមួយត្រូវបានទាញចេញពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដទៃទៀតដែលមិនស្ថិតនៅក្នុងរបាយការណ៍នេះឡើយ។

សិទ្ធិខាងក្រោមត្រូវបានជ្រើសរើសសម្រាប់ការសង្កេតការណ៍សវនាការ៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល
- សិទ្ធិយល់ដឹងអំពីបទចោទប្រកាន់
- សិទ្ធិទទួលបានការពន្យល់ប្រាប់សិទ្ធិ

---

[12] ឧទាហរណ៍៖គណៈកម្មការអ្នកច្បាប់អន្តរជាតិ - *បទអត្ថាធិប្បាយអំពីរបាយការណ៍បឋមរបស់កម្ពុជាស្តីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌* (ហ្សឺណែវ៖គណៈកម្មការអ្នកច្បាប់អន្តរជាតិខែមេសា ឆ្នាំ២០០៩)។រីឆាតប្លូនិងរ៉ូបឺតអាន់ដឺរូត *ការវាយតម្លៃលើកម្មវិធីសិទ្ធិ និងយុត្តិធម៌ (ប្រាជ្ញ)៖របាយការណ៍ចុងក្រោយ* (វ៉ាស៊ីនតោនឌីស៊ី៖ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃសហរដ្ឋអាមេរិក (ទ.អ.អ.ស.អ) ខែមករាឆ្នាំ២០០៨។ ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល*របាយការណ៍ដូចគ្នាស្តីពីកម្ពុជា*ឆ្នាំ២០០៩ (ភ្នំពេញ៖ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាលខែមេសាឆ្នាំ២០០៩)។

- សិទ្ធិមានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ក្នុងការការពារក្តី
- សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ
- សិទ្ធិទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលំអៀង
- សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាក្សី)
- សិទ្ធិទទួលដឹងឮភស្តុតាងរបស់ភាគីម្ខាងទៀត
- សិទ្ធិមិនឆ្លើយដាក់បន្ទុកខ្លួនឯង
- ការហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (ត្រូវបានជំនុំជម្រះសម្រាប់បទល្មើសដែលមិនត្រូវបានចាត់ទុកថាជាបទល្មើសក្នុងពេលប្រព្រឹត្ត) និង
- សិទ្ធិជនជាប់ចោទជាអនីតិជន

## រចនាសម្ព័ន្ធ

ដើម្បីឲ្យការកត់ត្រាទិន្នន័យពាក់ព័ន្ធនឹងការជំនុំជម្រះឲ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ ម.ស.ម.ក បានបង្កើតតារាងសង្កេតការណ៍សវនាការ (តារាងសង្កេតការណ៍) សម្រាប់ឲ្យមន្ត្រីសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ប្រើប្រាស់ក្នុងសវនាការ (មន្ត្រីសង្កេតការណ៍) (ឧបសម្ព័ន្ធទី១)។ តារាងសង្កេតការណ៍នេះត្រូវបានបង្កើតស្របតាមបរិបទសម្រាប់គម្រោង និងមានសំណួរប្រមាណជាង ៧០ ដែលចម្លើយឆ្លើយតបទៅនឹងសំណួរទាំងនេះ នឹងបង្ហាញថា តើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពដែរឬទេ។ សំណួរភាគច្រើនមានចម្លើយ៤ ប្រភេទ ដូចជា "មាន" "គ្មាន" "មិនពាក់ព័ន្ធ" និង "មិនដឹង"។ ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធមួយទំព័រភ្ជាប់នឹងតារាងសង្កេតការណ៍នេះ សម្រាប់ប្រើក្នុងសវនាការដែលពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជនផងដែរ (ឧបសម្ព័ន្ធទី២) ។ តាមរយៈតារាងសង្កេតការណ៍មន្ត្រីសង្កេតការណ៍ធ្វើការសង្កេតការណ៍ គោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅក្នុងសវនាការទាំងមូល និងធ្វើការសង្កេតលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទម្នាក់ៗ។ ទិន្នន័យដែលបានផ្តល់នៅក្នុងតារាងនៅក្នុងផ្នែកទី៣ បង្ហាញពីការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសវនាការទាំងមូល ដើម្បីធ្វើការប្រៀបធៀបជាមួយនឹងអំឡុងពេលរបាយការណ៍មុនៗ។ ហេតុដូច្នេះហើយឧទាហរណ៍សំណួរថា "តើជនជាប់ចោទបានទទួលជំនួយពីមេធាវីដែរឬទេ?" នៅពេលដែលមានជនជាប់ចោទច្រើននាក់មានវត្តមានក្នុងសវនាការតែមួយនោះមន្ត្រីសង្កេតការណ៍នឹងឆ្លើយថា "ទេ" ប្រសិនបើគ្មានជនជាប់ចោទណាម្នាក់បានទទួលជំនួយពីមេធាវី។ តាំងពីអំឡុងពេលរបាយការណ៍ទី៣ មន្ត្រីសង្កេតសវនាការឆ្លើយនឹងសំណួរនេះសម្រាប់សវនាការទាំងមូល ដើម្បីឲ្យអាចធ្វើការប្រៀបធៀបជាមួយទិន្នន័យប្រមូលបានក្នុងអំឡុងពេលរបាយការណ៍មុនៗហើយក៏ធ្វើការសង្កេតដែរថា តើជនជាប់ចោទម្នាក់ៗបានទទួលជំនួយពីមេធាវីដែរឬទេ។ ទិន្នន័យនេះនឹងត្រូវបានបង្ហាញនៅក្នុងការវិភាគ និងការពន្យល់ទិន្នន័យក្នុងផ្នែកទី៣។

ដោយសារតែតារាងសង្កេតការណ៍សវនាការត្រូវបានកែប្រែឲ្យខ្លី ម.ស.ម.ក បានចងក្រងសេចក្តីណែនាំមួយងាយស្រួលយល់ (សេចក្តីណែនាំស្តីពីតារាងសង្កេតការណ៍សវនាការ) (ឧបសម្ព័ន្ធទី២) ដើម្បីធានាឲ្យមានការបកស្រាយរួមមួយសម្រាប់សំណួរនីមួយៗនៅក្នុងតារាង និងពន្យល់អំពីមូលដ្ឋានច្បាប់ និងគោលបំណងនៃសំណួរនីមួយៗ។ សេចក្តីណែនាំស្តីពីតារាងសង្កេតការណ៍សវនាការមានសារៈសំខាន់ក្នុងការពន្យល់អត្ថន័យសំណួរនីមួយៗ និងធានាឲ្យមន្ត្រីសង្កេតការណ៍សវនាការទាំងបច្ចុប្បន្ន និងអនាគតយល់ដឹងស្របគ្នាអំពីសំណួរនីមួយៗ។ ឧបករណ៍មួយផ្សេងទៀតដែលសង្ខេបអំពីច្បាប់ជាតិ និងច្បាប់អន្តរជាតិដែល

ជាមូលដ្ឋាននៃសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍សវនាការនោះ គឺបញ្ជីច្បាប់ (ឧបសម្ព័ន្ធទី៣) ត្រូវបានផ្តល់ឲ្យមន្ត្រីសង្កេតការណ៍សវនាការ ដើម្បីបង្កការងាយស្រួលក្នុងការយោងច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានជ្រើសរើសសម្រាប់ការសង្កេតការណ៍សវនាការ។

ម.ស.ម.ក មានឆន្ទៈអនុវត្តការសង្កេតការណ៍សវនាការដោយគោរពតាមគោលការណ៍អន្តរជាតិជាមូលដ្ឋាន[13] និងបានបង្កើតនូវក្រមសីលធម៌សម្រាប់មន្ត្រីសង្កេតការណ៍ ដែលដាក់ចេញនូវកាតព្វកិច្ចមិនជ្រៀតជ្រែក ភាពមិនលំអៀង និងការរក្សាការសម្ងាត់ ដែលមន្ត្រីសង្កេតការណ៍ត្រូវគោរពតាម (ក្រមសីលធម៌) (ឧបសម្ព័ន្ធទី៤)។

## បុគ្គលិកនិងការបណ្តុះបណ្តាល

បច្ចុប្បន្ននេះ ក្រុមការងារអនុវត្តគម្រោងមានមន្ត្រីសង្កេតការណ៍ចំនួន ៣ នាក់ ដែលពោរពេញទៅដោយបទពិសោធន៍ ចំណេះដឹង និងជំនាញផ្នែកច្បាប់។ អ្នកផ្តល់ប្រឹក្សាទាំងជាតិ និងអន្តរជាតិផ្តល់ការគាំទ្រដល់ក្រុមមន្ត្រីសង្កេតការណ៍។ តាមរយៈកំណត់សម្គាល់ខាងលើ មន្ត្រីសង្កេតការណ៍ត្រូវគោរពតាមក្រមសីលធម៌។ មុនពេលការសង្កេតការណ៍សវនាការចាប់ផ្តើម មន្ត្រីសង្កេតការណ៍បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលយ៉ាងម៉ត់ចត់ ទាំងផ្នែកទ្រឹស្តី និងការអនុវត្ត រួមមានការបណ្តុះបណ្តាលស្តីពី៖

- ការសង្កេតការណ៍សវនាការ និងការប្រើប្រាស់តារាងសង្កេតការណ៍
- ក្រមសីលធម៌ និងសារៈសំខាន់នៃភាពមិនលំអៀង ការមិនជ្រៀតជ្រែក ការរក្សាការសម្ងាត់ និងលក្ខណៈជាវិជ្ជាជីវៈ និង
- បទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ក្នុងច្បាប់ជាតិ និងអន្តរជាតិ។

មន្ត្រីសង្កេតការណ៍សវនាការ សង្កេតសវនាការរឿងក្តីព្រហ្មទណ្ឌក្នុងតុលាការស្ទើរតែរាល់ថ្ងៃ ហេតុដូច្នេះទទួលបានចំណេះដឹងជាក់ច្បាស់អំពីនីតិវិធីព្រហ្មទណ្ឌ ដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា។ មន្ត្រីសង្កេតការណ៍សវនាការបានបង្កើតទំនាក់ទំនងល្អ និងវិជ្ជមានជាមួយបុគ្គលិករបស់តុលាការដែលបានសង្កេត នេះគឺស្របតាមគោលបំណងរបស់គម្រោង ដែលបំពេញការងារក្នុងភាពដៃគូជាមួយតុលាការ និងអ្នកពាក់ព័ន្ធវិស័យយុត្តិធម៌ដទៃទៀត ដើម្បីលើកកម្ពស់ការទទួលស្គាល់ និងអនុវត្តបទប្បញ្ញត្តិនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## នីតិវិធីសង្កេតការណ៍សវនាការ

ស្របតាមគោលបំណងនៃគម្រោង មន្ត្រីសង្កេតការណ៍ចំនួន២នាក់ ត្រូវបានចាត់ឲ្យសង្កេតសវនាការនៅតុលាការរាជធានីភ្នំពេញ និង ១នាក់ទៀតសង្កេតសវនាការនៅតុលាការខេត្តកណ្តាល។ ការធ្វើរបៀបនេះអាចឲ្យមន្ត្រីសង្កេតការណ៍ស្គាល់ច្បាស់ពីតុលាការដែលពួកគេត្រូវធ្វើការជាមួយ និងអាចឲ្យពួកគេបង្កើត

---

[13]សូមមើល៖អង្គការលើកលែងទោសអន្តរជាតិ - *សៀវភៅស្តីពីការជំនុំជម្រះដោយយុត្តិធម៌* (រាជធានីឡុង៍៖បោះពុម្ពផ្សាយដោយអង្គការលើកលែងទោសអន្តរជាតិឆ្នាំ១៩៩៨) Al Index POL 30/02/98។ដើលែនណាភីជីកនិងវ៉ានីសាលេសនី - *អ្វីទៅជាការជំនុំជម្រះដោយយុត្តិធម៌៖សេចក្តីណែនាំជាមូលដ្ឋានស្តីពីបទដ្ឋាន និងការអនុវត្តច្បាប់* (ញូវយ៉ក៖គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្សឆ្នាំ២០០០)។អង្គការសន្តិសុខនិងសហប្រតិបត្តិការអឺរ៉ុប(OSCE) /ការិយាល័យវិទ្យាស្ថានលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស (ODIHR)- *សង្កេតការណ៍សវនាការ៖សៀវភៅមគ្គុទេសក៏សម្រាប់អ្នកអនុវត្ត* (ប៉ូឡូញ៖OSCE/ ODIHR ឆ្នាំ២០០៨)។បាបារ៉ាអូលីវើរ៉ានិងលីនដាបេសារាទីម៉ូរ៉ាអេជ - *សៀវភៅសង្កេតការណ៍សវនាការនៃគណៈកម្មការអ្នកច្បាប់អន្តរជាតិ*(ហ្សឺណែវ៖គណៈកម្មការអ្នកច្បាប់អន្តរជាតិឆ្នាំ២០០២)។

ទំនាក់ទំនងជាមួយចៅក្រម និងបុគ្គលិកនៅក្នុងតុលាការនោះ។ មន្ត្រីសង្កេតការណ៍របស់ ម.ស.ម.ក ធ្វើការសង្កេតការណ៍សវនាការទៅតាមកាលវិភាគរបស់តុលាការ ដើម្បីបង្កើតទិន្នន័យ និងគំរូសុក្រិតនៃសវនាការ។

ចំពោះសវនាការនីមួយៗដែលបានសង្កេត ទិន្នន័យត្រូវបានកត់ត្រាដោយផ្ទាល់នៅលើតារាងសង្កេតការណ៍សវនាការ។ យើងកំណត់ការយកព័ត៌មានត្រឹមតែនៅក្នុងសវនាការប៉ុណ្ណោះ ដូច្នេះគ្មានការសម្ភាសន៍ ឬកិច្ចសន្ទនាបន្ថែមនោះទេ លើកលែងតែកិច្ចខិតខំប្រឹងប្រែងក្នុងការកត់ត្រាសាលក្រមដែលប្រកាសបន្ទាប់ពីសវនាការបានបញ្ចប់។

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យ

ទិន្នន័យនៃសវនាការនីមួយៗ ត្រូវបានស្រង់ចេញពីតារាងសង្កេតការណ៍សវនាការហើយបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ ម.ស.ម.ក (ប្រព័ន្ធគ្រប់គ្រងទិន្នន័យ)។[14] ប្រព័ន្ធគ្រប់គ្រងទិន្នន័យឆ្លុះបញ្ចាំងសំណួរនៅក្នុងតារាងសង្កេតការណ៍សវនាការ និងត្រូវបានបង្កើតឡើងដោយប្រើប្រព័ន្ធ Microsoft Visual Basic។ បន្ថែមទៅលើតួនាទីរក្សាទុកទិន្នន័យដែលបានមកពីតារាងសង្កេតការណ៍ ប្រព័ន្ធគ្រប់គ្រងទិន្នន័យត្រូវបានបង្កើតឡើងដើម្បីវិភាគទិន្នន័យដែលបានរក្សាទុក ឧទាហរណ៍ប្រព័ន្ធនេះនឹងបង្ហាញសញ្ញាពីការឃុំខ្លួនបណ្ដោះអាសន្នលើសថិរវេលាដែលបញ្ញត្តិដោយច្បាប់។ ស្របពេលដែលគម្រោងដំណើរការ ប្រព័ន្ធគ្រប់គ្រងទិន្នន័យនឹងត្រូវអភិវឌ្ឍបន្ថែមទៀត។ បន្ទាប់ពីនោះប្រព័ន្ធគ្រប់គ្រងទិន្នន័យនឹងក្លាយជាបញ្ជីរាយទិន្នន័យដ៏ធំទូលាយ និងជាធនធានដ៏មានតម្លៃសម្រាប់ ម.ស.ម.ក និងអង្គការដទៃទៀតដែលធ្វើការដើម្បីលើកកម្ពស់ការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា។

## ការវិភាគ និងកិច្ចពិភាក្សា

ម.ស.ម.ក វិភាគទិន្នន័យនៃសវនាការដែលត្រូវបានរក្សាទុកក្នុង ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព្រមទាំងកត់សម្គាល់នូវការវិវត្តវិជ្ជមាន និងបញ្ហាអវិជ្ជមាននានាដែលកើតមាននៅក្នុងសវនាការ។ ទិន្នន័យមានមូលដ្ឋានលើចម្លើយដែលមន្ត្រីសង្កេតការណ៍សវនាការឆ្លើយទៅនឹងសំណួរនៅក្នុងតារាងសង្កេតការណ៍។ ទិន្នន័យត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ប្រចាំឆមាស និងប្រៀបធៀបជាមួយទិន្នន័យដែលប្រមូលបាននៅក្នុងអំឡុងពេលរបាយការណ៍មុនៗ ដើម្បីកំណត់នូវភាពប្រែប្រួលនៃការអនុវត្តរបស់តុលាការ។ របាយការណ៍ប្រចាំឆមាសនីមួយៗ បង្ហាញនូវការវិភាគស៊ីជម្រៅនូវផ្នែកតូចៗ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលបានសង្កេត។ ការវិភាគនេះមានគោលបំណងផ្ដល់លទ្ធភាពឲ្យ ម.ស.ម.ក កំណត់បាននូវភាពខ្លាំង និងភាពខ្សោយនៃការអនុវត្តរបស់តុលាការ និងផ្ដល់អនុសាសន៍សមស្របដល់តុលាការ និងអ្នកពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ដទៃទៀត ក្នុងផ្លូវមួយដែលអាចឲ្យការទទួលស្គាល់ និងការអនុវត្តបទប្បញ្ញត្តិស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសវនាការរឿងក្ដីព្រហ្មទណ្ឌ មានលក្ខណៈកាន់តែប្រសើរឡើង។

គម្រោងមានគោលបំណងផ្ដល់ទិន្នន័យត្រឹមត្រូវ ដែលជាមូលដ្ឋានជំរុញឲ្យមានការផ្លាស់ប្ដូរការអនុវត្តរបស់តុលាការ និងឈានទៅរកការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ សេចក្ដីព្រាងចុងក្រោយនៃរបាយការណ៍ប្រចាំឆមាសត្រូវបានផ្ញើជូនប្រធាននៃតុលាការដែលបានសង្កេត ដើម្បីទទួលបានយោបល់ និងអនុសាសន៍ នៅមុនពេលចេញផ្សាយ។ នៅពេលចេញផ្សាយ ម.ស.ម.ក ចែកចាយរបាយការណ៍នេះទៅឲ្យដៃគូពាក់ព័ន្ធ ព្រមទាំងស្នើសុំជួបប្រជុំ ឬធ្វើបទបង្ហាញ ដើម្បីផ្ដល់ការពន្យល់បន្ថែមទៅលើទិន្នន័យ ការវិភាគ និងអនុសាសន៍។ បុគ្គលិកគម្រោងក៏បានស្នើសុំជួបប្រជុំផងដែរ ជាមួយតំណាងតុលាការដែលបាន

[14] គេនឹងអាចទស្សនាប្រព័ន្ធគ្រប់គ្រងទិន្នន័យបាននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា៖ www.cchrcambodia.org។

សង្កេត ព្រមទាំងអង្គភាព អង្គការ និងស្ថាប័នពាក់ព័ន្ធវិស័យយុត្តិធម៌ដទៃទៀត ដែលជាប់ទាក់ទងនឹងអនុសាសន៍នៅក្នុងរបាយការណ៍។ កិច្ចប្រជុំនេះជាឱកាសមួយសម្រាប់ផ្លាស់ប្តូរគំនិតយោបល់ និងនាំឲ្យមានការយល់ច្បាស់អំពីការលំបាកដែលប្រឈមមុខដោយអ្នកធ្វើការដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌។ កិច្ចប្រជុំពិភាក្សាមានគោលបំណងជំរុញឲ្យមានការអនុវត្តអនុសាសន៍ ដែលមាននៅក្នុងរបាយការណ៍ ឬវិធានការណ៍ដទៃទៀត ដែលអាចដោះស្រាយនូវការព្រួយបារម្ភដែលនៅពីក្រោយអនុសាសន៍ទាំងនេះផងដែរ។

បន្ទាប់ពីចេញផ្សាយរបាយការណ៍ប្រចាំឆមាសទី៣ ម.ស.ម.ក បានស្នើសុំជួបពិភាក្សាជាមួយអង្គការ និងស្ថាប័នដូចខាងក្រោម៖

- តុលាការរាជធានីភ្នំពេញ
- តុលាការខេត្តកណ្តាល
- តុលាការខេត្តបាត់ដំបង
- តុលាការខេត្តបន្ទាយមានជ័យ
- តុលាការខេត្តរតនគិរី
- ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- សាលាឧទ្ធរណ៍
- ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
- អង្គការជំនួយផ្នែកច្បាប់កម្ពុជា
- ក្រុមមេធាវីគ្មានព្រំដែន
- គណៈមេធាវី
- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- នាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ
- មណ្ឌលអប់រំទីពីរ ព្រៃស "ម២"

លទ្ធផលនៃកិច្ចពិភាក្សាទាំងនេះ និងកិច្ចពិភាក្សាក្រោយពីការបោះផ្សាយនូវរបាយការណ៍ប្រចាំឆមាសលើកទី១ និងទី២ត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ ដើម្បីជួយពន្យល់អំពីបំរែបំរួលទិន្នន័យ និងដើម្បីផ្តល់ជាអនុសាសន៍។ ម.ស.ម.ក សូមធ្វើការវាយតម្លៃខ្ពស់ចំពោះកិច្ចពិភាក្សាជាវិជ្ជមាន និងមានប្រយោជន៍ជាមួយអ្នកពាក់ព័ន្ធតាំងពីចាប់ផ្តើមរហូតដល់ពេលនេះ និងការសហការណ៍ និងភាពជាដៃគូដែលអ្នកពាក់ព័ន្ធបានផ្តល់ចំពោះគម្រោងនេះជាទូទៅ។

# ៣. ទិន្នន័យនិងការវិភាគ

ក្នុងអំឡុងពេលរបាយការណ៍ទី៤ សវនាការដែលបានសង្កេតនៅតុលាការរាជធានីភ្នំពេញ និង តុលាការខេត្តកណ្តាល មានចំនួន៣៩៨ និងមានជនជាប់ចោទចំនួន ៦៨៨។ ផ្នែកនេះបង្ហាញពីទិន្នន័យ "ដើម" ដែលបានកត់ត្រាដោយមន្ត្រីសង្កេតការណ៍ដោយប្រើប្រាស់តារាងសង្កេតការណ៍ ដែលផ្អែកលើសិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងសវនាការនីមួយៗដែលបានសង្កេត។ ទិន្នន័យដែលបានមកពីអំឡុងរបាយការណ៍ទី៤ ត្រូវបានបង្ហាញរួមជាមួយទិន្នន័យដែលបានមកពីអំឡុងរបាយការណ៍ទី១ ទី២ និងទី៣ ក្នុងគោលបំណងធ្វើការប្រៀបធៀប និងវិភាគការប្រែប្រួលនៃការអនុវត្តក្នុងតុលាការ។ ទិន្នន័យដែលបង្ហាញក្នុងតារាងខាងក្រោមសម្រាប់អំឡុងរបាយការណ៍ទី៣ ជាទិន្នន័យសម្រាប់សវនាការទាំងមូល។ នៅក្នុងករណីដែលមន្ត្រីសង្កេតការណ៍ធ្វើការសង្កេតលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់ជនជាប់ចោទនីមួយៗ ក្នុងអំឡុងរបាយការណ៍ទី៤ ទិន្នន័យនេះត្រូវបានកំណត់ដាច់ដោយឡែកនៅក្នុងផ្នែកនេះ និង/ឬ ផ្នែកវិភាគទិន្នន័យ។

តួលេខទី១៖សវនាការដែលបានសង្កេតការណ៍

| **តុលាការរាជធានីភ្នំពេញ** | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំនួនសវនាការ | 142 | | 376 | | 439 | | 308 | |
| បទឧក្រិដ្ឋ | 84 | 59 | 190 | 51 | 223 | 51 | 117 | 38 |
| បទមជ្ឈិម | 58 | 41 | 186 | 49 | 216 | 49 | 191 | 62 |
| **តុលាការខេត្តកណ្តាល** | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ចំនួនសវនាការ | 57 | | 156 | | 146 | | 90 | |
| បទឧក្រិដ្ឋ | 21 | 37 | 55 | 35 | 52 | 36 | 36 | 40 |
| បទមជ្ឈិម | 36 | 63 | 101 | 65 | 94 | 64 | 54 | 60 |

តួលេខទី១ ខាងលើបានបង្ហាញពីចំនួន និងទីតាំងនៃសវនាការព្រហ្មទណ្ឌដែលបានសង្កេតដោយមន្ត្រីសង្កេតការណ៍ក្នុងអំឡុងរបាយការណ៍ទី៣ និងចំណាត់ថ្នាក់នៃបទល្មើសក្នុងសវនាការនីមួយៗ។ មាត្រា៤៦ នៃក្រមព្រហ្មទណ្ឌ ឲ្យនិយមន័យបទឧក្រិដ្ឋ គឺជាបទល្មើសទាំងឡាយណាដែលមានទោសអប្បបរមា ជាប់ពន្ធនាគារចាប់ពី ៥ឆ្នាំឡើងទៅ។ មាត្រា៤៧ ឲ្យនិយមន័យបទមជ្ឈិម គឺជាបទល្មើសដែលត្រូវជាប់ទោសពន្ធនាគារច្រើនជាង ៦ថ្ងៃ និងតិចជាង ឬស្មើ ៥ឆ្នាំ។ ទោសលហុ គឺត្រូវបានឲ្យនិយមន័យថាជាបទល្មើសដែលការដាក់ទោសជាការពិន័យ ឬត្រូវជាប់ពន្ធនាគារតិចជាង ឬស្មើ ៦ថ្ងៃ។[15]

[15]មាត្រា៤៨នៃក្រមព្រហ្មទណ្ឌ។

## សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(១) នៃអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖** "ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀងដែលបង្កើតដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ[...]។"
- **មាត្រា៣១៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** *"សវនាការត្រូវធ្វើឡើងជាសាធារណៈ។"*

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការសម្រេចថាមានទោស ឬគ្មានទោសនៅក្នុងសវនាការជាសាធារណៈ លើកលែងតែក្នុងករណីពិសេសមួយចំនួន។[16] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈពាក់ព័ន្ធនឹងធាតុផ្សំមួយចំនួន៖ សវនាការគួរតែបើកចំហជាទូទៅសម្រាប់សាធារណជន និងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ព័ត៌មានពីទីកន្លែង និងកាលបរិច្ឆេទនៃសវនាការគួរតែប្រកាសជាសាធារណៈ និងគួរតែមានសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីធានាការចូលរួមពីសាធារណជន។[17]

### តួលេខទី២៖សិទ្ធិទទួលបានសវនាការជាសាធារណៈ

| ២(ក) តើការជូនដំណឹងនៃសវនាការត្រូវបានបិទលើក្តារខៀនព័ត៌មានជាសាធារណៈនៅខាងក្រៅបន្ទប់សវនាការដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 5 | 3 | 0 | 0 | 234 | 40 | 195 | 49 |
| គ្មាន | 194 | 97 | 532 | 100 | 351 | 60 | 203 | 51 |
| **២(ខ) តើសាធារណជនត្រូវបានរារាំង ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ?** | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 0 | 0 | 0 | 0 | 1 | 0.3 |
| គ្មាន | 199 | 100 | 532 | 100 | 585 | 100 | 397 | 99.7 |

---

[16] មាត្រា៣១៦នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា តុលាការអាចបង្គាប់ឲ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់ប្រសិនបើតុលាការយល់ឃើញថាសវនាការជាសាធារណៈអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សង្គម ឬដល់ទំនៀមទម្លាប់ប៉ុន្តែត្រូវតែមានការពន្យល់ជាលាយលក្ខណ៍អក្សរនៃការបង្គាប់បែបនោះរួមជាមួយនឹងសាលក្រមលើអង្គសេចក្តី។មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចែងថាសារព័ត៌មាន និងសាធារណជនគួរតែមិនអនុញ្ញាតឲ្យចូលរួមក្នុងសវនាការទាំងអស់ក្នុងករណីដែល "ទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិនៅក្នុងសង្គមប្រជាធិបតេយ្យ" ដែលសាធារណភាពអាចធ្វើឲ្យខូចខាតដល់ប្រយោជន៍របស់ភាពយុត្តិធម៌ ឬនៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ។

[17] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ កថាខណ្ឌ ៦.២ នៃសេចក្តីជូនដំណឹងលេខ ២១៥/១៩៨៦ វ៉ាន់ម៉ាស តទល់នឹងហូឡង់ ដល់ស្រង់នៅក្នុងលេខយោងទី១២។

ទិន្នន័យសំណួរ២(ក) បង្ហាញពីការវិវឌ្ឍន៍គួរឲ្យកត់សម្គាល់ទាក់ទងទៅនឹងការជូនដំណឹងអំពីសវនាការជាសាធារណៈដែលនៅក្នុងសវនាការចំនួនជិតពាក់កណ្តាលនៃសវនាការដែលបានសង្កេតទាំងអស់នៅក្នុងអំឡុងពេលរបាយការណ៍ទី៤ មានការជូនដំណឹងជាសាធារណៈអំពីពេលវេលា និងទីកន្លែងសវនាការ។ មន្ត្រីសង្កេតការណ៍បង្ហាញថា នៅតុលាការខេត្តកណ្តាលមិនមានការជូនដំណឹងអំពីសវនាការនោះទេ។ ប្រធានតុលាការខេត្តកណ្តាល បានលើកយកហេតុផលចំនួនពីរយកមកបកស្រាយទៅលើបញ្ហានេះ។ ទីមួយ ព័ត៌មានទាក់ទងនឹងសវនាការត្រូវបានផ្តល់ដល់ ជនជាប់ចោទ និងភាគីពាក់ព័ន្ធតាមរយៈដីការរួចហើយ។ ទីពីរ មិនមានការកំណត់ពីច្បាប់តម្រូវឲ្យជូនដំណឹងជាសាធារណៈអំពីសវនាការឡើយ។ ដូច្នេះការវិវឌ្ឍវិជ្ជមាននៃសិទ្ធិនេះនៅក្នុងអំឡុងរបាយការណ៍ទាំងពីរចុងក្រោយនេះជាគុណសម្បត្តិរបស់តុលាការរាជធានីភ្នំពេញតែមួយគត់។

ចំពោះសំណួរ២(ខ) ទិន្នន័យសម្រាប់សំណួរនេះត្រូវបកស្រាយជាមួយនឹងលក្ខខ័ណ្ឌថា នៅពេលចាប់ផ្តើមសវនាការ មន្ត្រីសង្កេតការណ៍ស្ថិតនៅក្នុងបន្ទប់សវនាការ ដូច្នេះលទ្ធភាពនៃការសង្កេតស្ថានភាពនៅខាងក្រៅបន្ទប់សវនាការគឺមានកម្រិត។ ប៉ុន្តែទោះបីជាមានកម្រិតបែបនេះក៏ដោយ ក៏មន្ត្រីសង្កេតការណ៍ត្រូវធ្វើការសង្កេតជាទូទៅថាតុលាការរាជធានីភ្នំពេញ និងតុលាការខេត្តកណ្តាលប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់ក្នុងការបើកសវនាការដោយចំហនិងសាធារណៈ។ ជាលើកដំបូងចាប់តាំងពីការសង្កេតការណ៍សវនាការបានចាប់ផ្តើមមន្ត្រីសង្កេតការណ៍សវនាការបានកត់ត្រាករណីមួយដែលអ្នកចូលរួមសវនាការម្នាក់ត្រូវបានបណ្តេញចេញពីសវនាការ។ ជននោះគឺជាសាច់ញាតិរបស់ជនជាប់ចោទត្រូវបានបណ្តេញចេញពីសវនាការដោយសារទូរស័ព្ទរបស់គាត់រោទិ៍ឮខ្លាំង ទោះជាគាត់ត្រូវបានព្រមានឲ្យបិទទូរស័ព្ទក៏ដោយ។ លើសពីនេះទៅទៀតគាត់បានឆ្លើយនឹងសំណួររបស់ចៅក្រមជំនួសជនជាប់ចោទទៀតផង។ ដោយសារតែសកម្មភាពរបស់គាត់នាំឲ្យមានការរំខានដល់នីតិវិធីសវនាការ ការបណ្តេញគាត់ចេញពីបន្ទប់សវនាការ គឺជាការរក្សានូវភាពសុក្រិតរបស់សវនាការ។

## សិទ្ធិមានសេរីភាពនិងទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា៣៨នៃរដ្ឋធម្មនុញ្ញ៖** "ការចាប់ខ្លួនការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។"
- **មាត្រា១៤(៣)(គ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖** "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ៖ ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួស។
- **មាត្រា២០៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងលក្ខខ័ណ្ឌដែលបានចែងក្នុងផ្នែកនេះ។"
- **មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាជាការចាំបាច់៖

  ១. ដើម្បីបញ្ចប់បទល្មើស ឬបង្ការកុំឲ្យកើតឡើងជាថ្មី។

  ២. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

  ៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ។

៦.ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។

➢ **មាត្រា ២០៨-២១៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ថិរវេលាកំណត់នៃការឃុំខ្លួនបណ្តោះអាសន្ន"

សច្ចធារណ៍ដែលប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន គឺជាធាតុផ្សំចម្បងនៃការសន្មតជាមុនថាគ្មានទោសរហូតដល់ការរកឃើញនូវពិរុទ្ធភាពតាមច្បាប់។

## តួលេខទី៣៖ការឃុំខ្លួនបណ្តោះអាសន្ន

| ១៣(ឃ) តើមានការឃុំខ្លួនបណ្តោះអាសន្នដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 176 | 88 | 446 | 98 | 465 | 80 | 329 | 83 |
| គ្មាន | 7 | 4 | 8 | 1.5 | 114 | 19 | 66 | 16 |
| មិនដឹង | 16 | 8 | 2 | 0.5 | 6 | 1 | 3 | 1 |

ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្នដ៏ច្រើនលើសលុបទិន្នន័យសម្រាប់សំណួរ១៣(ឃ) បង្ហាញថាភាគរយសរុបនៃករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នបានកើនឡើងបន្តិចបន្តួចពី៨០% នៅក្នុងអំឡុងរបាយការណ៍ទី៣ដល់៨៣% នៅក្នុងអំឡុងរបាយការណ៍ទី៤ (ទោះជាមានការធ្លាក់ចុះតាំងពីអំឡុងពេលរបាយការណ៍ទី១និងទី២ក៏ដោយ)។ នៅពេលក្រឡេកមើលជនជាប់ចោទម្នាក់ៗវិញ៦៤% នៃជនទាំងនោះត្រូវបានឃុំខ្លួនបណ្តោះអាសន្ន គឺដូចគ្នាទៅនឹងទិន្នន័យប្រមូលបាននៅក្នុងអំឡុងរបាយការណ៍ទី៣។ អត្រានៃការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទពីបទមជ្ឈិមនៅតែមានកម្រិតខ្ពស់។ ខណៈពេលដែលទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍ទី៣ បង្ហាញថា៨៦% នៃករណីឃុំខ្លួនបណ្តោះអាសន្ន គឺទៅលើជនជាប់ចោទបទមជ្ឈិម ទិន្នន័យនេះបានកើនឡើងដល់៩៧,៤% នៅក្នុងអំឡុងពេលរបាយការណ៍ទី៤។ រីឯ៩២,៦% នៃជនជាប់ចោទពីបទឧក្រិដ្ឋត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ទិន្នន័យបានបង្ហាញថាមានការងារជាច្រើនដែលត្រូវបំពេញ ដើម្បីឲ្យយុត្តាធិការទទួលស្គាល់ហេតុផលដែលនាំឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន និងថិរវេលារបស់ការឃុំខ្លួននេះ។

ក្នុងកិច្ចពិភាក្សាជាមួយ ម.ស.ម.ក តុលាការរាជធានីភ្នំពេញបានធ្វើការកត់សម្គាល់ថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាការសំខាន់សម្រាប់សន្តិសុខ។[18] ចៅក្រមដែលម.ស.ម.កបានជួបក៏បានលើកឡើងផងដែរថាអត្រានៃការឃុំខ្លួនបណ្តោះអាសន្នមានការធ្លាក់ចុះដោយហេតុថាប្រទេសមានសន្តិសុខល្អហើយប្រជាជនយល់ដឹងពីច្បាប់ច្រើនហេតុដូច្នេះហើយទើបមានការឃុំខ្លួនតិចជាមុន។ ម.ស.ម.ក បានធ្វើការពិភាក្សាជាមួយប្រធានតុលាការខេត្តកណ្តាល ហើយលោកបានទទួលស្គាល់ថាការឃុំខ្លួនបណ្តោះអាសន្នគឺជាបញ្ហាធ្ងន់ធ្ងរ ប៉ុន្តែលោកបានពោលថា តុលាការខេត្តកណ្តាលមិនមានលទ្ធភាពក្នុងការជំនួសការឃុំខ្លួនបណ្តោះ

[18]កិច្ចពិភាក្សាជាមួយលោកចៅក្រមកែសាខនចៅក្រមកៅវ៉ាន់ឌីចៅក្រមចាំងស៊ីណាតនិងលោកព្រះរាជអាជ្ញាហ៊ីងប៊ុនធានៅតុលាការរាជធានីភ្នំពេញ នៅថ្ងៃទី៣០ខែមិថុនាឆ្នាំ២០១១។

អាសន្នដោយការដាក់ឲ្យត្រួតពិនិត្យតាមផ្លូវតុលាការឡើយ។ ខណៈដែលរបាយការណ៍បង្ហាញថាអត្រានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងសវនាការដែលបានសង្កេតមានការថយចុះបន្តិចបន្តួច បើក្រឡេកមើលទៅលើចំនួនភាគរយនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជនជាប់ចោទម្នាក់ៗវិញ នៅតែជាចំនួនមួយខ្ពស់ ជាពិសេសជនដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម។ ជាការសំខាន់ណាស់ដែលចៅក្រមត្រូវតែអនុវត្តច្បាប់ដោយប្រុងប្រយ័ត្ន ដូចនេះការឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវបានប្រើតែក្នុងស្ថានភាពដែលកំណត់ដោយច្បាប់ហើយដែលគួរតែជាករណីលើកលែង។ មាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញាត្តិនូវហេតុផលមួយចំនួន ដែលអាចនាំឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន។ ក៏ប៉ុន្តែហេតុផលទាំងនេះគួរតែត្រូវបានថ្លឹងថ្លែងប្រៀបធៀបជាមួយនឹងជម្រើសផ្សេងពីការឃុំខ្លួនបណ្តោះអាសន្ន ដែលបានបញ្ញាត្តិដូចជា ការកំណត់នូវការរឹតត្បិតឲ្យបានច្បាស់ចំពោះជនជាប់ចោទ ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យរបស់តុលាការ ដែលបានបញ្ញាត្តិក្នុងមាត្រា២២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជម្រើសផ្សេងទៀតដូចជាការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យរបស់តុលាការគឺជាវិធានការណ៍ដែលមិនសូវខ្លាំងក្លា បើប្រៀបធៀបនឹងការឃុំខ្លួនបណ្តោះអាសន្ន ហើយអាចមានប្រសិទ្ធភាពស្មើគ្នា ក្នុងការធានាបាននូវលទ្ធផលដូចគ្នាទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន ដូចជាការធានានូវវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការ ការរារាំងមិនឲ្យប្រព្រឹត្តបទល្មើសតទៅទៀត និងការធ្វើទុក្ខបុកម្នេញទៅលើសាក្សី។

នៅក្នុងសវនាការដែលបានសង្កេតមួយចំនួន មានការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការហួសថិរវេលាដែលបានកំណត់ដោយច្បាប់។ តួលេខទី៤ខាងក្រោមបង្ហាញព័ត៌មានលម្អិតអំពីសវនាការចំនួន ៤ ដែលបានសង្កេតក្នុងអំឡុងរបាយការណ៍ទី៤ ដែលមានជនជាប់ចោទចំនួន៥នាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្នលើសថិរវេលាដែលកំណត់ដោយច្បាប់។

## តួលេខទី៤ៈការឃុំខ្លួនបណ្តោះអាសន្នលើសថិរវេលាកំណត់ដោយច្បាប់

| អំឡុងពេលរបាយការណ៍ទី៤ | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | តុលាការ និង កាលបរិច្ឆេទ សង្កេតការណ៍ សវនាការ | ចំនួន ថ្ងៃអតិបរមា នៃការឃុំខ្លួន បណ្តោះ អាសន្ន[19] | ចំនួនថ្ងៃនៃ ការឃុំខ្លួន បណ្តោះ អាសន្ន | ចំនួនថ្ងៃ ឃុំខ្លួនប ណ្តោះអាស ន្នលើស | ចំណាត់ថ្នាក់ នៃបទល្មើស | បទចោទប្រ កាន់ និងច្បាប់ | រយៈពេល នៃការ ជាប់ ទោស ពន្ធនាគារ |
| 1 | កណ្តាល/១២ មករា ២០១១ | 310 | 404 | 94 | មជ្ឈិម | ការបំពាន រាងកាយធ្វើ ឲ្យមានរបួស /ច្បាប់ អ៊ុនតាក់ | 17 ខែ |

[19]ថិរវេលាកំណត់នៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងតួលេខទី៤ ត្រូវបានគណនាស្របតាមមាត្រា ២០៨ និង ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងអំពីរយៈពេលអតិប្បបរមានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់បទល្មើសឧក្រិដ្ឋ និងមជ្ឈិម។ មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានអនុញ្ញាតឲ្យមានការឃុំខ្លួនបន្ថែមរយៈពេល ៤ ខែ នៅមុនពេលសវនាការ និងក្រោយពីបញ្ចប់ការស៊ើបសួរ។ រយៈពេលបន្ថែមនេះក៏ត្រូវបានយកមកគិតផងដែរ នៅក្នុងការគណនាដែលបង្ហាញនៅក្នុងតារាងក្រោមចំណងជើងថា "*ចំនួនថ្ងៃអតិប្បបរមានៃការឃុំខ្លួនបណ្តោះអាសន្ន*" ខាងលើ។ ថិរវេលាអប្បបរមានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់បទល្មើសឧក្រិដ្ឋ គឺ ២២ ខែ (ឬស្មើនឹង ៦៨២ ថ្ងៃ)។ ថិរវេលាអប្បបរមានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់បទល្មើសឧក្រិដ្ឋ គឺ ១០ ខែ (ឬស្មើនឹង ៣១០ ថ្ងៃ)។

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2 | កណ្ដាល/១៧ កុម្ភៈ ២០១១ | 310 | 350 | 40 | មជ្ឈិម | លួច/ច្បាប់អ៊ុនតាក់ | 13ខែ |
| 3 | កណ្ដាល/២១ មីនា ២០១១ | 310 | 342 | 32 | មជ្ឈិម | លួច/ច្បាប់អ៊ុនតាក់ | 18ខែ |
| 4 | កណ្ដាល/២៩ មិថុនា ២០១១ | 310 | 323 | 13 | មជ្ឈិម | ប្រើប្រាស់គ្រឿងញៀនខុសច្បាប់ | 6ខែ |

នៅក្នុងតារាងតួលេខទី៤ នេះការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានចាត់ទុកថាចាប់ផ្ដើមនៅថ្ងៃឃុំខ្លួន និងបញ្ចប់នៅថ្ងៃជំនុំជម្រះ ឬនៅថ្ងៃប្រកាសសាលក្រមនៅក្នុងករណីដែលសាលក្រមមិនត្រូវបានប្រកាសនៅថ្ងៃសវនាការ។

ការឃុំខ្លួនជនជាប់ចោទទាំង៥នាក់បណ្ដោះអាសន្នហួសពេលកំណត់ និងខុសច្បាប់គឺច្បាស់ណាស់ជាការល្មើសនឹងមាត្រា៩(៣)នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលតម្រូវឲ្យជនជាប់ចោទពីបទល្មើសណាមួយ ទទួលបានការជំនុំជម្រះដោយឥតពន្យារពេល។ លើសពីនេះការឃុំខ្លួនលើសរយៈពេលកំណត់នេះ ល្មើសទៅនឹងមាត្រា២៤៩នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តិថា ប្រសិនបើជនជាប់ចោទមិនត្រូវបាននាំខ្លួនទៅជំនុំជំម្រះក្នុងអំឡុងពេលនៃការឃុំខ្លួនបណ្ដោះអាសន្នទេនោះ *"ជនជាប់ចោទនឹងត្រូវបានដោះលែងឲ្យមានសេរីភាព"*។ បញ្ហាជាក់លាក់គឺស្ថិតនៅត្រង់ថានៅក្នុងសវនាការទាំង៤ ដែលមានការឃុំខ្លួនបណ្ដោះអាសន្នលើសរយៈពេលកំណត់ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ជាបញ្ហាដែលត្រូវបានសង្កេតឃើញ និងបន្តតាំងពីពេលចាប់ផ្ដើមសង្កេតការណ៍សវនាការនៅឆ្នាំ២០០៩។ នៅក្នុងអំឡុងពេលរបាយការណ៍ទី១មានសវនាការចំនួន៨ ដែលមានការឃុំខ្លួនបណ្ដោះអាសន្នលើសរយៈពេលកំណត់ ហើយដែលក្នុងចំណោមនោះសវនាការចំនួន៧ ទាក់ទងនឹងបទល្មើសមជ្ឈិម។ នៅក្នុងអំឡុងពេលរបាយការណ៍ទី២ មានសវនាការចំនួន១៨ ដែលមានការឃុំខ្លួនបណ្ដោះអាសន្នលើសរយៈពេលកំណត់ហើយដែលក្នុងចំណោមនោះ មានសវនាការចំនួន១៣ ទាក់ទងនឹងបទល្មើសមជ្ឈិម។ នៅក្នុងអំឡុងពេលរបាយការណ៍ទី៣សវនាការចំនួន៥ ក្នុងចំណោមសវនាការចំនួន៨ ដែលមានការឃុំខ្លួនបណ្ដោះអាសន្នលើសរយៈពេលកំណត់ទាក់ទងនឹងបទល្មើសមជ្ឈិម។

ក្នុងកិច្ចពិភាក្សាជាមួយតុលាការរាជធានីភ្នំពេញ ដែលធ្វើឡើងបន្ទាប់ពីការចេញផ្សាយរបាយការណ៍ប្រចាំឆមាសទី២ចៅក្រមបានលើកឡើងថាតុលាការបានធ្វើការដោយប្រុងប្រយ័ត្នដោយធ្វើការត្រួតពិនិត្យម្ដងទៅពីរដងក្នុងមួយខែ នូវស្ថានភាពរបស់ជនជាប់ចោទដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីធានាថាមិនមានការលើសថិរវេលាកំណត់នៃការឃុំខ្លួន។ មានការកត់សម្គាល់ឃើញថាការឃុំខ្លួនបណ្ដោះអាសន្នលើសថិរវេលាកំណត់ ភាគច្រើនបណ្ដាលមកពីមន្ត្រីពន្ធនាគារមិនបានធ្វើបច្ចុប្បន្នភាពទិន្នន័យនៅក្នុងប្រព័ន្ធ។[20] ប្រសិនបើបញ្ហានេះកើតឡើងពិតប្រាកដមែននោះ ការផ្លាស់ប្ដូរដ៏សំខាន់គឺស្ថិតនៅលើប្រព័ន្ធគ្រប់គ្រងរឿងក្ដីដែលប្រតិបត្តិដោយពន្ធនាគារ ដើម្បីធានាថាជនជាប់ចោទមិនត្រូវបានដកហូតសិទ្ធិសេរីភាពជ្រុលហួសហេតុ។

ការសង្កេតការណ៍សវនាការបានរកឃើញថា មានភាពជាប់ទាក់ទងគ្នាសំខាន់រវាងចំនួននៃជនជាប់ចោទពីបទល្មើសមជ្ឈិមដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន និងកង្វះខាតនៃមេធាវី។ ដូចដែលបានបង្ហាញ

[20]កិច្ចពិភាក្សាជាមួយចៅក្រមកែ សាខន ចៅក្រមកោ វ៉ាន់ឌី ចៅក្រមចាំង ស៊ីណាត និងព្រះរាជអជ្ញាហ៊ីង ប៊ុនជា នៅតុលាការរាជធានីភ្នំពេញនៅថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១១។

នៅក្នុងតួលេខទី៨ នៅក្នុងផ្នែកនេះជនជាប់ចោទទទួលបានជំនួយពីមេធាវីតែក្នុងសវនាការចំនួន៣៣% នៃសវនាការករណីបទមជ្ឈិមទាំងអស់ប៉ុណ្ណោះ។ នៅក្នុងកិច្ចពិភាក្សាជាមួយតុលាការរាជធានីភ្នំពេញបន្ទាប់ពីការចេញផ្សាយរបាយការណ៍ប្រចាំឆមាសទី២លោកព្រះរាជអាជ្ញាហ៊ឹង ប៊ុនជាទទួលស្គាល់ថាកង្វះខាតមេធាវីជះឥទ្ធិពលលើនីតិវិធីនៃការឃុំខ្លួន។ ការយល់ឃើញដូចគ្នានេះក៏ត្រូវបានលើកឡើងផងដែរក្នុងកិច្ចពិភាក្សាជាមួយលោកចៅក្រមហុក វ៉ាន់ធីណានៃតុលាការខេត្តកណ្ដាល។[21] ទិន្នន័យដែលបានប្រមូលពីមន្ត្រីសង្កេតការណ៍បង្ហាញថា អវត្តមាននៃមេធាវីអាចបង្កឲ្យមានភាពងាយស្រួលបាត់ដាននៃរយៈពេលដែលជនជាប់ចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។ នៅក្នុងចំណោមជនជាប់ចោទទាំងអស់ដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្នលើសថិរវេលាកំណត់នៅក្នុងអំឡុងពេលរបាយការណ៍ទី៤ មានជនជាប់ចោទតែម្នាក់ប៉ុណ្ណោះដែលទទួលបានជំនួយពីមេធាវី។

ក្រៅពីករណីពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ន ម.ស.ម.ក ក៏ព្រួយបារម្ភផងដែរចំពោះការពន្យារពេលសវនាការ។ នៅពេលពិភាក្សាជាមួយអនុប្រធានតុលាការរាជធានីភ្នំពេញ ទាក់ទងនឹងរបាយការណ៍ប្រចាំឆមាសលើកទី៤ លោកអនុប្រធានបានលើកឡើងពាក់ព័ន្ធនឹងករណីដែលតម្រូវឲ្យមានវត្តមានភាគីពាក់ព័ន្ធ (អជ្ញាធរ ឬជនរងគ្រោះ) ដូចជាបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន រំលោភសេពសន្ថវៈ ឬករណីជួញដូរមនុស្ស ដែលអវត្តមានភាគីពាក់ព័ន្ធអាចនាំឲ្យមានការពន្យារពេលសវនាការ។ អវត្តមានមេធាវីក៏អាចនាំឲ្យមានការពន្យារពេលសវនាការផងដែរ។ ទោះជាយ៉ាងណាក៏ដោយ នេះមិនមែនជាឆន្ទៈរបស់ចៅក្រមក្នុងការពន្យារពេលសវនាការនោះឡើយ ព្រោះការពន្យារពេលអាចបង្កើតនូវបញ្ហាជាច្រើនដូចជា ការតម្រូវកោះហៅភាគីពាក់ព័ន្ធឲ្យបង្ហាញខ្លួននៅតុលាការ និងក្នុងការជូនដំណឹងសារជាថ្មីទៅកាន់ភាគីពាក់ព័ន្ធនៅពេលដែលមានការផ្លាស់ប្ដូរនូវកាលវិភាគសវនាការ។ បញ្ហានេះក៏អាចនាំឲ្យមានផលប៉ះពាល់ដល់កាលវិភាគនៃសវនាការដ៏ទៃទៀតដែលត្រូវបានកំណត់រួចហើយ។

## សិទ្ធិយល់ពីបទចោទប្រកាន់

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(៣) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖**ជនជាប់ចោទ "ត្រូវបានព័ត៌មានភ្លាមៗនិងដោយលំអិតអំពីប្រភេទនិងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។"
- **មាត្រា១៤(៣)(ច) នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖** "ក្នុងការសម្រេចសេចក្ដីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួនជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ...ទទួលបានអ្នកបកប្រែភាសាដោយឥតគិតឈ្នួលបើជនជាប់ចោទមិនយល់ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ។"
- **មាត្រា៣២២នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះសាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។"
- **មាត្រា៣២៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ប្រធានសវនាការប្រាប់ជនជាប់ចោទឲ្យដឹងអំពីអំពើដែលគេចោទប្រកាន់មកលើខ្លួននិងធ្វើការសួរចម្លើយជននោះ។"
- **មាត្រា៣៣០នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ក្នុងករណីចាំបាច់ប្រធានអាចរកហៅអ្នកបកប្រែ។"

[21]កិច្ចពិភាក្សាជាមួយចៅក្រមហុកវ៉ាន់ធីណានៅតុលាការខេត្តកណ្ដាល នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១។

> ➢ **មាត្រា៣៣១នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "កាលណាសំណួរត្រូវសួរដល់ជនគថ្លង់ក្រឡាបញ្ជីត្រូវសរសេរសំណួរហើយឲ្យសាមីខ្លួនអាននិងឆ្លើយជាលាយល័ក្ខណ៍អក្សរ។ ក្នុងករណីសាមីជនមិនចេះអាន ឬមិនចេះអក្សរប្រធានសវនាការត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៣៣០ [...] ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជននោះមកបកប្រែ។"

ជនជាប់ចោទមានសិទ្ធិក្នុងការយល់ដឹងពីបទចោទប្រកាន់ដែលត្រូវបានចោទមកលើខ្លួន។

## តួលេខទី៥៖សិទ្ធិយល់ដឹងពីបទចោទប្រកាន់

| ៣(ក) តើចៅក្រមបានប្រកាសពីរឿងក្តីដែលត្រូវជំនុំជម្រះដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 196 | 98 | 493 | 93 | 556 | 95 | 385 | 97 |
| គ្មាន | 3 | 2 | 39 | 7 | 29 | 5 | 13 | 3 |
| ៣(ខ) តើចៅក្រមបានប្រាប់ពីបទចោទប្រកាន់ដែរឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 198 | 99 | 503 | 95 | 545 | 93 | 385 | 97 |
| គ្មាន | 1 | 1 | 29 | 5 | 40 | 7 | 13 | 3 |
| ៣(គ) តើចៅក្រមបានប្រាប់ពីមាត្រាច្បាប់ដែលពាក់ព័ន្ធដែរឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 169 | 85 | 313 | 59 | 299 | 51 | 277 | 70 |
| គ្មាន | 30 | 15 | 219 | 41 | 286 | 49 | 121 | 30 |
| ៣(ឃ) តើចៅក្រមបានប្រាប់ពីកាលបរិច្ឆេទប្រព្រឹត្តបទល្មើសដែរឬទេ? | | | | | | | | |
| ទិន្នន័យ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | | | | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | | | | | 417 | 71 | 325 | 82 |
| គ្មាន | | | | | 168 | 29 | 73 | 18 |
| ៣(ង) តើចៅក្រមបានប្រាប់ពីទីកន្លែងនៃការប្រព្រឹត្តបទល្មើសដែរឬទេ? | | | | | | | | |
| ទិន្នន័យ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | | | | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | | | | | 394 | 67 | 315 | 79 |
| គ្មាន | | | | | 191 | 33 | 83 | 21 |
| ៣(ច) តើចៅក្រមបានរៀបរាប់ពីឈ្មោះភាគីដែលពាក់ព័ន្ធដែរឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មាន | 196 | 98 | 443 | 83 | 512 | 88 | 360 | 90 |
| គ្មាន | 3 | 2 | 89 | 17 | 73 | 12 | 38 | 10 |
| ៣(ឆ) ប្រសិនបើត្រូវការ តើអ្នកបកប្រែត្រូវបានផ្តល់ឲ្យដែរឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 18 | 3 | 23 | 4 | 10 | 3 |
| គ្មាន | 0 | 0 | 1 | 1 | 1 | 0.2 | 0 | 0 |
| មិនពាក់ព័ន្ធ | 199 | 100 | 513 | 96 | 561 | 95.8 | 388 | 97 |
| ៣(ជ) ប្រសិនបើត្រូវការ តើជនពិការត្រូវបានគេផ្តល់ជំនួយដែរឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 0 | 0 | 2 | 1 | 1 | 0.3 |
| គ្មាន | 1 | 1 | 3 | 1 | 0 | 0 | 0 | 0 |
| មិនពាក់ព័ន្ធ | 198 | 99 | 529 | 99 | 583 | 99 | 397 | 99.7 |

ចៅក្រមបានប្រកាសរឿងក្តីដែលត្រូវជំនុំជម្រះ និងបទចោទប្រកាន់ទៅលើជនជាប់ចោទ នៅក្នុងសវនាការចំនួន ៩៧% នៅក្នុងអំឡុងរបាយការណ៍ទី៤ជាការបង្ហាញឲ្យឃើញនូវការវិវឌ្ឍប្រសើរឡើងបន្តិចបន្តួចបើប្រៀបធៀបនឹងទិន្នន័យនៅក្នុងអំឡុងរបាយការណ៍ទី២ និងទី៣ ហើយឈានជិតដល់ ១០០%នៃការគោរពសិទ្ធិនេះ។ នៅក្នុងអំឡុងរបាយការណ៍ទី២ និងទី៣ ចំនួនភាគរយនៃសវនាការដែលចៅក្រមបានប្រាប់ពីច្បាប់ដែលពាក់ព័ន្ធ មានការថយចុះគួរឲ្យកត់សំគាល់ គឺពី៥៩% មកនៅត្រឹម៥១%។ ក៏ប៉ុន្តែមន្ត្រីសង្កេតការណ៍បានសង្កេតឃើញពីភាពប្រសើរឡើងនៅក្នុងអំឡុងពេលរបាយការណ៍ទី៤ ដែលចៅក្រមបានលើកឡើងនូវច្បាប់ពាក់ព័ន្ធនៅក្នុងសវនាការចំនួន៧០%។

## ការពន្យល់ប្រាប់សិទ្ធិ

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(៣)(ក) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖**ជនជាប់ចោទ "ត្រូវបានព័ត៌មានភ្លាមៗនិងដោយលំអិតពីប្រភេទនិងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។"
- **មាត្រា៣២៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ប្រធានសវនាការប្រាប់ជនជាប់ចោទឲ្យដឹងអំពីអំពើដែលគេចោទប្រកាន់មកលើខ្លួននិងធ្វើការសួរចម្លើយជននោះ។"

ដើម្បីឲ្យបុគ្គលម្នាក់អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន បុគ្គលនោះត្រូវដឹងថាខ្លួនមានសិទ្ធិនោះ។ ម.ស.ម.ក សង្កេតមើលថា តើចៅក្រមបានប្រាប់ជនជាប់ចោទពីសិទ្ធិជាមូលដ្ឋានដែរឬទេ។ ការណ៍ដែលចៅក្រមបានប្រាប់ដល់ជនជាប់ចោទបានគ្រប់គ្រាន់អំពីសិទ្ធិជាមូលដ្ឋាន ជាបញ្ហាសំខាន់ពាក់ព័ន្ធទៅនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ហើយអាចនឹងបង្ហាញខ្លួននៅមុខតុលាការដោយគ្មានមេធាវី ដែលអាចប្រាប់

ពួកគេពីសិទ្ធិទាំងនេះបាន។ សិទ្ធិមួយចំនួនទាមទារឲ្យមានការពន្យល់ ជាពិសេសនៅពេលដែលសិទ្ធិទាំងនោះមានអត្ថន័យបច្ចេកទេសច្បាប់។ ទិន្នន័យនៃការសង្កេតការណ៍សវនាការចែកដាច់រវាងការប្រាប់ជនជាប់ចោទពីសិទ្ធិ និងការពន្យល់ពីសិទ្ធិ។

តាមរយៈការបង្ហាញរបស់តួលេខទី៦ ខាងក្រោម អត្រាទិន្នន័យសវនាការដែលចៅក្រមប្រាប់ ឬប្រាប់ និងពន្យល់ពីសិទ្ធិមូលដ្ឋានដល់ជនជាប់ចោទនៅក្នុងសវនាការ មានចំនួនខ្ពស់ជាងទិន្នន័យនៅក្នុងអំឡុងពេលរបាយការណ៍មុនៗ។ ចៅក្រមត្រូវបានសង្កេតឃើញថាបានប្រាប់ដល់ជនជាប់ចោទអំពីសិទ្ធិស្វ័យការពារ ឬសិទ្ធិទទួលបានជំនួយពីមេធាវី នៅក្នុងសវនាការដែលបានសង្កេតចំនួន៥៦%។ ទិន្នន័យនេះបង្ហាញនូវការកើនឡើង បើប្រៀបធៀបនឹងទិន្នន័យនៅក្នុងអំឡុងរបាយការណ៍ទី១ (៥៤%) និងនៅក្នុងអំឡុងពេលទី៣ (៤៧%) ប៉ុន្តែមានចំនួនទាបជាងទិន្នន័យនៅក្នុងអំឡុងរបាយការណ៍ទី២ (៦៧%)។ ជាការសំខាន់ដែលចៅក្រមនឹកឃើញអំពីសិទ្ធិបុគ្គលដែលត្រូវទទួលបានការប្រាប់ និងការពន្យល់អំពីសិទ្ធិទាំងនោះជាពិសេស សិទ្ធិទទួលបានជំនួយពីមេធាវី និងសិទ្ធិស្វ័យការពារ ដែលជាផ្នែកមួយនៃគោលការណ៍ស្មើភាព និងអនុញ្ញាតឲ្យជនជាប់ចោទអាចរៀបចំការពារក្តី។ នៅក្នុងករណីអវត្តមានមេធាវី ដែលអាចប្រាប់ជនជាប់ចោទពីសិទ្ធិរបស់ខ្លួននោះ ជនជាប់ចោទម្នាក់ៗនឹងពឹងពាក់លើចៅក្រមក្នុងការយល់ដឹងពីសិទ្ធិមូលដ្ឋានរបស់ពួកគេ។ ប្រសិនបើមិនមានព័ត៌មាន ឬការពន្យល់ទាំងនេះទេជនជាប់ចោទនឹងងាយរងគ្រោះដោយសារការរំលោភសិទ្ធិជាមូលដ្ឋានរបស់ពួកគេហើយសុក្រិតភាពនៃការជំនុំជម្រះក៏មានភាពរង្គោះរង្គើដែរ។

តួលេខទី៦៖ការពន្យល់សិទ្ធិ

| ៤(ក) តើចៅក្រមបានប្រាប់ និងពន្យល់ ជនជាប់ចោទពីសិទ្ធិទទួលបានជំនួយពីមេធាវី ឬសិទ្ធិការពារខ្លួនដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រាប់ | 108 | 54 | 354 | 67 | 276 | 47 | 223 | 56 |
| ប្រាប់ និងពន្យល់ | 75 | 38 | 51 | 9 | 138 | 24 | 81 | 20 |
| គ្មានប្រាប់ និងគ្មានពន្យល់ | 12 | 6 | 73 | 14 | 104 | 18 | 58 | 15 |
| មិនពាក់ព័ន្ធ | 4 | 2 | 54 | 10 | 67 | 11 | 36 | 9 |

| ៤(ខ) តើចៅក្រមបានប្រាប់និង ពន្យល់ជនជាប់ចោទពីសិទ្ធិនៅស្ងៀមដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រាប់ | 74 | 37 | 80 | 15 | 55 | 9 | 105 | 26 |
| ប្រាប់ និងពន្យល់ | 38 | 19 | 11 | 2 | 29 | 5 | 13 | 3 |
| គ្មានប្រាប់ និងគ្មានពន្យល់ | 83 | 42 | 387 | 73 | 434 | 75 | 244 | 62 |
| មិនពាក់ព័ន្ធ | 4 | 2 | 54 | 10 | 67 | 11 | 36 | 9 |

| ៩(គ) តើចៅក្រមបានប្រាប់និងពន្យល់ជនជាប់ចោទពីសិទ្ធិផ្លាស់ប្តូរចៅក្រមជំនុំជម្រះដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រាប់ | 121 | 61 | 281 | 53 | 189 | 32 | 117 | 29 |
| ប្រាប់ និងពន្យល់ | 63 | 32 | 39 | 7 | 149 | 26 | 77 | 19 |
| គ្មានប្រាប់ និងគ្មានពន្យល់ | 11 | 5 | 158 | 30 | 180 | 31 | 168 | 43 |
| មិនពាក់ព័ន្ធ | 4 | 2 | 54 | 10 | 67 | 11 | 36 | 9 |
| ៩(ឃ) តើចៅក្រមបានប្រាប់និងពន្យល់ជនជាប់ចោទពីសិទ្ធិមានសំណូមពរចុងក្រោយ ដែរឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រាប់ | 121 | 61 | 337 | 63 | 298 | 51 | 275 | 69 |
| ប្រាប់ និងពន្យល់ | 67 | 34 | 40 | 8 | 111 | 19 | 23 | 6 |
| គ្មានប្រាប់ និងគ្មានពន្យល់ | 7 | 3 | 101 | 19 | 109 | 19 | 64 | 16 |
| មិនពាក់ព័ន្ធ | 4 | 2 | 54 | 10 | 67 | 11 | 36 | 9 |

## សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការការពារក្តី

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(៣)(ខ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖** "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួនជនគ្រប់រូបមានសិទ្ធិ៖មានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។"
- **មាត្រា៣១៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "មុនពេលសវនាការមេធាវីអាចពិនិត្យមើលសំនុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។ មេធាវីឬលេខារបស់មេធាវីអាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឲ្យធ្វើការចម្លងលិខិតសំនុំរឿងដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅក្រោមការពិនិត្យរបស់ក្រឡាបញ្ជី។"

បុគ្គលដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ គួរតែទទួលបានពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងបទចោទប្រកាន់ប្រឆាំងនឹងខ្លួន។ ពាក្យថា "គ្រប់គ្រាន់" ត្រូវបានឲ្យនិយមន័យ (បូករួមនឹងកត្តាដទៃទៀត) ទៅតាមបទចោទប្រកាន់ និងភាពស្មុគស្មាញនៃរឿងក្តី។ ការសម្របសម្រួលដែលជនជាប់ចោទត្រូវទទួលបាននៅក្រោមសិទ្ធិនេះរួមមានការទទួលបានឯកសារ និងភស្តុតាងដទៃទៀតដែលជនជាប់ចោទត្រូវការសម្រាប់ការពាររឿងក្តីរបស់ខ្លួន ព្រមទាំងឱកាសជួប និងពិភាក្សាជាមួយមេធាវី។

## តួលេខទី៧៖ សិទ្ធិមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ក្នុងការការពារក្តី

| ១៥(ក) តើមានអ្វីមួយ ដែលបង្ហាញថាមេធាវីជនជាប់ចោទ ត្រូវបានចាត់តាំងនៅក្នុងថ្ងៃសវនាការដែរឬទេ? | | | | | | | |
|---|---|---|---|---|---|---|---|
| ទិន្នន័យ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយការណ៍នេះ | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | | 8 | 1.5 | 15 | 3 | 5 | 1 |
| គ្មាន | | 524 | 98.5 | 570 | 97 | 393 | 99 |

| ១៥(ខ) តើបញ្ហាមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីត្រូវបានលើកឡើងដោយភាគីជនជាប់ចោទដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 60 | 30 | 8 | 2 | 3 | 0.01 | 2 | 0.6 |
| គ្មាន | 139 | 70 | 524 | 98 | 582 | 99.5 | 396 | 99.4 |

សំណួរ ១៥(ក) បង្ហាញថា តើចៅក្រម ក្រឡាបញ្ជី ឬមេធាវី បាននិយាយអ្វីមួយដែលបង្ហាញថា មេធាវីជនជាប់ចោទត្រូវបានចាត់តាំងនៅថ្ងៃសវនាការដែរឬទេ។ សវនាការដែលបានសង្កេតចំនួន ១%មានការចាត់តាំងមេធាវីឲ្យជនជាប់ចោទនៅថ្ងៃសវនាការដូច្នេះ អាចនឹងគ្មានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី។

## សិទ្ធិទទួលបានជំនួយពីមេធាវី និងមានវត្តមានក្នុងសវនាការ

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា៣៨នៃរដ្ឋធម្មនុញ្ញ៖** "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"
- **មាត្រា១៤(៣)(ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖** "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិៈត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួននិងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួនក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះបើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។"
- **មាត្រា៣០០នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"
- **មាត្រា៣០១នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ជំនួយពីមេធាវីត្រូវមានជាដាច់ខាតក្នុងករណីដូចតទៅ៖ (១) ករណីបទឧក្រិដ្ឋ (២)កាលណាជនជាប់ចោទជាអនីតិជន។"

នីតិវិធីច្បាប់ និងរបៀបធ្វើការរបស់តុលាការអាចជារឿងចម្លែក និងបំភ័យជនជាប់ចោទនៃបទល្មើសណាមួយ។ ដើម្បីឲ្យការជំនុំជម្រះប្រព្រឹត្តទៅដោយយុត្តិធម៌ ជាការសំខាន់ណាស់ក្នុងការធានាថា ជនជាប់ចោទមានឱកាសពឹងពាក់អ្នកជំនាញដែលមានសមត្ថភាពពន្យល់ខ្លួនអំពីបទចោទប្រកាន់ និងសិទ្ធិនានារបស់ខ្លួន ណែនាំអំពីដំណើរការសវនាការ ព្រមទាំងតំណាង និងការពារផលប្រយោជន៍របស់ខ្លួននៅក្នុងសវនាការ។

## តួលេខទី៨៖ សិទ្ធិទទួលបានជំនួយពីមេធាវី និងមានវត្តមាននៅក្នុងសវនាការ

| ១៦(ខ) តើជនជាប់ចោទទទួលបានជំនួយពីមេធាវីដែរ ឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 135 | 68 | 312 | 59 | 392 | 67 | 238 | 60 |
| គ្មាន | 64 | 32 | 220 | 41 | 193 | 33 | 160 | 40 |
| សវនាការបទឧក្រិដ្ឋ ៖ ៧(ក)តើជនជាប់ចោទទទួលបានជំនួយពីមេធាវីដែរ ឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 100 | 95 | 238 | 97 | 275 | 100 | 153 | 100 |
| គ្មាន | 5 | 5 | 7 | 3 | 0 | 0 | 0 | 0 |
| សវនាការបទមជ្ឈិម ៖ តើជនជាប់ចោទទទួលបានជំនួយពីមេធាវីដែរ ឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 35 | 37 | 74 | 26 | 117 | 38 | 85 | 35 |
| គ្មាន | 59 | 63 | 213 | 74 | 193 | 62 | 160 | 65 |

ចំពោះសិទ្ធិទទួលបានជំនួយពីមេធាវី មន្ត្រីសង្កេតការណ៍សវនាការបានកត់ត្រាថានៅក្នុងសវនាការចំនួនត្រឹមតែ៦០%ប៉ុណ្ណោះ ដែលជនចាប់ចោទទទួលបានជំនួយពីមេធាវី។ នៅពេលក្រឡេកមើលជនជាប់ចោទម្នាក់ៗទិន្នន័យបង្ហាញថាជនជាប់ចោទចំនួនត្រឹមតែជាងពាក់កណ្តាលប៉ុណ្ណោះ នៃជនជាប់ចោទទាំងអស់ចំនួន៦៨៨នាក់ពោលគឺ៣៨១ ឬស្មើនឹង៥៥% ដែលទទួលបានជំនួយពីមេធាវី។ ទិន្នន័យនេះបង្ហាញនូវការធ្លាក់ចុះបើប្រៀបធៀបនឹងទិន្នន័យនៅក្នុងអំឡុងរបាយការណ៍ទី៣ ដែលក្នុងចំណោមជនជាប់ចោទទាំងអស់ចំនួន១.០២៩នាក់ មានជនជាប់ចោទចំនួន ៦៣៣នាក់ ឬស្មើនឹង៦២% ដែលទទួលបានជំនួយពីមេធាវី។ មន្ត្រីសង្កេតការណ៍បានកត់ត្រាថានៅក្នុងសវនាការបទឧក្រិដ្ឋទាំងអស់ដែលបានសង្កេត ជនជាប់ចោទទទួលបានជំនួយពីមេធាវី។ មន្ត្រីសង្កេតការណ៍បានកត់សម្គាល់ឃើញថា យ៉ាងយោចណាស់មានជនជាប់ចោទម្នាក់ទទួលបានជំនួយពីមេធាវី ក្នុងចំណោមសវនាការបទឧក្រិដ្ឋទាំងអស់។ ក៏ប៉ុន្តែនៅពេលក្រឡេកមើលជនជាប់ចោទម្នាក់ៗ ដែលជាប់ចោទពីបទឧក្រិដ្ឋវិញមានជនជាប់ចោទចំនួនត្រឹមតែ ៩០% ប៉ុណ្ណោះដែលទទួលបានជំនួយពីមេធាវី។ អត្រានៃជនជាប់ចោទពីបទមជ្ឈិមដែលទទួលបានជំនួយពីមេធាវីនៅតែជាចំនួនមួយទាប ជនជាប់ចោទពីបទមជ្ឈិមមានចំនួនត្រឹមតែ ៣២%ប៉ុណ្ណោះដែលទទួលបានជំនួយពីមេធាវី។ នៅខណៈដែលច្បាប់មិនទាមទារឲ្យជនជាប់ចោទពីបទមជ្ឈិមត្រូវតែទទួលបានជំនួយពី

មេធាវីលើកលែងតែជាអនីតិជន ការណ៍ដែលជនជាប់ចោទទាំងនោះចំនួនត្រឹមតែមួយភាគបីបានទទួលជំនួយពីមេធាវី បង្កើតឲ្យមាននូវការព្រួយបារម្ភអំពីគោលការណ៍ស្មើភាពគ្នា។

ក្នុងអំឡុងពេលកិច្ចពិភាក្សាគ្នាជាមួយដៃគូ បន្ទាប់ពីបានការចេញផ្សាយរបាយការណ៍ប្រចាំឆមាសទី២ការឯកភាពគ្នាជាទូទៅផ្តោតទៅលើបញ្ហាកង្វះខាតមេធាវីដែលបណ្តាលមកពីកង្វះខាតធនធានមនុស្ស។ បញ្ហាកង្វះខាតមេធាវីជាទូទៅត្រូវបានជំទាស់។ នេះគឺមានន័យថាជនជាប់ចោទដែលច្បាប់តម្រូវឲ្យទទួលបានជំនួយពីមេធាវីបែរជាគ្មាន រីឯជនជាប់ចោទដែលត្រូវការមេធាវីដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពួកគេនៅតែងាយរងគ្រោះដោយសារតែភាពស្មុគស្មាញនៃដំណើរការនីតិវិធី។ បញ្ហាកង្វះខាតមេធាវីនេះបណ្តាលឲ្យមានការពន្យារពេលសវនាការ ដែលអាចបណ្តាលឲ្យមានការឃុំខ្លួនបណ្តោះអាសន្នលើសថិរវេលាកំណត់។ មានការលើកឡើងថាដំណើរការស្នើសុំមេធាវីមានរយៈពេលយូរ ហើយជាលទ្ធផលមេធាវីត្រូវបានចាត់តាំងនៅនាទីចុងក្រោយ។ ជាការឆ្លើយតបមេធាវី និងអង្គការជំនួយផ្នែកច្បាប់ធ្វើការជំទាស់ថាជារឿយៗពួកគេអវត្តមានពីសវនាការ ដោយសារតែពួកគេមិនបានទទួលការជូនដំណឹងជាមុនក្នុងពេលវេលាមួយគ្រប់គ្រាន់ថាពួកគេត្រូវមានវត្តមាននៅតុលាការ។[22] ក៏ដូចគ្នាដែរក្នុងអំឡុងពេលកិច្ចពិភាក្សាជាមួយមន្ត្រីតុលាការបានឲ្យដឹងថា មានមេធាវីមួយចំនួនជូនដំណឹងអំពីអវត្តមានរបស់ខ្លួនទៅតុលាការនៅថ្ងៃសវនាការតែម្តង ដែលធ្វើឲ្យតុលាការមិនអាចស្វែងរកមេធាវីជំនួសឲ្យបានទាន់ពេលវេលា។ តុលាការគណៈមេធាវី និងអង្គការជំនួយផ្នែកច្បាប់ត្រូវតែធ្វើការជាមួយគ្នា ដើម្បីធានាឲ្យមាននូវការទទួលបានជំនួយពីមេធាវីសម្រាប់បុគ្គលគ្រប់រូបដោយស្មើភាព និងមានប្រសិទ្ធិភាពដូចនេះជនជាប់ចោទទាំងនោះនឹងមានអ្នកជំនាញដើម្បីពន្យល់នូវការចោទប្រកាន់មកលើខ្លួន និងការពារផលប្រយោជន៍របស់ខ្លួននៅក្នុងតុលាការ។

## សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា៣៨នៃរដ្ឋធម្មនុញ្ញ៖** "ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។"
- **មាត្រា១៤(២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖**"ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មត់ជាមុនថាជាជនគ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់។"

សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ជាសិទ្ធិមូលដ្ឋាននៃការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានទទួលស្គាល់ជាសកល។ ទិន្នន័យនៅក្នុងតួលេខទី៩ ខាងក្រោមបង្ហាញថាតើជនជាប់ចោទអាចត្រូវបានគេចាត់ទុកថាមានពិរុទ្ធមុនពេលចេញសាលក្រមដែរឬទេ ឬ/និង តើកត្តាណាខ្លះដែលអាចជះឥទ្ធិពលលើការសន្មតទុកជាមុនរបស់ចៅក្រមអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។

[22]កិច្ចពិភាក្សាជាមួយក្រុមប្រឹក្សាអ្នកច្បាប់ការពារសិទ្ធិកម្ពុជានិងអង្គការជំនួយផ្នែកច្បាប់កម្ពុជានៅឆ្នាំ២០១០។

## តួលេខទី៩៖ ការសន្មតជាមុនថាគ្មានទោស

| ១៧(ក) តើជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានអ្នកទោសដែរ ឬទេ? | | | | | | | |
|---|---|---|---|---|---|---|---|
| ទិន្នន័យ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | | 318 | 60 | 331 | 57 | 243 | 61 |
| គ្មាន | | 160 | 30 | 187 | 32 | 119 | 30 |
| មិនពាក់ព័ន្ធ | | 54 | 10 | 67 | 11 | 36 | 9 |

| ១៧(ខ) តើជនជាប់ចោទត្រូវបានដាក់ខ្នោះក្នុងពេលសវនាការ ដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 0 | 0 | 1 | 0.2 | 1 | 0.3 |
| គ្មាន | 195 | 98 | 478 | 90 | 517 | 88.8 | 361 | 90.7 |
| មិនពាក់ព័ន្ធ | 4 | 2 | 54 | 10 | 67 | 11 | 36 | 9 |

| ១៧(គ) តើចៅក្រមបាននិយាយពីភាពមាន/គ្មានទោសរបស់ជនជាប់ចោទ មុនពេលប្រកាសសាលក្រមដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 20 | 10 | 5 | 1 | 1 | 0.1 | 2 | 1 |
| គ្មាន | 179 | 90 | 527 | 99 | 584 | 99.9 | 396 | 99 |

ទិន្នន័យនៃសំណួរ១៧(ក) បង្ហាញថាអត្រាសរុបដែលជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការនៅក្នុងឯកសណ្ឋានជាអ្នកទោសមានការកើនឡើងបន្តិចបន្តួច។ នៅក្នុងអំឡុងរបាយការណ៍ទី៤ ជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោស មានចំនួនច្រើនជាងពាក់កណ្តាលនៃចំនួនសវនា-ការដែលបានសង្កេត។ នៅពេលក្រឡេកមើលទិន្នន័យពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ៗវិញ ក្នុងចំណោមជនជាប់ចោទចំនួន ៦៨៨នាក់ ដែលបានសង្កេតមានជនជាប់ចោទចំនួន ៣២៩នាក់ ឬស្មើនឹង៤៨% បង្ហាញខ្លួននៅមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោស។ ការជម្រុញឲ្យជនជាប់ចោទចូលរួមសវនាការជាមួយឯកសណ្ឋានជាអ្នកទោស គឺជាបុរេនិច្ឆ័យ ហើយវាបង្ហាញថាមានទោស។ ការអនុវត្តបែបនេះ បើទោះបីជាធ្វើឡើងដោយឆន្ទៈ ឫអឆន្ទៈក្តី វាបង្ហាញរួចជាស្រេចនូវលទ្ធផលចុងក្រោយនៃករណី។ នៅពេលដែលជនជាប់ចោទត្រូវបានបង្ខំឲ្យចូលរួមសវនាការក្នុងឯកសណ្ឋានជាអ្នកទោសនោះ អាចនឹងនាំឲ្យមានការយល់ឃើញថាជននោះមានពិរុទ្ធ ហើយជះឥទ្ធិពលដោយចេតនា ឬអចេតនាទៅលើនីតិវិធី អាកប្បកិរិយារបស់ចៅក្រម និងជាចុងក្រោយគឺទៅលើលទ្ធផលនៃរឿងក្តី។

មាត្រា៩(៥)(ច) នៃប្រកាសលេខ២១៧ស្តីពីការគ្រប់គ្រប់ពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៨ចែងថា៖ *"អ្នកទោសដែលតម្រូវឲ្យបង្ហាញខ្លួននៅមុខតុលាការត្រូវអនុញ្ញាតឲ្យស្លៀកពាក់សំលៀកបំពាក់ស្អាតបាតនិងសមរម្យផ្ទាល់ខ្លួនរបស់គេ។"* នៅពេលពិភាក្សាអំពីឯកសណ្ឋានអ្នកទោសជាមួយមន្ត្រីតុលាការ មន្ត្រីតុលាការបានកត់សម្គាល់ឃើញថា សន្តិសុខគឺជាកត្តាចំបងដែលនាំឲ្យជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោស។ អនុសាសន៍ដែលបានផ្តល់នៅក្នុងរបាយការណ៍ប្រចាំឆមាសទី២ ស្តីពីការអនុញ្ញាតឲ្យជនជាប់ចោទស្លៀកពាក់សំលៀកបំពាក់ផ្ទាល់ខ្លួនដែលឆ្លុះបញ្ចាំងប្រកាសរបស់ក្រសួងមហាផ្ទៃស្តីពីបញ្ហានេះត្រូវបានជំទាស់ថា នឹងអាចជាការផ្តល់ជំនួយឲ្យជនជាប់ចោទរត់

គេច។ ឆ្លើយតបនឹងសំនួររបស់ ម.ស.ម.ក ប្រធានតុលាការខេត្តកណ្តាលបានបញ្ជាក់ថាជនជាប់ចោទដែលស្លៀកសំលៀកបំពាក់ជាអ្នកទោសគួរតែត្រូវបានកំណត់ថាគ្មានទោសរហូតដល់ត្រូវបានគេរកឃើញថាមានទោស។ ប៉ុន្តែចំពោះហេតុផលសុវត្ថិភាព គាត់គិតថាវាជាការល្អប្រសើរបំផុតក្នុងការឲ្យជនជាប់ចោទស្លៀកសំលៀកបំពាក់ជាអ្នកទោសនៅក្នុងសវនាការ ជាជាងសំលៀកបំពាក់ជនស៊ីវិល។ នៅខណៈដែលបញ្ហាសន្តិសុខគឺជាព្រួយបារម្ភសមស្របរបស់រដ្ឋ ការណ៍នេះមិនអាចប្រើជាការដោះសារចំពោះការមិនគោរពសិទ្ធិរបស់ជនជាប់ចោទនោះទេ។ ដែគួពាក់ព័ន្ធមួយចំនួនដែល ម.ស.ម.ក បានជួបពិភាក្សា បានគាំទ្រយន្តការឯកសណ្ឋានពណ៌ខុសគ្នាសម្រាប់ជនជាប់ចោទស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន (បច្ចុប្បន្ននេះអ្នកជាប់ពន្ធនាគារទាំងអស់នៅកម្ពុជា ទាំងអ្នកត្រូវបានផ្តន្ទាទោស និងអ្នកស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នសុទ្ធតែពាក់ឯកសណ្ឋានពណ៌ខៀវ) ឬយន្តការដែលតាមរយៈនោះជនជាប់ចោទអាចស្លៀកពាក់សំលៀកបំពាក់ផ្ទាល់ខ្លួននៅក្នុងសវនាការ។ មានការកត់សម្គាល់ថាបញ្ហានៃឯកសណ្ឋានអ្នកទោសគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រសួងមហាផ្ទៃ។ នៅខណៈដែលក្រសួងមហាផ្ទៃអាចនឹងជាអ្នក ដែលទទួលខុសត្រូវទាំងស្រុងចំពោះការអនុវត្តការផ្លាស់ប្តូរគោលនយោបាយ នៃការស្លៀកពាក់ឯកសណ្ឋានអ្នកទោសនៅពេលសវនាការ មន្ត្រីតុលាការអាចលើកពីគំនិតរបស់ពួកគេ និងធ្វើការតស៊ូមតិដើម្បីឲ្យដំណើរការចាំបាច់មួយចំនួនអាចត្រូវបានដាក់ឲ្យអនុវត្ត ក្នុងគោលបំណងពង្រឹងនូវការសន្មតជាមុនថាគ្មានទោសចំពោះជនជាប់ចោទដែលបង្ហាញខ្លួននៅមុខតុលាការ។

ទិន្នន័យនៃសំណួរ១៧(ខ) បង្ហាញថាមានករណីមួយនៅក្នុងអំឡុងរបាយការណ៍ទី៤ដែលជនជាប់ចោទបង្ហាញខ្លួននៅមុខតុលាការដោយជាប់ខ្នោះដៃ។ ជននេះបានសារភាពថាបានប្រព្រឹត្តអំពើឃាតកម្មដោយគិតទុកជាមុន ហើយត្រូវបានដាក់ខ្នោះរហូតក្នុងពេលសវនាការ និងត្រូវបានការពារយ៉ាងម៉ត់ចត់ដោយមន្ត្រីប៉ូលីស។ ទោះបីជាជនជាប់ចោទបានសារភាព ជនជាប់ចោទនៅតែមានសិទ្ធិពេញលេញទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលគួរតែត្រូវបានគោរព។

ទាក់ទងនឹងសំណួរ១៧(គ) មានករណីចំនួន ២ ដែលចៅក្រមត្រូវបានសង្កេតថាបានពោលពាក្យអំពីភាពមាន ឬគ្មានពិរុទ្ធនៅមុនពេលចេញសាលក្រម។ នៅក្នុងករណីមួយដែលបានកើតឡើងនៅតុលាការរាជធានីភ្នំពេញជនជាប់ចោទចំនួន៣នាក់ ត្រូវបានចោទប្រកាន់ពីបទប្លន់យោងតាមមាត្រា៣៥៣ និង៣៥៧នៃក្រមព្រហ្មទណ្ឌ។ ជនជាប់ចោទត្រូវបានអះអាងថាបានហៅអ្នករត់ម៉ូតូឌុបឲ្យនាំពួកគេទៅវត្តព្រៃស្ពឺដែលជាកន្លែងប្រព្រឹត្តបទល្មើស។ នៅពេលទៅដល់ទីកន្លែងជនជាប់ចោទម្នាក់បានហុចញញួរឲ្យជនជាប់ចោទម្នាក់ទៀតរួចវាយទៅលើអ្នករត់ម៉ូតូឌុបនិងយកម៉ូតូហើយរត់គេចខ្លួន។ ចៅក្រមត្រូវបានស្តាប់ឮថាបាននិយាយទៅកាន់ជនជាប់ចោទម្នាក់៖ "*ព្រោះតែអ្នកឯងជាចោរបានជាទៅជិះម៉ូតូជាមួយចោរ។* "ករណីដែលចៅក្រមត្រូវបានសង្កេតឃើញថាបានប្រើពាក្យពាក់ព័ន្ធនឹងភាពមាន ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទនៅមុនពេលចេញសាលក្រមមានចំនួនត្រឹមតែ១% ប៉ុណ្ណោះនៃសវនាការដែលបានសង្កេតដែលជាការធ្លាក់ចុះពីចំនួន ១០% នៅក្នុងអំឡុងរបាយការណ៍ទី១។ នៅខណៈដែលពាក្យសំដីទាំងនេះជាការព្រួយបារម្ភជាខ្លាំងនិងមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើករណីនីមួយៗ ការធ្លាក់ចុះនៃចំនួនសវនាការដែលមានពាក្យសំដីទាំងនេះគឺជាការវិវឌ្ឍន៍ជាវិជ្ជមានមួយផ្សេងទៀត។

## ឯករាជ្យភាពមិនលំអៀង និងវិជ្ជាជីវៈរបស់ចៅក្រម

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ៖**

- **មាត្រា១២៨នៃរដ្ឋធម្មនុញ្ញ៖** អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។"
- **មាត្រា១៣២នៃរដ្ឋធម្មនុញ្ញ៖** "ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។"
- **មាត្រា១៤(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** "ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀងដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ។"

សិទ្ធិទទួលបានការជំនុំជម្រះពីសំណាក់សាលាជម្រះក្តីដែលឯករាជ្យ និងមិនលំអៀងនេះជាសិទ្ធិមូលដ្ឋាន ដែលគណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានលើកឡើងថា សិទ្ធិនេះជា "*សិទ្ធិមួយដាច់ខាត ដែលគ្មានករណីលើកលែង*"។[23] ទិន្នន័យនៅក្នុងតួលេខទី១០ ខាងក្រោមបង្ហាញថាតើមានអ្វីនៅក្នុងសវនាការដែលជាតម្រុយបង្ហាញថា ភាពមិនលំអៀងរបស់ចៅក្រមស្ថិតនៅក្នុងភាពសង្ស័យ។

### តួលេខទី១០៖ ឯករាជ្យភាព ភាពមិនលំអៀង និង វិជ្ជាជីវៈរបស់ចៅក្រម

| ៨(ក) តើមានអ្វីមួយបង្ហាញថាចៅក្រមមានប្រយោជន៍នៅក្នុងរឿងក្តីដោយសារតួនាទីនៅក្នុងវិស័យតុលាការដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | | | 0 | 0 | 0 | 0 |
| គ្មាន | | | 585 | 100 | 398 | 100 |

| ៨(ខ) តើមានអ្វីមួយបង្ហាញថាភាគីណាមួយបាននិយាយជាមួយចៅក្រមក្នុងអំឡុងពេលពិភាក្សាចេញសេចក្តីសម្រេចដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 32 | 16 | 34 | 6 | 43 | 7.5 | 19 | 5 |
| គ្មាន | 167 | 84 | 498 | 94 | 92 | 15.5 | 106 | 26.5 |
| មិនពាក់ព័ន្ធ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | | 187 | 32 | 10 | 2.5 |
| មិនដឹង | | | | | 263 | 45 | 263 | 66 |

[23]គណៈកម្មាធិការសិទ្ធិមនុស្ស - ទស្សនៈនៃគណៈកម្មាធិការសិទ្ធិមនុស្សចំពោះមាត្រា៥កថាខណ្ឌ៤នៃពិធីសារបន្ថែមរបស់កតិកាសញ្ញាអន្តរជាតិនៃសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយកថាខណ្ឌ៥.២នៃសេចក្តីជូនដំណឹងលេខ២៦៣/១៩៨៧៖លោកហ្គនហ្សាឡេសដេលរីយូជាមួយនឹងប៉េរូ(CCPR/C/46/D/263/1987) ចុះថ្ងៃទី២៨ខែតុលាឆ្នាំ១៩៩២។

នៅក្នុងសវនាការដែលបានសង្កេត គ្មានតម្រុយបង្ហាញថាចៅក្រមមានផលប្រយោជន៍នៅពីក្រោយតួនាទីធម្មតារបស់ពួកគាត់នោះទេ។

ទាក់ទងនឹងការពិភាក្សាសម្រេចសេចក្តីសវនាការចំនួន ១៩ក្នុងចំណោមសវនាការចំនួន ១២៥ដែលមានការពិភាក្សាសម្រេចសេចក្តី (ឬស្មើនឹង ៥%នៃចំនួនសវនាការទាំងអស់) មានតម្រុយបង្ហាញថា ចៅក្រមបានសន្ទនាជាមួយភាគីក្នុងអំឡុងពេលពិភាក្សាសម្រេចសេចក្តី។ នេះជាការវិវឌ្ឍវីកចម្រើនបើប្រៀបធៀបនឹងទិន្នន័យក្នុងអំឡុងរបាយការណ៍មុនៗ ក៏ប៉ុន្តែវានៅតែជាករណីដែលនាំឲ្យមានការព្រួយបារម្ភ។ នៅក្នុងសវនាការទាំង១៩ មន្ត្រីសង្កេតការណ៍បានកត់ត្រាថាមានសវនាការចំនួន៦ ដែលចៅក្រមបាននិយាយជាមួយព្រះរាជអាជ្ញា មានសវនាការចំនួន៦ ដែលចៅក្រមបាននិយាយជាមួយព្រះរាជអាជ្ញា និងមន្ត្រីតុលាការមានសវនាការចំនួន៥ ដែលចៅក្រមនិយាយជាមួយមន្ត្រីតុលាការ និងមានសវនាការចំនួន២ ដែលចៅក្រមនិយាយជាមួយព្រះរាជអាជ្ញា និងមេធាវីជនជាប់ចោទ។ នៅក្នុងអំឡុងកិច្ចពិភាក្សាបញ្ហានេះត្រូវបានលើកឡើងថាក្រឡាបញ្ជីត្រូវការចូលក្នុងបន្ទប់ពិភាក្សាដើម្បីផ្តល់ឯកសារដល់ចៅក្រម។[24] ខណៈដែលនេះអាចជាគោលបំណងនៃការចេញចូលរបស់ក្រឡាបញ្ជី ឬភាគីដទៃទៀតទៅក្នុងបន្ទប់ពិភាក្សា ការចេញចូលនេះដោយមិនគិតទៅលើហេតុផលអាចចោទជាបញ្ហាទៅលើភាពឯករាជ្យ និងមិនលំអៀងរបស់ចៅក្រម។

ក្នុងអំឡុងរបាយការណ៍ទី១ បញ្ហាមួយទៀតត្រូវបានកត់សម្គាល់ដោយមន្ត្រីសង្កេតការណ៍ គឺការសន្ទានាតាមទូរស័ព្ទជាញឹកញាប់របស់ចៅក្រមមេធាវី និងមន្ត្រីតុលាការដូចជាក្រឡាបញ្ជីក្នុងអំឡុងពេលនីតិវិធីសវនាការ។ បន្ទាប់ពីបានសង្កេតឃើញបញ្ហានេះមន្ត្រីសង្កេតការណ៍ចាប់ផ្តើមសង្កេតការប្រើប្រាស់ទូរស័ព្ទដៃរបស់ចៅក្រមនៅក្នុងសវនាការចាប់តាំងពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៩។ ការធ្វើរបៀបនេះធ្វើឲ្យមានការព្រួយបារម្ភថា តើចៅក្រមដែលបានធ្វើការសន្ទនាតាមទូរស័ព្ទបានយកចិត្តទុកដាក់ស្តាប់អំណះអំណាងរបស់ភាគី និងភស្តុតាងដែលបានបង្ហាញដែរឬទេ។ លើសពីនេះ ការធ្វើរបៀបនេះ(ទោះបីជាមិនកើតឡើងក៏ដោយ) អាចបង្ហាញថាចៅក្រមបើកឲ្យមានការទទួលឥទ្ធិពលពីភាគីខាងក្រៅ។

### តួលេខទី១១៖ការប្រើប្រាស់ទូរស័ព្ទដៃរបស់ចៅក្រមក្នុងសវនាការ

| ៨(ង) តើចៅក្រមនិយាយទូរស័ព្ទដៃរឬទេ ក្នុងអំឡុងពេលសវនាការ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 17 | 28 | 151 | 28 | 126 | 22 | 73 | 18 |
| គ្មាន | 43 | 72 | 381 | 72 | 459 | 78 | 325 | 82 |
| ប្រសិនបើមាន តើចៅក្រមឆ្លើយតបបែបណា? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ឆ្លើយដោយខ្លី ហើយដាក់ទូរស័ព្ទចុះ | 11 | 65 | 82 | 54 | 82 | 65 | 44 | 60 |
| បន្តការសន្ទនាតាមទូរស័ព្ទ | 6 | 35 | 69 | 46 | 44 | 34 | 29 | 40 |

[24] កិច្ចពិភាក្សាជាមួយបុគ្គលិកមកពីសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី២៩ខែកក្កដា២០១០

ចំនួនសវនាការដែលចៅក្រមប្រើប្រាស់ទូរស័ព្ទដៃនៅក្នុងពេលសវនាការកំពុងដំណើរការ មានការថយចុះបន្តិចបន្តួចពី២២% នៅក្នុងអំឡុងរបាយការណ៍ទី៣មកនៅត្រឹម១៨% នៅក្នុងអំឡុងរបាយការណ៍ទី៤។ នៅក្នុងសវនាការចំនួន៤០% នៃសវនាការដែលបានសង្កេតទាំងអស់ ចៅក្រមត្រូវបានសង្កេតឃើញថាបានធ្វើការសន្ទនាតាមទូរស័ព្ទ ដែលចំនួននេះបានកើនឡើងបើប្រៀបធៀបនឹងទិន្នន័យនៅក្នុងអំឡុងរបាយការណ៍ទី៣។ ទោះបីជាការសន្ទនាភាគច្រើនធ្វើឡើងក្នុងរយៈពេលខ្លី (ចៅក្រមនៅក្នុងសវនាការចំនួន៦០% នៃករណីនេះ បានសន្ទនាតាមទូរស័ព្ទក្នុងរយៈពេលខ្លីហើយដាក់ចុះ) ក៏ដោយក៏ការធ្វើរបៀបនេះជាការបន្ទាបតម្លៃនីតិវិធីសវនាការ។ ការសន្ទនាតាមទូរស័ព្ទក្នុងពេលសវនាការធ្វើឲ្យរំខានដល់សវនាការ និងចោទជាបញ្ហាអំពីទំហំដែលចៅក្រមបានចូលរួម និងស្តាប់អង្គសវនាការ។

ក្នុងកិច្ចពិភាក្សាជាមួយដៃគូ បញ្ហានេះត្រូវបានកត់សម្គាល់ថាមិនមានច្បាប់ចែងអំពីការសន្ទនាតាមទូរស័ព្ទនៅក្នុងសវនាការដោយចៅក្រម ឬ/និងព្រះរាជអាជ្ញានោះទេ។[25] មានការលើកឡើងថា ចៅក្រមនិងព្រះរាជអាជ្ញាមួយចំនួន មានការរវល់នឹងការងារដទៃទៀត ហើយមន្ត្រីនគរបាលត្រូវការទាក់ទងពួកគេដើម្បីចំណាត់ការរឿងក្តីផ្សេងទៀត ហេតុដូច្នេះហើយការសន្ទនាតាមទូរស័ព្ទមិនអាចបង្ហាញពីការលំអៀងលើរឿងក្តីនោះទេ។ ព្រះរាជអជ្ញារងនៃសាលាដំបូងរាជធានីភ្នំពេញបានលើកឡើងថា ពិតជាពិបាកសម្រាប់ចៅក្រមក្នុងការឈប់ទទួលទូរស័ព្ទ ដោយយោងទៅលើហេតុថាចៅក្រម មានតួនាទីលើករណីផ្សេងទៀតនៅក្នុងពេលតែមួយ។ ប៉ុន្តែចៅក្រមគួរតែឆ្លើយតបខ្លីៗ និងបញ្ចប់ការសន្ទនាភ្លាមនៅពេលកំពុងដំណើរការសវនាការ។ នៅក្នុងខណៈដែលការសន្ទនាតាមទូរស័ព្ទភាគច្រើន ទាក់ទងនឹងការងាររបស់ចៅក្រមក្នុងនីតិវិធីស៊ើបសួរ ការទទួលបានយុត្តិធម៌នៅក្នុងរឿងក្តីមួយ មិនគួរត្រូវបានបន្ទាបតម្លៃ ដើម្បីចំណាត់ការនីតិវិធីនៅក្នុងរឿងក្តីមួយទៀតនោះឡើយ។ ការសន្ទនាតាមទូរស័ព្ទអាចជះឥទ្ធិពលទៅលើទស្សនៈរបស់សាធារណជនទៅលើតុលាការ និងអាចធ្វើឲ្យអ្នកសង្កេតការណ៍យល់ឃើញថា ចៅក្រមបើកឲ្យមានឥទ្ធិពលពីខាងក្រៅនៅក្នុងអំឡុងពេលនីតិវិធី។ សារសម្រាប់ចៅក្រមអាចត្រូវបានប្រមូលយ៉ាងងាយដោយបុគ្គលិកតុលាការដទៃទៀតនៅពេលដែលចៅក្រមកំពុងនៅក្នុងសវនាការ និងឆ្លើយតបសារទាំងនោះនៅពេលដែលសវនាការបានបញ្ចប់។ ក្រសួងយុត្តិធម៌គួរតែចេញសេចក្តីណែនាំអំពីបញ្ហានេះ ដើម្បីបំភ្លឺអំពីគោលការណ៍នៃការប្រើប្រាស់ទូរស័ព្ទដៃក្នុងសវនាការ។

## សិទ្ធិបង្ហាញភស្តុតាង (រួមទាំងសិទ្ធិហៅនិងសាកសួរសាក្សី)

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(៣)(ង) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** "ជនគ្រប់រូបមានសិទ្ធិ [...]មានការសួរចម្លើយឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។
- **មាត្រា១៥៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានប្រយោជន៍ក្នុងការសំដែងឲ្យឃើញការពិត[...]ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ[...]និងសាក្សីផងបានដែរ។"
- **មាត្រា២៩៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីអាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយណាដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញ

[25] កិច្ចសន្ទនាជាមួយចៅក្រម សៀងស៊ីវុត្ថានៅសាលាឧទ្ធរណ៍នៅថ្ងៃទី២០ខែមេសាឆ្នាំ២០១១និងកិច្ចសន្ទនាជាមួយឯកឧត្តមសួងលាងហៃអនុរដ្ឋលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តាធិការ។

សោហ៊ុយ។"

- **មាត្រា៣២៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "នៅពេលបើកពិភាក្សាដេញដោល ភាគីអាចសុំឲ្យតុលាការស្ដាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែមិនកោះហៅឲ្យត្រឹមត្រូវទេ។ការស្ដាប់ចម្លើយសាក្សីនេះត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះឲ្យថយទៅនៅក្នុងបន្ទប់រង់ចាំ។
- **មាត្រា៣២៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ប្រធានសវនាការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ថាមានប្រយោជន៍[...]ព្រះរាជអាជ្ញាមេធាវី និងភាគីអាចត្រូវបានឲ្យលើកសំណួរសួរ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវីសំណួរផ្សេងទៀតត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ាប្រធានសវនាការសម្រេចដោយឥស្សរចិត្តថាតើសំណួរនេះត្រូវតែសួរឬទេ។"

ខណៈដែលតុលាការត្រូវចេញសេចក្ដីសម្រេចដោយពឹងផ្អែកលើភស្តុតាងតែមួយមុខនោះ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវមានឱកាសស្មើគ្នាក្នុងការបង្ហាញភស្តុតាង ដើម្បីគាំទ្ររឿងក្ដីរបស់ខ្លួន។[26] ជាទូទៅភស្តុតាងមាន ៣ ប្រភេទ (១) សក្ខីភាពរបស់សាក្សី (ដូចជាកំណត់ហេតុពីបុគ្គលដែលបានឃើញហេតុការណ៍) (២) ការបង្ហាញឯកសារ (ដូចជាប័ណ្ណកម្មសិទ្ធិដីធ្លី) និង/ឬ (៣) វត្ថុតាង (ដូចជាអាវុធប្រឡាក់ឈាម)។

## តួលេខទី១២៖ ភស្តុតាង

| ៦(ក) តើភស្តុតាងត្រូវបានបង្ហាញដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 153 | 77 | 512 | 96 | 569 | 97 | 394 | 99 |
| គ្មាន | 46 | 13 | 20 | 4 | 16 | 3 | 4 | 1 |
| **៧(ក) តើមានអ្វីមួយ ដែលបង្ហាញថាភាគីណាមួយមិនទទួលបានឱកាសបង្ហាញភស្តុតាងដែរឬទេ?** | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 3 | 2 | 3 | 1 | 0 | 0 | 0 | 0 |
| គ្មាន | 196 | 98 | 529 | 99 | 585 | 100 | 398 | 100 |

ទិន្នន័យសំណួរ៦(ក) បង្ហាញថាចំនួនសវនាការដែលមានការបង្ហាញភស្តុតាងមានការកើនឡើងជិត ១០០%នៃចំនួនសវនាការទាំងអស់។ គ្មានសវនាការណាមួយ ដែលបង្ហាញថា ភាគីត្រូវបានបដិសេធមិនផ្ដល់ឱកាសបង្ហាញភស្តុតាងនោះទេ។

ពាក់ព័ន្ធនឹងគោលការណ៍ស្មើភាពគ្នា ភាគីនីមួយៗមានសិទ្ធិហៅសាក្សី ដើម្បីផ្ដល់សក្ខីកម្មគាំទ្ររឿងក្ដីរបស់ខ្លួន និងសាកសួរសាក្សីដែលហៅដោយភាគីដទៃទៀតនៃរឿងក្ដី។[27] ជនជាប់ចោទមានសិទ្ធិហៅ និង

---

[26]មាត្រា៣៣៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[27]មាត្រា១៤(៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។មាត្រា២៩៨៣២៤និង៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាកសួរសាក្សីរបស់ខ្លួនក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងសាក្សីដាក់បន្ទុកខ្លួន។[28] សិទ្ធិនេះមិនគួរត្រូវបានបកស្រាយថាជាសិទ្ធិដែលគ្មានព្រំដែន អាចបង្ខំសាក្សីឲ្យចូលរួមសវនាការ ឬជាសិទ្ធិដែលអាចហៅសាក្សីដោយមិនកំណត់ចំនួននោះទេ។ មាត្រា៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បញ្ជាក់ថាសាក្សីគួរតែនៅក្នុងបន្ទប់រង់ចាំរហូតដល់ពេលត្រូវបានហៅទៅសាកសួរ ហើយសាក្សីមិនគួរមើលឃើញ ឬស្តាប់ឮអ្វីដែលកើតឡើងនៅក្នុងបន្ទប់សវនាការ នៅមុនពេលផ្តល់សក្ខីភាពនោះទេ។ នៅក្នុងបន្ទប់រង់ចាំ សាក្សីមិនអនុញ្ញាតឲ្យទាក់ទងជាមួយសាក្សីដទៃទៀតនោះទេ។[29] ការបញ្ញត្តិរបៀបនេះ មានគោលបំណងជៀសវាងនូវករណី ដែលសាក្សីយកលំនាំតាម ឬក្លែងសក្ខីភាពឲ្យស្របតាមដំណើរនៃរឿងក្តី។

## តួលេខទី១៣៖សិទ្ធិហៅនិងសាកសួរសាក្សី

| ៥(ក) តើមានអ្វីមួយបង្ហាញថាភាគីណាមួយមិនបានទទួលឱកាសហៅសាក្សីដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 4 | 2 | 1 | 0.18 | 2 | 0.4 | 0 | 0 |
| គ្មាន | 195 | 98 | 531 | 99.82 | 583 | 99.6 | 398 | 100 |
| ៧(ខ) តើមានអ្វីមួយបង្ហាញថាភាគីណាមួយមិនបានទទួលឱកាសសាកសួរសាក្សីដែរឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 3 | 0.56 | 0 | 0 | 0 | 0 |
| គ្មាន | 58 | 29 | 79 | 14.44 | 119 | 20 | 91 | 23 |
| មិនពាក់ព័ន្ធ | 141 | 71 | 450 | 85 | 466 | 80 | 307 | 77 |
| ៥(ខ) តើសាក្សីស្ថិតក្នុងបន្ទប់សវនាការដែរឬទេ នៅមុនពេលសាកសួរ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 10 | 5 | 28 | 5 | 22 | 4 | 22 | 5 |
| គ្មាន | 48 | 24 | 54 | 10 | 97 | 16 | 72 | 18 |
| មិនពាក់ព័ន្ធ | 141 | 71 | 450 | 85 | 466 | 80 | 307 | 77 |

នៅក្នុងអំឡុងរបាយការណ៍ទី៤ គ្មានសវនាការណាមួយដែលបង្ហាញថាភាគីណាមួយមិនទទួលបានឱកាសហៅសាក្សីនោះទេ ជាការវិវឌ្ឍវិជ្ជមាន។ ទាក់ទងនឹងសំណួរ៧(ខ) នៅក្នុងសវនាការដែលបានសង្កេតទាំងអស់ភាគីទទួលបានឱកាសសាកសួរសាក្សី។

[28]មាត្រា១៤(៣)(ង) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[29]មាត្រា៣២២នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## សិទ្ធិទទួលដឹងឮភស្តុតាង

**ប្រភពច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា១៤(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖** "ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការនិងសាលាជំរះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ។"[30]
- **មាត្រា៣១៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "មុនពេលសវនាការមេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជី នៃតុលាការនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។ មេធាវី ឬលេខាធិការរបស់មេធាវី អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការ ឲ្យធ្វើការចម្លងលិខិតនៃសំណុំរឿងដោយខ្លួនជាអ្នកចេញសោហ៊ុយនិងនៅក្រោមត្រួតពិនិត្យរបស់ក្រឡាបញ្ជី។
- **មាត្រា១២៩, ១៤៥, ១៤៩, ១៧០, ២៥៩និង៤២៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ។**

សិទ្ធិទទួលដឹងឮអំពីភស្តុតាង មានន័យថាចុងចម្លើយមានសិទ្ធិទទួលបានឯកសារផ្សេងៗ ដើម្បីស្វែងយល់ពីភស្តុតាងដែលពាក់ព័ន្ធនៅក្នុងសំនុំរឿង។ ឯកសារសំខាន់ៗ គឺជាសំណុំរឿងដែលរៀបចំដោយចៅក្រមស៊ើបសួរ ដែលក្នុងនោះមានដីកាបញ្ជូនសំនុំរឿងទៅជំនុំជម្រះ ដែលត្រូវបានបញ្ជូនទៅឲ្យប្រធានតុលាការដើម្បីកំណត់កាលបរិច្ឆេទសវនាការជំនុំជម្រះ។ សំណុំរឿងនេះមានភស្តុតាងទាំងអស់ដែលប្រមូលបាន និងសេចក្តីសន្និដ្ឋានរបស់ចៅក្រមស៊ើបសួរ។

### តួលេខទី១៤៖ សិទ្ធិទទួលដឹងឮភស្តុតាងរបស់ភាគីម្ខាងទៀត

| ៧(គ) តើមានអ្វីមួយបង្ហាញថាភស្តុតាងដូចគ្នាមិនត្រូវបានដឹងឮដោយភាគីទាំងពីរដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 3 | 2 | 4 | 1 | 0 | 0 | 0 | 0 |
| គ្មាន | 196 | 98 | 528 | 99 | 585 | 100 | 398 | 100 |

## សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា៣៨នៃរដ្ឋធម្មនុញ្ញ៖** "ច្បាប់ហាមឃាត់មិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ[...] ការចោទប្រកាន់ការចាប់ខ្លួនការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅ

---

[30]គណៈកម្មាធិការនៅក្នុងបទអត្ថាធិប្បាយទូទៅលេខ ៣២ បានបញ្ជាក់ថា "សិទ្ធិស្មើភាពនៅចំពោះមុខតុលាការ និងសាលាជម្រះក្តីក្នុងន័យទូទៅ ធានាបន្ថែមលើគោលការណ៍ដែលមាននៅក្នុងឃ្លាទី២ នៃមាត្រា ១៤ កថាខណ្ឌ ១ ការទទួលបានស្មើគ្នា និងសិទ្ធិស្មើគ្នា និងធានាថាភាគីនៃរឿងក្តីត្រូវបានយកចិត្តទុកដាក់ដោយគ្មានការរើសអើង។" គណៈកម្មាធិការសិទ្ធិមនុស្ស បទអត្ថាធិប្បាយទូទៅ លេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពនៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (CCPR/C/GC/32) ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧។ អាចរកបាននៅលើគេហទំព័រ៖ [http://www.unhcr.org/refworld/category,LEGAL,,GENERAL,,478b2b2f2,0.html](http://www.unhcr.org/refworld/category,LEGAL,,GENERAL,,478b2b2f2,0.html)

កើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ [...]ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តីតាមផ្លូវចិត្តក្តីមិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ[...] វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"

- **មាត្រា១៤(៣)(ឆ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖** "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ[...] មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯងឬសារភាពថាមានពិរុទ្ធ។"

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធ ទាក់ទងនឹងការហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្ម យោរយៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬដាក់ទណ្ឌកម្ម។ នេះគឺមានន័យថា គ្មានការគាបសង្កត់ផ្លូវចិត្ត ឬផ្លូវកាយ ដោយផ្ទាល់ ឬមិនផ្ទាល់ ដែលបង្កជាស្លាកស្នាមលើជនជាប់ចោទដោយមន្ត្រីស៊ើបអង្កេត ឬមន្ត្រីតុលាការ ដើម្បីទទួលបានចម្លើយសារភាពឡើយ។

### តួលេខទី១៥៖សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព

| ១៤(គ) តើមានអ្វីមួយបង្ហាញថា ជនជាប់ចោទត្រូវបានគំរាមកំហែងបង្ខំឲ្យសារភាព ដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 6 | 3 | 28 | 5 | 39 | 7 | 12 | 3 |
| គ្មាន | 193 | 97 | 504 | 95 | 546 | 93 | 386 | 97 |
| ១៤(ឃ) តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទត្រូវបានគេធ្វើទារុណកម្មបង្ខំឲ្យសារភាពដែរឬទេ? | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 10 | 5 | 35 | 7 | 44 | 8 | 23 | 6 |
| គ្មាន | 189 | 95 | 497 | 93 | 541 | 92 | 375 | 94 |

ស្របតាមគោលបំណងនៃសំណួរ ១៤(គ) ការបង្ខិតបង្ខំត្រូវបានឲ្យនិយមន័យថាជាការគាបសង្កត់ផ្លូវចិត្តមិនត្រឹមត្រូវ ដូចជាការគំរាមកំហែង។ សំណួរ ១៤(ឃ) ត្រូវបានប្រើដើម្បីសង្កេតថា តើមានអ្វីមួយដែលបង្ហាញថា ជនជាប់ចោទត្រូវបានគាបសង្កត់ឲ្យសារភាព តាមរយៈការប្រើអំពើហិង្សា ឬទារុណកម្ម។ ឧទាហរណ៍នៃតម្រុយដែលកត់សម្គាល់ដោយមន្ត្រីសង្កេតការណ៍ ថាជនជាប់ចោទត្រូវបានបង្ខំឲ្យសារភាពតាមរយៈការប្រើអំពើហិង្សា ឬទារុណកម្ម រួមមានការអះអាងជាក់លាក់របស់ជនជាប់ចោទ អំពីការប្រព្រឹត្តិមិនត្រឹមត្រូវ និងការសង្កេតមើលស្លាកស្នាមដែលកើតចេញពីការរំលោភបំពានលើរាងកាយ។ គួរកត់សម្គាល់ផងដែរថា ទិន្នន័យនៃសំណួរនេះហាក់ដូចជាការប៉ាន់ស្មាន ដោយសារតែមន្ត្រីសង្កេតការណ៍សវនាការមិនអាចកំណត់ឲ្យប្រាកដប្រជាថា អំណះអំណាងរបស់ជនជាប់ចោទនៅក្នុងតុលាការជាការពិតឬយ៉ាងណា។

ចំនួនសវនាការដែលបង្ហាញថាការគំរាមកំហែងត្រូវបានប្រើប្រាស់ដើម្បីបង្ខំឲ្យជនជាប់ចោទសារភាព ឬករណីដែលអំពើហិង្សា ឬទារុណកម្មត្រូវបានប្រើប្រាស់មានការធ្លាក់ចុះពី៧% និង ៨%នៅក្នុងអំឡុងរបាយការណ៍ទី៣ មកនៅត្រឹម៣% និង៦% នៃចំនួនសវនាការទាំងអស់។ នៅពេលពិភាក្សាអំពីទិន្នន័យដែល

ប្រមូលបាននៅក្នុងអំឡុងរបាយការណ៍មុនៗ ជាមួយចៅក្រមនៅតុលាការចៅក្រមភាគច្រើនបាននិយាយថាវាជាធម្មតាទេដែលជនជាប់ចោទនឹងដោះសារបែបនេះ នៅពេលដែលមន្ត្រីនគរបាលមិនមានវត្តមានក្នុងបន្ទប់សវនាការហេតុដូច្នេះហើយទើបការត្រួតពិនិត្យឲ្យបានម៉ត់ចត់មានសារៈសំខាន់ដើម្បីបង្ហាញថាការពិតការគំរាមកំហែង ឬអំពើហិង្សាគឺមិនបានកើតឡើងទេ។ ចៅក្រមខ្លះកត់សម្គាល់ឃើញថាប្រសិនបើមានការប្រព្រឹត្តអំពើហិង្សានោះជនជាប់ចោទ គួរតែដាក់ពាក្យបណ្តឹងទៅសភាស៊ើបសួរ ដើម្បីបដិសេធសក្ខីកម្មនោះ។ ខណៈដែលមន្ត្រីនគរបាលមានទំនួលខុសត្រូវក្នុងការមិនប្រើអំពើហិង្សាជាការសំខាន់ណាស់ដែលតុលាការ ជាពិសេសព្រះរាជអាជ្ញា ធ្វើការណែនាំមន្ត្រីនគរបាលអំពីបញ្ហានេះហើយរំឭកពួកគេថាពួកគេនឹងប្រឈមមុខនឹងច្បាប់ ប្រសិនបើប្រើប្រាស់អំពើហិង្សាដើម្បីទទួលបានចម្លើយសារភាព។ ចៅក្រមចាំបាច់មានការប្រុងប្រយ័ត្ននៅពេលពិចារណាទៅលើចម្លើយសារភាពណាមួយ ដែលត្រូវបានអះអាងថាទទួលបានតាមរយៈការបង្ខិតបង្ខំមិនត្រឹមត្រូវ ដោយយោងតាមរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ យោងតាមមាត្រា៣២១នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលរកឃើញថាចម្លើយសារភាពបានមកពីការគាបសង្កត់ផ្លូវកាយ ឬផ្លូវចិត្ត ចៅក្រមមិនត្រូវយកជាភស្តុតាងនោះទេ ។

## ហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

**ប្រភពនៅក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ៖**

- **មាត្រា១៥នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ៖** "គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះមិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើស ហើយច្បាប់បានបញ្ញត្តិឲ្យមានការដាក់ទោសស្រាលជាងមុនជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។ គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើ ឬការខកខានណាមួយដែលជននោះបានប្រព្រឹត្ត ក្នុងខណៈពេលដែលអំពើ ឬការខកខាននោះជាបទល្មើសព្រហ្មទណ្ឌស្របតាមគោលការណ៍។

គោលការណ៍សំខាន់នៃច្បាប់ព្រហ្មទណ្ឌ គឺថាគ្មានបុគ្គលណាមួយត្រូវបានរកឃើញថាមានពិរុទ្ធ ដោយសារការប្រព្រឹត្តអំពើ ឬការធ្វេសប្រហែសដែលមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌក្នុងពេលដែលអំពើ ឬការធ្វេសប្រហែសនោះកើតមានឡើង។ ដូចគ្នានេះដែរ បទប្បញ្ញត្តិដែលចែងអំពីទោសដែលធ្ងន់ជាងបទប្បញ្ញត្តិដែលអនុវត្តនៅពេលដែលបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្ត នឹងមិនត្រូវបានអនុវត្តឡើយ។

តួលេខទី១៦៖ ហាមឃាត់ចំពោះការអនុវត្តអនុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

| ១៨(ក) តើមានអ្វីមួយ ដែលបង្ហាញថាជនជាប់ចោទត្រូវបានជំនុំជម្រះរឿងក្តីនេះពីមុនមកដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | | | 1 | 0.1 | 1 | 0.2 |
| គ្មាន | | | 1028 | 99.9 | 687 | 99.8 |

| ២១(ច) តើការសម្រេចទោសនៅកម្រិតទោសប្បញ្ញត្តិត្រូវបានអនុវត្តនៅក្នុពេលដែលប្រព្រឹត្តបទល្មើសដែរឬទេ? | | | | | | |
|---|---|---|---|---|---|---|
| ទិន្នន័យ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | ទិន្នន័យមិនត្រូវបានប្រមូលនៅក្នុងអំឡុងពេលរបាយកាណ៍នេះ | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | | | 166 | 60.1 | 299 | 43 |
| គ្មាន | | | 0 | 0 | 97 | 14 |
| មិនពាក់ព័ន្ធ | | | 110 | 39.9 | 40 | 6 |
| មិនដឹង | | | | | 252 | 37 |

ទាក់ទងនឹងសំណួរ ១៨(ក) និង ២១(ច) ទិន្នន័យពាក់ព័ន្ធនឹងជនជាប់ចោទម្នាក់ៗ មិនមែនសវនាការទាំងមូលនោះទេ។

នៅក្នុងសវនាការដែលបានសង្កេត មានសវនាការចំនួនមួយដែលមានជំនុំជម្រះពីរដងលើបទល្មើសដដែល។ ជនជាប់ត្រូវបានចោទប្រកាន់ពីបទលួចយោងតាមមាត្រា៨៣ នៃច្បាប់អ៊ិនតាក់។ នៅក្នុងសវនាការនៃតុលាការរាជធានីភ្នំពេញ ជនជាប់ចោទបានប្រាប់ចៅក្រមថាខ្លួនត្រូវបានកាត់ទោសលើបទល្មើសនេះម្តងរួចមកហើយនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០។ នៅពេលសវនាការបានបញ្ចប់ ជនជាប់ចោទត្រូវបានរកឃើញថាគ្មានពិរុទ្ធ។

សំណួរ ២១(ច) ត្រូវបានបញ្ចូលក្នុងតារាងសង្កេតការណ៍សវនាការនៅខែតុលា ឆ្នាំ២០១០ និងត្រូវបានបញ្ចូលដោយសារក្រមព្រហ្មទណ្ឌចូលជាធរមានបានចែងថា បទប្បញ្ញត្តិថ្មីដែលចែងឲ្យមានទោសស្រាលជាងត្រូវអនុវត្តភ្លាម ប៉ុន្តែបទប្បញ្ញត្តិណាដែលចែងឲ្យមានទោសធ្ងន់ជាងនឹងត្រូវបានអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបច្បាប់ប៉ុណ្ណោះ។[31] ហេតុដូច្នេះហើយ ការផ្តន្ទាទោសទៅលើជនជាប់ចោទចំនួន ៩៧នាក់(១៤%) គឺមិនស្ថិតនៅក្នុងកម្រិតទោសដែលអនុវត្តនៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តនោះទេ។ នេះជាលទ្ធផលដែលចៅក្រមបានអនុវត្តបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌទាក់ទងនឹងទោសដែលស្រាលជាង។ ទិន្នន័យ "មិនពាក់ព័ន្ធ" នៅក្នុងសំណួរនេះមានចំនួន ៤០ករណីដែលជនជាប់ចោទដែលត្រូវបានប្រកាសថាគ្មានពិរុទ្ធ ឬចាត់របៀប។ ទិន្នន័យ "មិនដឹង" មានន័យថាមិនទទួលបានព័ត៌មានពីសាលក្រម។

## សវនាការពាក់ព័ន្ធនឹងអនីតិជន

អនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ដែលអនុវត្តចំពោះនីតិជន ក៏ដូចជាមានការការពារបន្ថែមដោយសារតែអាយុ ភាពចាស់ទុំ និងការវិវឌ្ឍន៍ផ្នែកសតិបញ្ញា។ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និង អនុសញ្ញាស្តីពីសិទ្ធិកុមារ បានបញ្ញត្តិនូវវិធានការណ៍ជាក់លាក់សម្រាប់ការពារអនីតិជននៅក្នុងនីតិវិធីព្រហ្មទណ្ឌ និង ត្រូវបានគាំទ្រដោយវិធាន និងសេចក្តីណែនាំអន្តរជាតិមួយចំនួន។ មាត្រា ៣១ និង ៤៨ នៃរដ្ឋធម្មនុញ្ញបានទទួលស្គាល់យ៉ាងច្បាស់នូវអនុសញ្ញាស្តីពីសិទ្ធិកុមារ និងធានាថារដ្ឋត្រូវការពារសិទ្ធិកុមារ ហើយច្បាប់ជាតិក៏បានបង្កើតបទបញ្ញត្តិផ្សេងៗ ដាច់ដោយឡែកសម្រាប់អនីតិជននៅក្នុងចំណុចសំខាន់ៗមួយចំនួន។

[31] សូមអានមាត្រា៩និង១០នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

តួលេខទី១៧៖ សវនាការពាក់ព័ន្ធនឹងអនីតិជន

| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
|---|---|---|---|---|---|---|---|---|
| ចំនួនសវនាការ | 26 | | 46 | | 48 | | 24 | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| បទឧក្រិដ្ឋ | 16 | 62 | 33 | 72 | 30 | 62 | 12 | 50 |
| បទមជ្ឈិម | 10 | 48 | 13 | 28 | 18 | 38 | 12 | 50 |

នៅក្នុងអំឡុងរបាយការណ៍ទី៤ មានសវនាការចំនួន ២៤ក្នុងចំណោមសវនាការសរុបចំនួន ៣៩៨ ពាក់ព័ន្ធនឹងអនីតិជន (ស្មើនឹង ៦%នៃចំនួនសវនាការសរុប)។ ជាសរុប ជនជាប់ចោទជាអនីតិជនចំនួន៥៣នាក់ត្រូវបានសង្កេតនៅក្នុងអំឡុងរបាយការណ៍ទី៤។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅកម្ពុជាត្រូវបានកំណត់អាយុចាប់ពី ១៨ឆ្នាំ ឡើងទៅ។ ជនដែលមានអាយុក្រោម ១៨ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើសមិនអាចត្រូវបានចោទប្រកាន់ ឬជំនុំជម្រះដោយតុលាការទេ។ អនីតិជនដែលមានអាយុរវាងពី១៤ ដល់ ១៨ឆ្នាំ អាចទទួលខុសត្រូវព្រហ្មទណ្ឌ ឋិតនៅក្នុងសភាពជាក់លាក់នៃទោសព្រហ្មទណ្ឌ ដែលត្រូវបានដាក់ទៅលើអនីតិជនដែលរកឃើញថាមានពិរុទ្ធភាព។ នៅក្នុងលក្ខណៈបែបនេះ អនីតិជនមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដូចនីតិជនដែរ ក៏ដូចជាមានការការពារបន្ថែមដោយសារតែអាយុ ភាពចាស់ទុំ និងការវិវឌ្ឍន៍ផ្នែកសតិបញ្ញា។ ជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅនឹងទទួលការជំនំជុំរះក្នុងលក្ខណៈជានីតិជន។

### អនីតិជន – ភាពឯកជន

- **មាត្រា ១៤(១)នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ៖** "សារព័ត៌មាន និងសាធារណៈជនអាចមិនឲ្យចូលរួមទាំងស្រុង[...] នៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ [...] ប៉ុន្តែការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌត្រូវប្រកាសជាសាធារណៈលើកលែងតែផលប្រយោជន៍អនីតិជនតម្រូវផ្សេងពីនេះ ឬរឿងក្តីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។"
- **មាត្រា ៤០(២)(VII)នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖** "រដ្ឋភាគីត្រូវធានា ជាពិសេសថា [...] ត្រូវគោរពយ៉ាងពេញលេញ នូវសិទ្ធិនៃជីវិតឯកជនរបស់កុមារ នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។"

សវនាការព្រហ្មទណ្ឌ ដែលពាក់ព័ន្ធនឹងនីតិជនជាទូទៅគួរតែធ្វើឡើងជាសាធារណៈដើម្បីផ្តល់សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ក៏ប៉ុន្តែ នៅពេលដែលសវនាការពាក់ព័ន្ធនឹងអនីតិជន ជាការស្របច្បាប់ក្នុងការដាក់កម្រិតទៅលើការចូលរួមស្តាប់សវនាការដើម្បីការពារភាពឯកជនរបស់អនីតិជន និងចៀសវាងទទួលការស្អប់ខ្ពើម។

### តួលេខទី១៨៖ អនីតិជន – ភាពឯកជន

| ២(ក) តើមានការបិទប្រកាសលើក្តារខៀនសាធារណៈដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី ៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 0 | 0 | 21 | 44 | 8 | 33 |
| គ្មាន | 26 | 100 | 46 | 100 | 27 | 56 | 16 | 67 |
| **២(ខ) តើមានសាធារណជនដែលត្រូវហាមឃាត់មិនឲ្យចូល ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ?** | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 0 | 0 | 0 | 0 | 1 | 4 |
| គ្មាន | 26 | 100 | 46 | 100 | 48 | 100 | 23 | 96 |
| **២៤(ក) តើមានវិធានការណ៍អ្វីខ្លះដែលការពារភាពឯកជនរបស់ជនជាប់ចោទជាអនីតិជនក្នុងពេលសវនាការ?** | | | | | | | | |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 0 | 0 | 0 | 0 | 2 | 8 |
| គ្មាន | 26 | 100 | 46 | 100 | 57 | 97 | 22 | 92 |

ទិន្នន័យសម្រាប់សំណួរ២(ខ) នៃតារាងសង្កេតការណ៍សវនាការអនីតិជនបង្ហាញថា តុលាការដែលបានសង្កេត បានកម្រិតចំពោះការចូលរួមនៅក្នុងសវនាការចំនួនមួយដែលពាក់ព័ន្ធនឹងអនីតិជន។ ស្ថានភាពជុំវិញការដាក់កម្រិតនេះ ត្រូវបានបញ្ជាក់នៅខាងដើមជំពូកនេះ គឺដោយសារតែសមាជិកគ្រួសារបង្កការរំខាននៅក្នុងបន្ទប់សវនាការ ហើយឆ្លើយសំណួរជំនួសអនីតិជន។ មានសវនាការចំនួន ២ដែលវិធានការណ៍ការពារត្រូវបានអនុវត្ត។ ករណីទីមួយកើតឡើងនៅតុលាការរាជធានីភ្នំពេញ ទាក់ទងនឹងអនីតិជនអាយុ ១៥ឆ្នាំ ជាប់ចោទពីបទស្ថានទំងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ តាមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។ នៅថ្ងៃទី១៩ ខែមករា ២០១១ ជនរងគ្រោះភេទស្រីអាយុ ៥ឆ្នាំ បានដើរទៅផ្ទះរបស់ជនជាប់ចោទដើម្បីមើលទូរទស្សន៍។ ជនជាប់ចោទចើបនាង ហើយប្រាប់ឲ្យនាងដោះសំពត់ចេញមុននឹងរំលោភនាង។ នៅក្នុងសវនាការ របាំងត្រូវបានដាក់ដើម្បីការពារភាពឯកជនរបស់ជនជាប់ចោទជាអនីតិជន ដោយសារគាត់ខ្លាចសាធារណជននៅក្នុងសវនាការ។ លើសពីនេះទៅទៀត ជនជាប់ចោទត្រូវបានឪពុក និងមេធាវី អះអាងថាមានបញ្ហាខាងស្មារតី ហេតុដូច្នេះហើយទើបត្រូវការការការពារបន្ថែម។

ខណៈដែលវាជាការប្រសើរដែលមានការរកឃើញថាការការពារសិទ្ធិរបស់ជនជាប់ចោទជាអនីតិជន និងជនរងគ្រោះជាអនីតិជន ត្រូវបានអនុវត្ត ទិន្នន័យបង្ហាញថាអត្រាករណីដែលមានការការពារនេះនៅមានចំនួនទាប។ តុលាការត្រូវតែយកចិត្តទុកដាក់បន្ថែមលើការការពារភាពឯកជនរបស់អនីតិជន។ មន្ត្រីនៅឯតុលាការដែលបានសង្កេត បាននិយាយថា ក្រុមប្រឹក្សាជំនុំជម្រះពិចារណាអំពីបញ្ហាសវនាការអសាធារណៈរបស់អនីតិជនយ៉ាងម៉ត់ចត់។ បញ្ហានេះត្រូវបានកត់សម្គាល់ថាតុលាការទាំងពីរអនុវត្តសវនាការអសាធារណៈតែចំពោះរឿងក្តីពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ។ កិច្ចសន្ទនាជាមួយតុលាការបានបង្ហាញថា ការការពារត្រូវបានអនុវត្តជាញឹកញាប់ទៅលើរឿងក្តីដែលពាក់ព័ន្ធនឹងជនរងគ្រោះជាអនីតិជន ជាជាងជនជាប់ចោទជាអនីតិជន ជាពិសេសរឿងក្តីពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ។ តុលាការគួរតែទទួលស្គាល់ថាការការពារ

ភាពឯកជនរបស់អនីតិជនគួរតែអនុវត្តទាំងទៅលើជនរងគ្រោះជាអនីតិជន និងជនជាប់ចោទជាអនីតិជន ហើយត្រូវតែផ្តល់ការយកចិត្តទុកដាក់ឲ្យបានច្រើនទៅលើប្រភេទនៃរឿងក្តីដែលជំនុំជម្រះជាអសាធារណៈ។

## អនីតិជន – ការឃុំខ្លួនបណ្តោះអាសន្ន

**ប្រភពនៅក្នុងច្បាប់នៅកម្ពុជា និង ច្បាប់អន្តរជាតិ៖**

- **មាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ។
- **មាត្រា២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "អនីតិជនអាយុតិចជាង ១៤ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជនឲ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។"
- **មាត្រា២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** "ចំពោះអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលាឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ៖
  ១. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ខែបានទេ កាលណាអនីតិជនមានអាយុតិចជាង ១៦ឆ្នាំ។
  ២. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ខែបានទេ កាលណាអនីតិជនមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ។
- **មាត្រា ២១៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** " ចំពោះអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំដល់ក្រោម ១៨ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ៖
  ១. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២ខែបានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ឆ្នាំ។
  ២. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ខែបានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ ដល់ក្រោម១៨ឆ្នាំ។
  ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នតាមចំណុចទី១ និង ចំណុចទី២ខាងលើនេះ មិនត្រូវលើសពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំនត់សម្រាប់អនីតិជននោះឡើយ។"

ដូចទៅនឹង និងលើសពីករណីនីតិជន បទដ្ឋានអន្តរជាតិមិនជំរុញឲ្យមានការឃុំខ្លួនបណ្តោះអាសន្នឡើយក្នុងរឿងក្តីពាក់ព័ន្ធអនីតិជន។ ក្នុងករណីភាគច្រើន ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារត្រូវបានការពារដោយមិនឲ្យពួកគេនៅឆ្ងាយពីឪពុកម្តាយ។[32] ការឃុំខ្លួនកុមារ រួមទាំងបន្ទាប់ពីការចាប់ខ្លួន និងមុនពេលសវនាការ គួរតែត្រូវបានចៀសវាងតាមដែលអាចធ្វើទៅបាន និងគួរតែត្រូវបានប្រើជាវិធានការណ៍ចុងក្រោយបង្អស់ក្នុងរយៈពេលមួយដ៏ខ្លី។[33] ទាំងបទដ្ឋានច្បាប់ជាតិ និងអន្តរជាតិចែងយ៉ាងជាក់លាក់ថាក្នុង

[32] មាត្រា៩នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[33] មាត្រា៣៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។មាត្រា៩៦និង២១២នៃក្រមនីតិវិធីព្រហ្មទណ្ឌ។មាត្រា២១២ នៃនីតិវិធីក្រមព្រហ្មទណ្ឌ ហាមឃាត់ការឃុំខ្លួនរបស់អនីតិជនអាយុក្រោម១៤ឆ្នាំដោយមាត្រា២១៣និង២១៤ កំណត់ថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់អនីតិជនអាយុពី ១៤ឆ្នាំ ទៅ១៨ឆ្នាំដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម។

ករណីលើកលែងដែលអនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្នពួកគេគួរតែត្រូវបានដាក់ដាច់ដោយឡែកពីនីតិជន។[34]

**តួលេខទី១៩៖ អនីតិជន – ការឃុំខ្លួនបណ្ដោះអាសន្ន**

| ២៣ តើមានការឃុំខ្លួនបណ្ដោះអាសន្នដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 17 | 65 | 44 | 96 | 42 | 87.5 | 17 | 71 |
| គ្មាន | 7 | 27 | 1 | 2 | 5 | 10.5 | 7 | 29 |
| មិនពាក់ព័ន្ធ | 0 | 0 | 0 | 0 | 0 | 0 | | |
| មិនដឹង | 2 | 8 | 1 | 2 | 1 | 2 | | |

| ២៣(ខ) ប្រសិនបើមាន តើមានអ្វីមួយ ដែលបង្ហាញថាជនជាប់ចោទមិនត្រូវបានចែកឲ្យដាច់ពីនីតិជនដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មាន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| គ្មាន | 18 | 69 | 44 | 96 | 43 | 90 | 17 | 71 |
| មិនពាក់ព័ន្ធ | 8 | 31 | 2 | 4 | 5 | 10 | 7 | 29 |

ក្នុងសវនាការដែលបានសង្កេតចំនួន ៩២%ដែលជនជាប់ចោទជាអនីតិជន ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។ នៅពេលដែលក្រឡេកមើលទៅលើជនជាប់ចោទជាអនីតិជនម្នាក់ៗវិញ អនីតិជនចំនួន ៥៣ នាក់ ឬស្មើនឹង ៧០% ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។ នេះជាអត្រាមួយដែលខ្ពស់ជាងអត្រាឃុំខ្លួននីតិជនបណ្ដោះអាសន្នទៅទៀត ដែលមានត្រឹមតែ៦៩%។ ការណ៍នេះត្រូវបានបដិសេធដោយអ្នកតំណាងរបស់តុលាការរាជធានីភ្នំពេញនៅពេលដែល ម.ស.ម.កបានជួបដើម្បីពិភាក្សាអំពីរបាយការណ៍ប្រចាំឆមាសលើកទី២ ថាអនីតិ-ជនតែងតែត្រូវបានឃុំខ្លួនបណ្ដោះអាសន្ននៅពេលដែលមន្ត្រីនគរបាល និងតុលាការកំពុងត្រួតពិនិត្យបញ្ជាក់អំពីអាយុពិតប្រាកដរបស់ពួកគេ។ ក៏ប៉ុន្តែនេះមិនមែនជាហេតុផលសមរម្យក្នុងការឃុំខ្លួនអនីតិជនខ្លួនបណ្ដោះអាសន្នឡើយ។ មូលហេតុជាក់លាក់ដែលនាំឲ្យមានការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន មានចំនួនតិចតួច ហើយសច្ចធារណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្នសម្រាប់អនីតិជនមានកម្រិតខ្ពស់ជាងករណីនីតិជន។ តុលាការត្រូវបំពេញការងារច្រើនជាងនេះដើម្បីធានាថាវិធីសាស្ត្រដទៃទៀតត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាប្រឈម ក្នុងការត្រួតពិនិត្យបញ្ជាក់អំពីអាយុពិតប្រាកដរបស់ជនជាប់ចោទជាអនីតិជន។

---

34. មាត្រា១៦៦នៃក្រមព្រហ្មទណ្ឌ ចែងអំពីលក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ៖ “អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន។” សូមអានផងដែរ មាត្រា៣៧(គ) នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ និង វិធាន ១៣.៤នៃវិធានអប្បបរមានៃរដ្ឋបាលយុត្តិធម៌សម្រាប់អនីតិជននៃអង្គការសហប្រជាជាតិ (វិធានប៉េកាំង) ដែលអនុម័តដោយសេចក្ដីសម្រេចមហាសន្និបាតលេខ ៤០/៣៣ចុះថ្ងៃទី២៩ខែវិច្ឆិកាឆ្នាំ១៩៨៥។

តួលេខ ១៩៖ អនីតិជន - ការឃុំខ្លួនបណ្ដោះអាសន្ន

| ២៣ (ក) តើមានការឃុំខ្លួនបណ្ដោះអាសន្នដែរឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្នន័យ | អំឡុងរបាយការណ៍ទី ១ | | អំឡុងរបាយការណ៍ទី ២ | | អំឡុងរបាយការណ៍ទី ៣ | | អំឡុងរបាយការណ៍ទី៤ | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| មាន | ១៧ | ៦៥ | ៨៤ | ៩៦ | ៤២ | ៨៧.៥ | ១៧ | ៧១ |
| គ្មាន | ៧ | ២៧ | ១ | ២ | ៥ | ១០.៥ | ៧ | ២៩ |
| មិនពាក់ព័ន្ធ | ០ | ០ | ០ | ០ | ០ | ០ | | |
| មិនដឹង | ២ | ៨ | ១ | ២ | ១ | ២ | | |

| ២៣ (ខ) ប្រសិនបើមានការឃុំខ្លួនបណ្ដោះអាសន្ន តើមានអ្វីបង្ហាញថា ជនជាប់ចោទមិនត្រូវបាន ដាក់ជាច់ដោយឡែកពីនីតិជនដែរ ឬទេ? | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ទិន្ន័យ | អំឡុងរបាយការណ៍ទី ១ | | អំឡុងរបាយការណ៍ទី២ | | អំឡុងរបាយការណ៍ទី ៣ | | អំឡុងរបាយការណ៍ទី ៤ | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| មាន | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| មិនមាន | ១៨ | ៦៩ | ៨៤ | ៩៦ | ៤៣ | ៩០ | ១៧ | ៧១ |
| មិនពាក់ព័ន្ធ | ៨ | ៣១ | ២ | ៤ | ៥ | ១០ | ៧ | ២៩ |

នៅក្នុងសវនាការពាក់ព័ន្ធនឹងអនីតិជនដែលបានសង្កេតចំនួន ៩២% មានការប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្ន។ នៅពេលដែលក្រឡេកមើលទៅលើអនីតិជនជាជនជាប់ចោទម្នាក់ៗ ឃើញមានអនីតិជនចំនួន ៥៣នាក់ ឬស្មើនឹង ៧៧% ត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន។ បើប្រៀបធៀបទិន្នន័យនេះ ជាមួយនឹងទិន្នន័យពាក់ព័ន្ធនឹងនីតិជនចំនួន ៦៤% អត្រានេះមានកម្រិតខ្ពស់ជាង។ បញ្ហានេះត្រូវបានបញ្ជាក់ពីមន្ត្រីដែលជាតំណាងមកពីតុលាការរាជធានីភ្នំពេញ នៅក្នុងកិច្ចជួបពិភាក្សាអំពីរបាយការណ៍ប្រចាំឆមាសទី២ ថាជាទូទៅអនីតិជនត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន នៅពេលដែលមន្ត្រីប៉ូលីស និងតុលាការកំពុងតែត្រួតពិនិត្យមើលអាយុរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ នេះមិនអាចត្រូវបានចាត់ទុកជាមូលហេតុឃុំខ្លួនអនីតិជនបណ្ដោះអាសន្នឡើយ។ មូលហេតុដែលអាចនាំឲ្យមានការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន មានចំនួនតិចតួចប៉ុណ្ណោះ ហើយសច្ចធារណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្នអនីតិជនស្ថិតនៅក្នុងកម្រិតមួយខ្ពស់ជាងនីតិជន។ តុលាការគួរតែខិតខំប្រឹងប្រែង ដើម្បីធានាថាមានការចាត់វិធានការណ៍ដោះស្រាយបញ្ហាដែលអាចកើតមានឡើង ក្នុងការត្រួតពិនិត្យអាយុរបស់ជនជាប់ចោទជាអនីតិជន។

## អនីតិជន និងការផ្តន្ទាទោស

| ប្រភពនៅក្នុងច្បាប់កម្ពុជា និង ច្បាប់អន្តរជាតិ៖ |
| --- |
| ➢ **មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ៖**"អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ"។ |
| ➢ **មាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ៖** វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និង វិធានការឧបត្ថម្ភ មានដូចតទៅ៖<br>១. ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។<br>២. ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។<br>៣. ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។<br>៤. ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។<br>៥. ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។ |

នៅពេលសម្រេចដាក់ទោសលើអនីតិជន ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ចៅក្រមត្រូវពិចារណាទៅលើផលប្រយោជន៍ល្អបំផុតរបស់កុមារជាអាទិភាព។[35] ការដាក់ទោសពន្ធនាគារលើអនីតិជនដែលត្រូវបានរកឃើញថាបានល្មើសច្បាប់ព្រហ្មទណ្ឌត្រូវតែជាវិធានការណ៍ចុងក្រោយបង្អស់ ហើយនឹងត្រូវបានប្រើតែនៅក្នុងករណីពិសេសប៉ុណ្ណោះ។[36]

### តួលេខ ២០៖ អនីតិជន - ការផ្តន្ទាទោស

| ២៥(ខ)តើមានអ្វីដែលបង្ហាញថាចៅក្រមធ្វើការពិចារណាទៅលើទោសមិនមែនពន្ធនាគារមុនទោសពន្ធនាគារ? | | | | | | | | |
| --- | --- | --- | --- | --- | --- | --- | --- | --- |
| ទិន្នន័យ | អំឡុងរបាយការណ៍ទី ១ | | អំឡុងរបាយការណ៍ទី ២ | | អំឡុងរបាយការណ៍ទី ៣ | | អំឡុងរបាយការណ៍ទី ៤ | |
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| មាន | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| មិនមាន | ២០ | ៧៧ | 46 | ១០០ | ៣២ | ៦៧ | ១៥ | ៦២ |
| មិនពាក់ព័ន្ធ | ៦ | ២៣ | ០ | ០ | ១៦ | ៣៣ | ៩ | ៣៨ |

មន្ត្រីសង្កេតការណ៍សវនាការសង្កេតឃើញថា គ្មានករណីណាមួយដែលបង្ហាញថាចៅក្រមពិចារណាទៅលើទោសមិនមែនពន្ធនាគារ មុននឹងឈានទៅរកការសម្រេចដាក់ទោសពន្ធនាគារឡើយ។ ការណ៍ដែលមន្ត្រីសង្កេតការណ៍សវនាការបន្តសង្កេតឃើញនិន្នាការឆ្ពោះទៅរកការអនុវត្តទោសពន្ធនាគារ

[35]មាត្រា ២(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ សូមមើលផងដែរគណៈកម្មាធិការសិទ្ធិកុមារ- កថាខណ្ឌទី ១០ និង ៧១ បទអត្ថាធិប្បាយទូទៅលេខ១០៖សិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន។

[36]មានត្រា ២៧ (ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

នាំឲ្យមានការព្រួយបារម្ភ ដោយសារតែមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ បានបង្កើតនូវសច្ចធារណ៍ប្រឆាំងការផ្តន្ទាទោស និងការដាក់ទោសពន្ធនាគារ លើអនីតិជន។ កិច្ចពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធ សបញ្ជាក់ឱ្យឃើញថាតុលាការនៅមានកង្វះខាតនូវយន្តការសម្រាប់អនុវត្តវិធានការណ៍ដទៃទៀតដែលចែងដោយច្បាប់។ ខណៈដែលអង្គការយូនីសេហ្វបានធ្វើការសហការជាមួយនឹងក្រសួងយុត្តិធម៌ក្នុងគោលបំណងលើកស្ទួយសិទ្ធិកុមារ តាមរយៈសិក្ខាសាលាតស៊ូមតិលើជម្រើសទណ្ឌកម្មផ្សេងៗនោះ ធនធានសម្រាប់ការអនុវត្តនេះនៅតែមានកម្រិតទាំងសម្រាប់រឿងក្តីអនីតិជននិងរឿងក្តីនីតិជន។[37]

ប្រទេសកម្ពុជាមានក្របខណ្ឌច្បាប់រឹងមាំ ដែលអនុញ្ញាតឱ្យមានជម្រើសសម្រាប់ចំណាត់ការលើករណីអនីតិជន។ ប៉ុន្តែទិន្នន័យដែលប្រមូលបានបង្ហាញថាមានកង្វះខាតធនធាន និងរចនាសម្ព័ន្ធផ្នែកយុត្តិធម៌ និងសង្គម ដើម្បីគាំទ្រតុលាការក្នុងការអនុវត្តន៍ច្បាប់នេះ។ វិធានការណ៍ផ្សេងៗដូចជា ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ និងបំពេញសេវាកម្មសហគមន៍ ទាមទារឲ្យមាននីតិវិធីត្រឹមត្រូវ និងធនធានគ្រប់គ្រាន់។ ការណ៍នេះទាមទារឲ្យមានយុទ្ធសាស្ត្រក្នុងកិច្ចសហការណ៍ជាមួយនឹងរដ្ឋាភិបាលក្នុងការធ្វើការជាមួយនឹងដៃគូម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នឯកជនដទៃទៀតដើម្បីធានាបាននូវការអភិវឌ្ឍវិស័យយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធិភាព ដែលផ្តោតសំខាន់ទៅលើការធានាថាយុវជនដែលល្មើសច្បាប់ ទទួលបាននូវការគាំពារគ្រប់គ្រាន់ដើម្បីក្លាយទៅជាសមាជិកមានប្រយោជន៍មួយនៅក្នុងសង្គមជាតិ។

---

[37]កិច្ចប្រជុំរវាងបុគ្គលិកគម្រោង និងអង្គការយូនីសេហ្វ នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១។

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ទិន្នន័យប្រមូលបានពីការសង្កេតសវនាការចំនួន ៣៩៨ នៅក្នុងអំឡុងរបាយការណ៍ទី ៤ បន្តបង្ហាញអំពីភាពប្រសើរឡើងនៅក្នុងការប្រកាន់ខ្ជាប់នូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលក្នុងនោះមានសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ។ នៅក្នុងសវនាការមួយចំនួនតូច ចៅក្រមបាននិយាយសំដីដែលបង្ហាញពីការយល់ដឹងមិនបានពេញលេញនូវគោលការណ៍សន្មតទុកជាមុនថាគ្មានទោស ហើយចំណាត់ការតុលាការទៅលើភស្តុតាង និងសាក្សី នៅតែជាចំណុចមួយដែលមានការវិវឌ្ឍន៍វិជ្ជមាន ដោយសារភាគីទាំងពីរទទួលបាននូវឱកាសស្មើគ្នាក្នុងការបង្ហាញ និងត្រួតពិនិត្យភស្តុតាង។ ប៉ុន្តែការព្រួយបារម្ភចម្បងនៅតែកើតមានឡើង ទាក់ទងទៅនឹងអត្រាខ្ពស់នៃការឃុំខ្លួនបណ្តោះអាសន្ន ទោះបីជាម.ស.ម.ក សង្កេតឃើញថា អត្រាមានការធ្លាក់ចុះបន្តិចបន្តួចក៏ដោយ។ ការព្រួយបារម្ភនៅតែកើតមានឡើង ពាក់ព័ន្ធនឹងអត្រាទាបនៃការទទួលបានជំនួយពីមេធាវី ដោយជនជាប់ចោទក្នុងបទមជ្ឈិម។ ម.ស.ម.ក បានសង្កេតឃើញថាអត្រានៃជនជាប់ចោទពីបទឧក្រិដ្ឋ ទទួលបានជំនួយពីមេធាវីមានការធ្លាក់ចុះ ការណ៍នេះនាំឲ្យមានការព្រួយបារម្ភ ព្រោះថាច្បាប់តម្រូវឲ្យមានមេធាវីជាដាច់ខាត។

ឆ្លងតាមការវិភាគទៅលើទិន្នន័យប្រមូលបាន ម.ស.ម.ក បានធ្វើការកត់សម្គាល់ទៅលើផ្នែកមួយចំនួនដែលមានការកែទម្រង់ប្រព័ន្ធតុលាការ និងមានការផ្លាស់ប្តូរក្នុងការអនុវត្តន៍ នឹងអាចរួមចំណែកឲ្យមានការកើនឡើងនូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

ម.ស.ម.ក បានផ្តល់អនុសាសន៍ទៅលើចំណុចខ្វះខាតទាំងឡាយដែលបានសង្កេតឃើញនៅក្នុងអំឡុងពេលរបាយការណ៍ទី ៤ ដូចខាងក្រោម៖

### អនុសាសន៍ចំពោះបញ្ហាពន្យារពេល និងការឃុំខ្លួនបណ្តោះអាសន្ន

- **រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ**គួរតែធានាថា អនាគតចៅក្រមទទួលបានការបណ្តុះបណ្តាលស្តីពីបទប្បញ្ញត្តិពាក់ព័ន្ធការឃុំខ្លួនបណ្តោះអាសន្ន ដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌអត្ថន័យនៃមូលហេតុទាំង ៦ ដែលអាចនាំឲ្យមានឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងការអនុវត្តជាក់ស្តែង៖ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬ ដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។
- **សភាស៊ើបសួរ ប្រធានសាលាឧទ្ធរណ៍**(សូមមើលមាត្រា២៨៣និង២៨៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ)និង**អធិការកិច្ចនៃក្រសួងយុត្តិធម៌**គួរតែត្រួតពិនិត្យចៅក្រមស៊ើបសួរ ប្រសិនបើមើលឃើញជាក់ស្តែងថាពួកគេមានចេតនា ឬធ្វេសប្រហែស មិនយកចិត្តទុកដាក់ចិរវេលាកំណត់នៃការឃុំខ្លួនបណ្តោះអាសន្ន។ គណៈកម្មាធិការវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែផ្អែកលើបញ្ហានេះ ដើម្បីជាមូលដ្ឋានក្នុងការស៊ើបសួរ និងដាក់ពិន័យ ចៅក្រមស៊ើបសួរទាំងនោះ។
- **ក្រសួងយុត្តិធម៌**គួរតែបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យថ្នាក់ជាតិ ដើម្បីត្រួតពិនិត្យការឃុំខ្លួនបណ្តោះអាសន្ន និងធានាថាមិនមានការឃុំខ្លួនបណ្តោះអាសន្នលើសចិរវេលាកំណត់ដោយច្បាប់។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យនេះគួរតែធានាថា កាលបរិច្ឆេទនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ជនជាប់ចោទម្នាក់ៗត្រូវបានកត់ត្រាទុក ហើយមានការផ្តល់ជាសញ្ញាប្រាប់នូវកាលបរិច្ឆេទចុងក្រោយនៃការឃុំខ្លួនបណ្តោះអាសន្ន និង

មានប្រព័ន្ធសម្រាប់ត្រួតពិនិត្យការឃុំខ្លួនទាំងអស់ ហើយនៅក្នុងករណីដែលមានការឃុំខ្លួនបណ្តោះអាសន្នលើសថិរវេលាកំណត់ដោយច្បាប់ មានការផ្តល់សញ្ញាឲ្យដឹងដោយស្វ័យប្រវត្តិ។ នៅពេលដែលថ្ងៃចុងក្រោយនៃការឃុំខ្លួនតាមច្បាប់មកដល់ ជនជាប់ចោទត្រូវតែបានដោះលែងដោយស្វ័យប្រវត្តិ ស្របតាមមាត្រា២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យការឃុំខ្លួននៅទូទាំងប្រទេសណាមួយក៏ដោយគួរតែមានប្រព័ន្ធផ្តល់ដំណឹងដល់អង្គការផ្តល់ជំនួយផ្នែកច្បាប់ និងជនជាប់ចោទដទៃទៀត ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ធ្វើរបៀបនេះជំនួយផ្នែកច្បាប់នឹងត្រូវបានផ្តល់ឲ្យដល់ជនជាប់ចោទ។

- នៅក្នុងករណីដែលជនជាប់ចោទកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ហើយថិរវេលាកំណត់ដោយច្បាប់ជិតឈានមកដល់នោះ ជនជាប់ចោទទាំងនោះគួរតែទទួលបានអាទិភាពក្នុងការជំនុំជម្រះ។
- កង្វះខាតមេធាវី អាចនឹងរួមចំណែកឲ្យមានការឃុំខ្លួនបណ្តោះអាសន្នលើសថិរវេលាកំណត់ ដោយសារបាត់ដានព័ត៌មានជនជាប់ចោទនៅក្នុងប្រព័ន្ធ។ ជំនួយផ្នែកហិរញ្ញវត្ថុដល់អង្គការជំនួយផ្នែកច្បាប់គួរតែត្រូវបានបង្កើនដើម្បីធានាថាជនទាំងឡាយណាដែលចង់បាន និងមានតម្រូវការអាចទទួលបានជំនួយពីមេធាវី។ **គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**(គណៈមេធាវី) ស្របជាមួយនឹងការទទួលខុសត្រូវដែលកំណត់ដោយច្បាប់ ក្នុងការផ្តល់នូវសេវាកម្មជំនួយផ្នែកច្បាប់ គួរតែសហការជាមួយមេធាវី និងក្រុមហ៊ុនមេធាវីឯកជនក្នុងការជម្រុញឲ្យមានការផ្តល់ជំនួយផ្នែកច្បាប់ដោយស្ម័គ្រចិត្ត ដើម្បីបំពេញកង្វះខាតជំនួយផ្នែកច្បាប់ដែលផ្តល់ដោយមេធាវី ជាពិសេសសម្រាប់ជនជាប់ចោទដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នលើសថិរវេលាកំណត់ដោយច្បាប់។

## អនុសាសន៍ចំពោះបញ្ហាផ្តល់ជំនួយផ្នែកច្បាប់

ម.ស.ម.ក ទទួលស្គាល់ថាបញ្ហាទាំងឡាយនៅក្នុងផ្នែកនេះអាចនឹងកើតឡើង ដោយសារភាពមានកម្រិតនៃធនធានជាជាងចំណេះដឹងឬសមត្ថភាព។ ទោះបីជាយ៉ាងនេះក៏ដោយដោយសារតែសារៈសំខាន់នៃសិទ្ធិនេះ ក្នុងការធានាឲ្យជនជាប់ចោទម្នាក់ទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ អនុសាសន៍ត្រូវបានផ្តល់ដូចខាងក្រោម៖

- មាត្រា១៤៥ ២៥៤ ៣០៤ ៣១៩ ៣៩១ និង៤២៨នៃក្រមនីតិវិធីព្រហ្មទណ្ឌគួរតែត្រូវបានធ្វើវិសោធនកម្មដើម្បីធានាថា ក្នុងករណីដែលមេធាវីអវត្តមាន ជនជាប់ចោទទាំងអស់មានឱកាសមើលផ្នែកដែលពាក់ព័ន្ធនឹងសំណុំរឿងរបស់ខ្លួន ដើម្បីជាជំនួយក្នុងការឆ្លើយតបនឹងការចោទប្រកាន់ប្រឆាំងនឹងខ្លួន និងរៀបចំការការពារក្តី។
- នៅរាល់គ្រប់ដំណាក់កាលនៃរឿងក្តីព្រហ្មទណ្ឌ អាជ្ញាធរមានសមត្ថកិច្ចដូចជាមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះគួរតែចាត់វិធានការណ៍ដើម្បីធានាថានៅក្នុងករណីដែលចាំបាច់សិទ្ធិជនជាប់ចោទទទួលបានជំនួយពីមេធាវីត្រូវបានគោរព និងសម្របសម្រួល រួមមាន៖
    - o ការរក្សាទុកបញ្ជីឈ្មោះមេធាវី នៅឯប៉ុស្តិ៍ប៉ូលីស ការិយាល័យព្រះរាជអាជ្ញា និងតុលាការ
    - o ប្រសិនបើមិនទាន់មាន បង្កើតកិច្ចសហការណ៍រវាងគណៈមេធាវី និងអង្គការផ្តល់ជំនួយផ្នែកច្បាប់ដើម្បីផ្តល់ជំនួយច្បាប់ដោយឥតគិតថ្លៃ ដល់ជនជាប់ចោទដែលគ្មានលទ្ធភាពខាងហិរញ្ញវត្ថុ។
- ចំពោះការយឺតយ៉ាវដែលតុលាការតែងតែជួបប្រទះ នៅក្នុងការស្នើសុំមេធាវី **ក្រសួងយុត្តិធម៌**គួរតែបំពេញការងារជាមួយតុលាការ ដើម្បីបង្កើតនូវគោលនយោបាយអនុវត្តចំពោះការដាក់ពាក្យស្នើសុំមេធាវី។ គោលនយោបាយនេះគួរតែធានាថាគណៈមេធាវី និងអង្គការជំនួយផ្នែកច្បាប់នានាទទួលបានដំណឹងឲ្យបានឆាប់រហ័សបំផុតតាមតែអាចធ្វើទៅបានអំពីតម្រូវការមេធាវី។

- **តុលាការ គណៈមេធាវី និងអង្គការជំនួយផ្នែកច្បាប់នានា** ត្រូវធ្វើការរួមគ្នាដើម្បីធានាថាជំនួយផ្នែកច្បាប់មានសម្រាប់ជនជាប់ចោទច្រើននាក់តាមដែលអាចធ្វើទៅបាន ជាមួយនឹងពេលវេលាដែលឆាប់រហ័ស។ **ក្រសួងយុត្តិធម៌**គួរតែចេញសេចក្តីណែនាំដែលចែងថា នៅក្នុងករណីដែលជំនួយពីមេធាវីត្រូវមានដាច់ខាត ដូចជាករណីបទល្មើសព្រហ្មទណ្ឌ ឬករណីពាក់ព័ន្ធនឹងអនីតិជនមេធាវីគួរតែត្រូវបានចាត់តាំងនៅដំណាក់កាលដំបូងនៃនីតិវិធីព្រហ្មទណ្ឌ ដើម្បីជៀសវាងការចាត់តាំងមេធាវីនៅនាទីចុងក្រោយនិងធានាបាននូវពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំការពារក្តី។
- **គណៈមេធាវី**គួរតែបង្កើតនូវបរិក្ខារសិក្សាដើម្បីជាជំនួយដល់សាធារណជនឲ្យមានការយល់ដឹងអំពីរបៀបទទួលបានជំនួយផ្នែកច្បាប់តាមរយៈមូលនិធិជំនួយផ្នែកច្បាប់របស់គណៈមេធាវី និងអង្គការជំនួយផ្នែកច្បាប់នានា។
- **រាជរដ្ឋាភិបាលកម្ពុជា**ត្រូវតែទទួលស្គាល់អំពីសារៈសំខាន់នៃជំនួយផ្នែកច្បាប់ក្នុងការធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។ រាជរដ្ឋាភិបាលគួរតែបង្កើតឲ្យមានគោលនយោបាយជាតិមួយស្តីពីជំនួយផ្នែកច្បាប់រួមទាំងយុទ្ធសាស្ត្រក្នុងការផ្តល់ថវិកាសម្រាប់ជំនួយផ្នែកច្បាប់ និងថវិកាសម្រាប់សវនកម្មប្រចាំឆ្នាំទៅលើថវិកាជំនួយផ្នែកច្បាប់របស់គណៈមេធាវី។
- **ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌**គួរតែសហការជាមួយភាគីផ្តល់ជំនួយផ្នែកច្បាប់ដែលពាក់ព័ន្ធ ដើម្បីអនុវត្តនូវអនុសាសន៍នៅក្នុងរបាយការណ៍របស់ខ្លួន ឆ្នាំ២០០៦*ជំនួយផ្នែកច្បាប់នៅកម្ពុជា៖ ការអនុវត្តន៍ការយល់ដឹង និងតម្រូវការ* រួមទាំងការបង្កើតនូវស្ថាប័នសម្របសម្រួលកណ្តាលមួយដើម្បីផ្តល់ថវិកានិងបង្កើតហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិមួយសម្រាប់ជំនួយផ្នែកច្បាប់។
- **ក្រសួងយុត្តិធម៌**គួរតែធ្វើការងារជាមួយនឹងម្ចាស់ជំនួយអន្តរជាតិ ដើម្បីអប់រំបណ្តុះបណ្តាលនិងបង្កើនការយល់ដឹងឲ្យបានល្អប្រសើរអំពីអត្ថន័យនិងផលប្រយោជន៍នៃជំនួយផ្នែកច្បាប់។ យុទ្ធនាការបង្កើនការយល់ដឹង គួរតែបង្កើតយុទ្ធសាស្ត្រមួយដែលអាចបញ្ជូនព័ត៌មានទៅដល់ថ្នាក់មូលដ្ឋានឧទាហរណ៍តាមរយៈការផ្តល់ការបណ្តុះបណ្តាលនិងព័ត៌មានទៅដល់ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរភូមិស្រុក។

## អនុសាសន៍ចំពោះការអនុវត្តគោលការណ៍សន្មតជាមុនថាគ្មានទោស

- **ក្រសួងមហាផ្ទៃ**គួរតែចេញសេចក្តីណែនាំអំពីមាត្រា៩(៥)(ច) នៃសេចក្តីប្រកាសលេខ ២១៧ ស្តីពីការគ្រប់គ្រងពន្ធនាគារ ដើម្បីឲ្យមានភាពច្បាស់លាស់ថាអ្នកជាប់ឃុំខ្លួនត្រូវតែបង្ហាញខ្លួននៅមុខតុលាការក្នុងសំលៀកបំពាក់ផ្ទាល់ខ្លួន និងការធានាថានៅក្នុង**មជ្ឈមណ្ឌលឃុំខ្លួន**ជនជាប់ឃុំដែលតម្រូវឲ្យបង្ហាញខ្លួននៅមុខតុលាការទទួលបានឱកាសស្លៀកសំលៀកបំពាក់ផ្ទាល់របស់ខ្លួន។ នៅមុនពេលបង្ហាញខ្លួននៅមុខតុលាការចុងចម្លើយទាំងអស់គួរតែទទួលបានសំលៀកបំពាក់ ដែលខ្លួនស្លៀកពាក់នៅពេលដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នឬប្រសិនបើសំលៀកបំពាក់នោះត្រូវបានបាត់បង់ ឬបោះបង់ចោលអ្នកជាប់ឃុំគួរតែទទួលបានឱកាសស្វែងរកសំលៀកបំពាក់ដែលផ្ញើមកឲ្យខ្លួនដោយក្រុមគ្រួសារឬមិត្តភ័ក្រ្ត។

## អនុសាសន៍ចំពោះការគោរពសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាព

- **ក្រសួងមហាផ្ទៃ** គួរតែបន្តផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ (រួមទាំងមន្ត្រីនគរបាលយុត្តិធម៌) និងមន្ត្រីពន្ធនាគារអំពីបច្ចេកទេសសួរចម្លើយដែលគ្មានការបង្ខិតបង្ខំនិងហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្មដែលឃោរឃៅអមនុស្សធម៌បន្ថោកបន្ទាបឬទណ្ឌកម្ម។

- **រាជរដ្ឋាភិបាលកម្ពុជា** គួរតែចាត់ការឲ្យរហ័សនូវការបង្កើតយន្តការបង្ការថ្នាក់ជាតិ ដើម្បីស៊ើបអង្កេតបណ្តឹងរួមទាំងអំណះអំណាងអំពីការធ្វើទារុណកម្មពីសំណាក់នគរបាលមន្ត្រីពន្ធនាគារ និងមន្ត្រីអនុវត្តច្បាប់ដទៃទៀត ដើម្បីសង្កេតមើលមធ្យោបាយក្នុងការឃុំខ្លួន និងផ្តល់ជាអនុសាសន៍ដល់រដ្ឋាភិបាល។

យន្តការបង្ការថ្នាក់ជាតិគួរតែត្រូវបង្កើតឡើងស្របតាមមាត្រា១៧ និង១៨នៃពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្មដែលទាមទារឲ្យស្ថាប័នឬយន្តការនេះឯករាជ្យពីរដ្ឋាភិបាល។

- **រាជរដ្ឋាភិបាលកម្ពុជានិងព្រះរាជអាជ្ញា** គួរតែធានាថាអំណះអំណាងអំពីការប្រព្រឹត្តមិនត្រឹមត្រូវត្រូវបានស៊ើបអង្កេតយ៉ាងរហ័សនិងដោយមិនលំអៀង។ ទង្វើនៃទារុណកម្មគួរតែនាំឲ្យមានការកាត់ទោស ជនដែលប្រព្រឹត្តទង្វើនោះ និងត្រូវបានព្យួរការងាររង់ចាំលទ្ធផលនៃការស៊ើបអង្កេត។

## អនុសាសន៍ចំពោះភាពឯករាជ្យ មិនលំអៀង និងវិជ្ជាជីវៈចៅក្រម

- **ក្រសួងយុត្តិធម៌** ឬក៏អាជ្ញាធរពាក់ព័ន្ធដទៃទៀត ដូចជាប្រធានតុលាការកំពូលគួរតែចេញសេចក្តីណែនាំជាលាយល័ក្ខអក្សរដល់ចៅក្រមជំនុំជម្រះ និងព្រះរាជអាជ្ញាដើម្បីរំឭកអំពីមាត្រា៣៣៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលហាមឃាត់ចៅក្រមជំនុំជម្រះមិនឲ្យនិយាយជាមួយបុគ្គលណាមួយនៅក្នុងអំឡុងពេលពិភាក្សាសម្រេចរួមបញ្ចូលទាំងក្រឡាបញ្ជីព្រះរាជអាជ្ញានិងមេធាវី។ ការបំពានលើសេចក្តីណែនាំគួរតែជាមូលដ្ឋានសម្រាប់រាយការណ៍អំពីចៅក្រម ឬព្រះរាជអាជ្ញាដែលប្រព្រឹត្តល្មើសដោយអធិការកិច្ចនៃក្រសួងយុត្តិធម៌ទៅកាន់គណៈកម្មការវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងដើម្បីចាត់វិធានការណ៍ដាក់ពិន័យ ។
- **ក្រសួងយុត្តិធម៌** គួរតែចេញសេចក្តីបង្គាប់ទៅកាន់ប្រធានតុលាការទាំងអស់ឲ្យធានាថា៖
  - វិធានផ្ទៃក្នុងនៃតុលាការនីមួយៗ ត្រូវតែមានបញ្ចូលការហាមប្រើប្រាស់ទូរស័ព្ទទាំងអស់នៅក្នុងបន្ទប់សវនាការ និងចំពោះបុគ្គលទាំងអស់។
  - ក្រឡាបញ្ជីត្រូវតែអានបទប្បញ្ញត្តិដែលពាក់ព័ន្ធនៃវិធានផ្ទៃក្នុងនៅមុនការចាប់ផ្តើមនៃសវនាការនីមួយៗ។
  - មន្ត្រីតុលាការរួមមានចៅក្រមព្រះរាជអាជ្ញា និងមេធាវីត្រូវតែធ្វើជាគំរូ។ប្រធានក្រុមប្រឹក្សាជំនុំជម្រះគួរតែពង្រឹងសណ្តាប់ធ្នាប់នៅក្នុងបន្ទប់សវនាការស្របតាមមាត្រា៣១៨នៃក្រមនីតិវិធីព្រហ្មទណ្ឌដោយបញ្ជារឲ្យចេញពីបន្ទប់សវនាការ នូវជនណាដែលត្រូវបានរកឃើញថាប្រើប្រាស់ទូរស័ព្ទក្នុងពេលសវនាការ។ ប្រហែលគ្នានេះដែរ ចៅក្រមនិងព្រះរាជអាជ្ញាមិនគួរទទួលឆ្លើយទូរស័ព្ទឡើយ។ ក្រឡាបញ្ជីគួរតែត្រូវបានណែនាំឲ្យទទួលសារជំនួសចៅក្រមដែលកំពុងជំនុំជម្រះនៅក្នុងសវនាការ។

## អនុសាសន៍ចំពោះសវនាការពាក់ព័ន្ធនឹងអនីតិជន

- **ក្រសួងយុត្តិធម៌** គួរតែធ្វើកិច្ចសហការជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការសាលាចៅក្រម និងព្រះរាជអាជ្ញាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការស្ថាប័នខាងក្រៅដើម្បីផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រម និងមេធាវីអំពីបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌដែលមានផលប៉ះពាល់លើអនីតិជនជាពិសេសសច្ចធារណ៍ប្រឆាំងនឹងការផ្តន្ទាទោសដាក់ពន្ធនាគារ នៅក្នុងមាត្រា៣៩ និងទោសមិនមែនពន្ធនាគារជំនួសការដាក់ទោសពន្ធនាគារ។
- **ក្រសួងយុត្តិធម៌និងក្រសួងអប់រំយុវជននិងកីឡា** គួរតែបង្កើតវិធីសាស្រ្តនិងកម្មវិធីទាំងឡាយដែលផ្តល់ជម្រើសសម្រាប់ការឆ្លើយតបទៅនឹងយុវជនដែលប្រព្រឹត្តល្មើសនិងអនុញ្ញាតឲ្យព្រះរាជអាជ្ញានិងចៅក្រមស៊ើបសួរបង្វែរជនល្មើលជាអនីតិជនចេញពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌផ្លូវការ។
- **រដ្ឋាភិបាលកម្ពុជានិងក្រសួងយុត្តិធម៌** គួរតែបង្កើនល្បឿននៃការអនុម័តច្បាប់យុត្តិធម៌អនីតិជនឲ្យបានឆាប់រហ័ស ដើម្បីផ្តល់ការបញ្ជាក់បំភ្លឺឲ្យកាន់តែប្រសើរឡើង អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃជនជាប់ចោទជាអនីតិជន។

- **ចៅក្រមស៊ើបសួរ** គួរតែធានាថាបទប្បញ្ញត្តិច្បាប់ជាតិនិងច្បាប់អន្តរជាតិដែលបង្កើតសច្ចធារណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនត្រូវបានគោរព។ ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនគួរតែត្រូវបានយកមកអនុវត្តតែនៅក្នុងករណីពិសេសប៉ុណ្ណោះហើយជាមធ្យោបាយចុងក្រោយបង្អស់ និងក្នុងរយៈពេលខ្លីសមស្របបំផុត។ ប្រព័ន្ធគ្រប់គ្រងទិន្ន័យដាច់ដោយឡែកសម្រាប់អនីតិជន ឬប្រព័ន្ធប្រើពណ៌កូដសម្រាប់ចងក្រងសំណុំរឿងដែលពាក់ព័ន្ធនឹងអនីតិជន គួរតែត្រូវបានបង្កើតឡើងដើម្បីជាការរំឭកដល់ចៅក្រមអំពីភាពខុសគ្នារវាងការប្រព្រឹត្តទៅលើនីតិជន និងអនីតិជន។
- យោងតាមច្បាប់ និងគោលការណ៍អន្តរជាតិស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលគួរតែធានាថាតុលាការប្រតិបត្តិតាមការអនុវត្តន៍ខាងក្រោមនៅពេលដែលនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជន៖
  - o ការជំនុំជម្រះជាអសាធារណៈ
  - o ការរៀបចំដោយឡែកសម្រាប់ការផ្តល់ភស្តុតាងដូចជារបាំង
  - o អនុញ្ញាតឲ្យមានសេចក្តីថ្លែងការណ៍តាមរយៈខ្សែអាត់វីដេអូ ពាក់ព័ន្ធនឹងភស្តុតាងរបស់កុមារ
- **ចៅក្រម** គួរតែធានាថាការដាក់ពន្ធនាគារអនីតិជន ជាមធ្យោបាយចុងក្រោយបង្អស់ និងប្រើជំនួសដោយបទប្បញ្ញត្តិផ្តន្ទាទោសថ្មីនៅក្នុងក្រមព្រហ្មទណ្ឌដោយដាក់ទោសមិនមែនពន្ធនាគារ ដែលមានដូចជាការបំពេញការងារសហគមន៍ នៅក្នុងពេលព្យួរទោសការដាក់ក្រោមវិធានការតាមដានអប់រំការពារ និងវិធានការឧបត្ថម្ភដែលមានចែងនៅក្នុងមាត្រា៣៩ និងមាត្រា៤០នៃក្រមព្រហ្មទណ្ឌ។
- **អង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នឯកជន** គួរតែស្វែងរកកិច្ចសហការជាមួយ**តុលាការក្រសួងយុត្តិធម៌**និង**ក្រសួងអប់រំយុវជននិងកីឡា**ដើម្បីផ្តល់ការគាំទ្រ និងស្តារនីតិសម្បទាយុវជនដែលបានប្រព្រឹត្តល្មើសច្បាប់ព្រហ្មទណ្ឌដោយផ្តល់មធ្យោបាយដែលអាចអនុវត្តបាន និងពិតប្រាកដ ផ្សេងពីការកាត់ទោសព្រហ្មទណ្ឌនិងដាក់ពន្ធនាគារ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

២០១២

រាជធានីភ្នំពេញ

# ៥.គន្ថនិទ្ទេស

## នីតិអន្តរជាតិ

### សន្ធិសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិ

ក្រុមប្រឹក្សាសហភាពអឺរ៉ុប៖*អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស*ចុះថ្ងៃទី០៤ខែវិច្ឆិកា១៩៥០។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ*អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តអំពើឃោរឃៅ អមនុស្សធម៌ឬបន្ថោកបន្ទាបឬទណ្ឌកម្ម* ចុះថ្ងៃទី១០ខែធ្នូ១៩៨៤។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ*អនុសញ្ញាស្តីពីសិទ្ធិកុមារ*ចុះថ្ងៃទី២០ខែវិច្ឆិកា១៩៨៩។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*ចុះថ្ងៃទី១៦ខែធ្នូ១៩៦៦។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ*ពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងនឹងទារុណកម្មអនុគណ:កម្មាធិការបង្ការទារុណកម្ម*នៅក្នុងខែកុម្ភ:២០០៧។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស*ចុះថ្ងៃទី១០ខែធ្នូ១៩៤៨។

### ឧបករណ៍ច្បាប់អន្តរជាតិដទៃទៀត

អង្គការសហប្រជាជាតិ*គោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ* អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ស្តីពីការបង្ការបទល្មើសនិងការប្រព្រឹត្តទៅលើជនល្មើសរៀបចំឡើងនៅទីក្រុងមីឡានពីថ្ងៃទី២៦ខែសីហាដល់ថ្ងៃទី០៦ខែកញ្ញាឆ្នាំ១៩៨៥គាំទ្រដោយសេចក្តីសម្រេចនៃអង្គមហាសន្និបាតលេខ៤០/៣២ចុះថ្ងៃទី២៩ខែវិច្ឆិកា១៩៨៥និងលេខ៤០/១៤៦ចុះថ្ងៃទី១៣ខែធ្នូ១៩៨៥។

អង្គការសហប្រជាជាតិ*គោលការណ៍មូលដ្ឋានស្តីពីតួនាទីមេធាវី* អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៨ស្តីពីការបង្ការបទល្មើសនិងការប្រព្រឹត្តទៅលើជនល្មើសរៀបចំឡើងនៅទីក្រុងហាវ៉ាណាប្រទេសគុយបានៅថ្ងៃទី០៧ខែកញ្ញាឆ្នាំ១៩៩០។

គោលការណ៍ដែលទាក់ទងនឹងលក្ខន្តិកៈនៃការបង្កើតស្ថាប័នជាតិ(គោលការណ៍ទីក្រុងប៉ារីស)ឆ្នាំ១៩៩៣។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិស្តីអំពី *វិធានបទដ្ឋានអប្បបរមាអនុវត្តចំពោះការប្រព្រឹត្តទៅលើទណ្ឌិត* ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៥៥។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ*សេចក្តីណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការបង្ការអនីតិជនប្រព្រឹត្តបទល្មើស (សេចក្តីណែនាំរីយ៉ាត)*អនុម័តដោយសេចក្តីសម្រេចនៃអង្គមហាសន្និបាតលេខ៤៥/១១២ចុះថ្ងៃទី១៤ខែធ្នូ១៩៩០។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ*វិធានអង្គការសហប្រជាជាតិស្តីពីការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព*ចុះថ្ងៃទី១៤ខែធ្នូ១៩៩០។

អង្គមហាសន្និបាតអង្គការសហប្រជាជាតិ *វិធានបទដ្ឋានអប្បរមានៃបទដ្ឋានអង្គការសហប្រជាជាតិសម្រាប់រដ្ឋបាលយុត្តិធម៌អនីតិជន* ចុះថ្ងៃទី២៩ខែវិច្ឆិកា១៩៨៥។

## នីតិជាតិ

### ច្បាប់

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៧)។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣ ដូចដែលបានធ្វើវិសោធនកម្ម)។

ច្បាប់ស្តីពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៥)។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (២០០៩)។

ប្រកាសលេខ២១៧ស្តីពីការគ្រប់គ្រងពន្ធនាគារ(ថ្ងៃទី៣១ខែមីនាឆ្នាំ១៩៩៨)។
បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល (១៩៩២)។

### គោលនយោបាយ

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ *យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី២០ខែមិថុនាឆ្នាំ២០០៣។

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ *ផែនការសកម្មភាពសម្រាប់ការអនុវត្តន៍យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌* ដែលត្រូវបានរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី២៩ខែមេសាឆ្នាំ២០០៥។

## ករណីសិក្សា

### *អន្តរជាតិ*

តុលាការសិទ្ធិមនុស្សអឺរ៉ុប *ហ្វចផ័រតទល់នឹងប្រទេសបារាំង* សេចក្តីសម្រេចលេខ២២២០៩/៩៣ECHR១៩៩៧-២ អាចរកបាននៅលើគេហទំព័រ៖http://cmiskp.echr.coe.int/tkp197/view.asp?item=1&portal=hbkm&action=html&highlight=%0922209/93&sessionid=72026732&skin=hudoc-en

គណៈកម្មាធិការសិទ្ធិមនុស្ស *សេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្សស្ថិតនៅក្រោមពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយសម័យប្រជុំលើកទី៣៩ សេចក្តីជូនដំណឹងលេខ២១៥/១៩៨៦ ជី.អា. វ៉ាន់មើសតទល់នឹងប្រទេសហូឡង់ សេចក្តីសម្រេចចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩០*(CCPR/C/39/D/215/1986)អាចរកបាននៅលើគេហទំព័រ៖

http://www.unhchr.ch/tbs/doc.nsf/%28Symbol%29/9e281a27532d5fe5c1256ab2004838b1?Opendocument

គណៈកម្មាធិការសិទ្ធិមនុស្ស *ទស្សនៈនៃគណៈកម្មាធិការសិទ្ធិមនុស្សលើមាត្រា៥កថាខណ្ឌទី៤នៃពិធីសារបន្ថែមលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សេចក្តីជូនដំណឹងលេខ២៦៣/១៩៨៧៖ លោកហ្គន់ហ្សាឡេសដេលរីយ៉ូតទល់នឹងលោកប៉េរូ*។សេចក្តីសម្រេចចុះថ្ងៃទី២៨ខែតុលាឆ្នាំ១៩៩២( CCPR/C/46/D/263/1987) អាចរកបាននៅលើគេហទំព័រ៖

http://www.unhchr.ch/tbs/doc.nsf/0/3977b6d1e738710c80256730004f6aaf?Opendocument

គណៈកម្មាធិការសិទ្ធិមនុស្ស *ការទទួលយក៖សេចក្តីជូនដំណឹងលេខ៥៩៤/១៩៩២៖ហ្វីលីពតទល់នឹងទ្រីនីដាតនិងតូបាហ្គោ*។សេចក្តីសម្រេចចុះថ្ងៃទី១៥ខែមីនាឆ្នាំ១៩៩៦(CCPR/C/56/D/594/1992) អាចរកបាននៅលើគេហទំព័រ៖http://www.bayefsky.com/pdf/124_trinidad594.pdf

គណៈកម្មាធិការសិទ្ធិមនុស្ស *បទអត្ថាធិប្បាយទូទៅលេខ៣២មាត្រា១៤៖សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការនិងសាលាជម្រះក្តីនិងការជំនុំជម្រះដោយយុត្តិធម៌*ចុះថ្ងៃទី២៣ខែសីហាឆ្នាំ ២០០៧(CCPR/C/GC/32) អាចរកបាននៅលើគេហទំព័រ៖

http://www.unhcr.org/refworld/type,GENERAL,,,478b2b2f2,0.html

គណៈកម្មាធិការសិទ្ធិមនុស្ស *ទស្សនៈនៃគណៈកម្មាធិការសិទ្ធិមនុស្សលើមាត្រា៥កថាខណ្ឌទី៤នៃពិធីសារបន្ថែមលើកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សេចក្តីជូនដំណឹងលេខ៩១៣/២០០០៖ ចាន់តទល់នឹងហ្គូយ៉ាណាសេចក្តីសម្រេចចុះថ្ងៃទី២៣ខែមករាឆ្នាំ២០០៦* (CCPR/C/85/D/913/2000)អាចរកបាននៅលើគេហទំព័រ៖

http://www.unhchr.ch/tbs/doc.nsf/0/b69fa1d51ad367c6c12571060050284e?Opendocument

### *ជាតិ*

ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ចុះថ្ងៃទី ១០ខែកក្កដាឆ្នាំ២០០៧។

### របាយការណ៍

ប្លូរីឆាតនិងរ៉ូប៊េតអានជីរូត *ការវាយតម្លៃទៅលើកម្មវិធីសិទ្ធិនិងយុត្តិធម៌ (ប្រាជ្ញ)៖របាយការណ៍ចុងក្រោយ*ក្រុងវ៉ាស៊ីនតោន៖ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក (UIAID) ខែមករាឆ្នាំ២០០៨អាចរកបាននៅលើគេហទំព័រ៖

http://www.usaid.gov/kh/democracy_and_governance/documents/Cambodia_HR-ROL_Evaluation_Final_Report.pdf

អង្គការអាដហុការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ អង្គការចិត្តសង្គមអន្តរវប្បធម៌ គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា របាយការណ៍រួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាស្តីពីទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដាក់ជូនគណៈកម្មាធិការប្រឆាំងទារុណកម្ម នៅមុនពេលរបាយការណ៍អំឡុងពេល

ទី២ របស់កម្ពុជា នៅក្នុងអង្គប្រជុំលើកទី៤៥ របស់គណៈកម្មាធិការប្រឆាំងទារុណកម្មដែលធ្វើឡើងនៅហ្សឺណែវ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ - ខែតុលា ឆ្នាំ២០១០។

គណៈកម្មាធិការប្រឆាំងទារុណកម្ម*ការពិចារណាទៅលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគីស្ដីពីមាត្រា១៩នៃអនុសញ្ញា៖ប្រទេសកម្ពុជា*ចុះថ្ងៃទី២៩ខែតុលាឆ្នាំ២០០៩(CAT/C/KHM/2)អាចរកបាននៅលើគេហទំព័រ៖http://www2.ohchr.org/english/bodies/cat/docs/AdvanceVersions/CAT-C-KHM-2.pdf

គណៈកម្មាធិការប្រឆាំងទារុណកម្ម*ការពិចារណាទៅលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគីស្ដីពីមាត្រា១៩នៃអនុសញ្ញា៖ប្រទេសកម្ពុជា*ចុះថ្ងៃទី០២ខែកុម្ភៈឆ្នាំ២០១០(CAT/C/KHM/Q/2) អាចរកបាននៅលើគេហទំព័រ៖
http://www2.ohchr.org/english/bodies/cat/docs/AdvanceVersions/CAT-C-KHM- 2.pdf

គណៈកម្មាធិការសិទ្ធិកុមារ*បទអត្ថាធិប្បាយទូទៅលេខ១០(២០០៧)៖សិទ្ធិកុមារនៅក្នុងវិស័យយុត្តិធម៌អនីតិជន*ចុះថ្ងៃទី២៥ខែមេសាឆ្នាំ២០០៧(CRC/C/GC/10)អាចរកបាននៅលើគេហទំព័រ៖

http://www.unhchr.ch/tbs/doc.nsf/0/b0ebdbcd1e49d11dc1257306004f1864?Opendocument

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌*ជំនួយផ្នែកច្បាប់នៅកម្ពុជា៖ការអនុវត្តន៍ចំណេះដឹងនិងតម្រូវការ*ភ្នំពេញ៖ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ខែធ្នូឆ្នាំ២០០៦អាចរកបាននៅលើគេហទំព័រ៖http://www.ewmi-praj.org/download/legalaid/Legal%20Aid%20in%20Cambodia%20study%20report.pdf

គណៈកម្មការអ្នកច្បាប់អន្តរជាតិ*បទអត្ថាធិប្បាយរបស់គណៈកម្មការអ្នកច្បាប់អន្តរជាតិលើរបាយការណ៍បឋមរបស់ប្រទេសកម្ពុជាស្ដីពីការអនុវត្តន៍កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ចសង្គមនិងវប្បធម៌*ក្រុងហ្សឺណែវ៖គណៈកម្មការអ្នកច្បាប់អន្តរជាតិខែមេសាឆ្នាំ២០០៩អាចរកបាននៅលើគេហទំព័រ៖http://www.icj.org/IMG/Cambodia_CESCR_Oral_SubmissionFINAL-30-04-09.pdf

ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល*របាយការណ៍ដូចគ្នាស្ដីពីប្រទេសកម្ពុជាឆ្នាំ២០០៩* រាជធានីភ្នំពេញ៖ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាលខែមេសាឆ្នាំ២០០៩អាចរកបាននៅលើគេហទំព័រ៖

http://www2.ohchr.org/english/bodies/cescr/docs/ngos/NGO_WG_Cambodia_CESCR42.pdf

តំណាងពិសេសសិទ្ធិមនុស្សប្រចាំនៅកម្ពុជា*របាយការណ៍ស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាលោកសាស្ត្រាចារ្យស៊ូរីយ៉ាស៊ូបេឌី*នៅថ្ងៃទី១៦ខែកញ្ញាឆ្នាំ២០១០(A/HRC/15/26)អាចរកបាននៅលើគេហទំព័រ៖http://cambodia.ohchr.org/WebDOCs/DocReports/3-SG-RA-Reports/A_HRC_CMB16092010E.pdf

រដ្ឋាភិបាលសហរដ្ឋអាមេរិក ការិយាល័យប្រជាធិបតេយ្យសិទ្ធិមនុស្សនិងការងារឆ្នាំ២០០៩*របាយការណ៍សិទ្ធិមនុស្ស*៖ប្រទេសកម្ពុជាខែមីនាឆ្នាំ២០១០អាចរកបាននៅលើគេហទំព័រ៖http://www.state.gov/g/drl/rls/hrrpt/2009/eap/135988.htm

## *អត្ថបទសារព័ត៌មាន*

ផនបូផា៖*មានការលើកឡើងជាផ្លូវការថា ការខ្វះខាតមេធាវីនាំឲ្យការឃុំខ្លួនបណ្ដោះអាសន្នមានរយៈពេលវែង*ដកស្រង់ចេញពីសារព័ត៌មានឌឺខែមបូឌា ដេលីចុះថ្ងៃទី២៣ខែមីនាឆ្នាំ២០១០។

## សៀវភៅស្ដីពីការជំនុំជម្រះដោយយុត្តិធម៌

អង្គការលើកលែងទោសអន្តរជាតិ *សៀវភៅស្ដីពីការជំនុំជម្រះដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ*ទីក្រុងឡុងដ៍៖ការបោះពុម្ពផ្សាយរបស់អង្គការលើកលែងទោសអន្តរជាតិឆ្នាំ១៩៩៨ AI Index POL 30/02/98 អាចរកបាននៅលើគេហទំព័រ៖

http://www.amnesty.org/en/library/asset/POL30/002/1998/en/81bf7626-d9b1-11dd-af2b-b1f6023af0c5/pol300021998en.pdf

អូលីវីរ៉ាបាបាវ៉ានិងលីនដាបេសារ៉ាទីម៉ូរ៉ាអែដ *សៀវភៅស្ដីពីការសង្កេតការណ៍សវនាការរបស់គណៈកម្មការអ្នកច្បាប់អន្តរជាតិ*ឆ្នាំ២០០២អាចរកបាននៅលើគេហទំព័រ៖

http://www.jsmp.minihub.org/Reports/otherresources/Trial_Observation_Manual.pdf

អង្គការសន្តិសុខនិងសហប្រតិបត្តិការអឺរ៉ុប/ ការិយាល័យវិទ្យាស្ថានប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស *ការសង្កេតការណ៍សវនាការ៖សៀវភៅយោងសម្រាប់អ្នកអនុវត្តប្រទេសប៉ូឡូញ៖* OSCE/ODIHR ឆ្នាំ២០០៨អាចរកបាននៅលើគេហទំព័រ៖

http://www.osce.org/publications/odihr/2008/04/30849_1119_en.pdf

ភីជីកជេលេណានិងវ៉ាណេសាលេសនី *អ្វីទៅជាការជំនុំជម្រះដោយយុត្តិធម៌? សេចក្ដីណែនាំជាមូលដ្ឋានស្ដីពីបទដ្ឋានច្បាប់និងការអនុវត្តន៍*ទីក្រុងញូវយ៉ក៖គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្សឆ្នាំ២០០០អាចរកបាននៅលើគេហទំព័រ៖

http://www.humanrightsfirst.org/pubs/descriptions/fair_trial.pdf

## សុន្ទរកថា

សុន្ទរកថាសម្ដេចហ៊ុនសែន *ស្ដីពីយុទ្ធសាស្ត្រចតុកោណសម្រាប់ការរីកលូតលាស់ការងារសមភាពនិងប្រសិទ្ធិភាពដំណាក់កាលទី២*ក្នុងកិច្ចប្រជុំលើកទី១នីតិកាលទី៤នៃរដ្ឋសភាជាតិនៅទីស្ដីការគណៈរដ្ឋមន្ត្រីរាជធានីភ្នំពេញនៅថ្ងៃទី២៦ខែកញ្ញាឆ្នាំ២០០៨។

## ផ្សេងៗ

អែដល័ដានីញ៉ែល "ការទទួលបានព័ត៌មានផ្នែកច្បាប់នៅកម្ពុជា៖ ជំហានដំបូងលទ្ធភាពនាពេលអនាគត"២០០៥ (២-៣) *ទនានុប្បវត្តិស្ដីពីព័ត៌មានច្បាប់និងព័ត៌មានវិទ្យា (JILT)*អាចរកបាននៅលើគេហទំព័រ៖http://www2.warwick.ac.uk/fac/soc/law/elj/jilt/2005_2-3/adler/#P86_17813

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា *បទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា*អាចរកបាននៅលើគេហទំព័រ៖http://www.bigpond.com.kh/Council_of_Jurists/Judicial/jud008g.htm

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា *សវនាការឌុច៖ឧទាហរណ៍ដ៏ល្អមួយសម្រាប់តុលាការកម្ពុជា*ចេញផ្សាយនៅថ្ងៃទី២៦ ខែកក្កដាឆ្នាំ២០១០អាចរកបាននៅលើគេហទំព័រ៖www.cchrcambodia.org

តុលាការព្រហ្មទណ្ឌអន្តរជាតិ *វិធាននៃភស្តុតាង និងនីតិវិធី* ដែលរៀបចំឡើងដោយសភានៃរដ្ឋភាគីនៅក្នុងសម័យប្រជុំលើកទី១ទីក្រុងញូយ៉កនៅថ្ងៃទី០៣ ដល់ថ្ងៃទី១០ ខែកក្កដាឆ្នាំ២០០២។កំណត់ត្រាជាផ្លូវការ ICC-ASP/1/3 អាចរកបាននៅលើគេហទំព័រ៖

http://www.icc-cpi.int/NR/rdonlyres/F1E0AC1C-A3F3-4A3C-B9A7-B3E8B115E886/140164/Rules_of_procedure_and_Evidence_English.pdf

**ប្រព័ន្ធគ្រប់គ្រងទិន្នន័យ**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាអាចរកបាននៅលើគេហទំព័រៈwww.cchrcambodia.org.

# ៦. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ តារាងសង្កេតការណ៍សវនាការ

### ព័ត៌មានទូទៅអំពីសវនាការ

| ១.ពត៌មានទូទៅ | | | | |
|---|---|---|---|---|
| ១(ក)កាលបរិច្ឆេទសវនាការ | ម៉ោងចាប់ផ្តើម | | | |
| ១(ខ) មន្រ្តីសង្កេតការណ៍សវនាការ | | | | |
| ១(គ) តុលាការ | ☐ ភ្នំពេញ ☐ កណ្តាល ☐ បន្ទាយមានជ័យ ☐ រនគិរី ☐ ផ្សេងៗ សូមបញ្ជាក់៖ ____________ | | | |
| ១(ឃ) ចៅក្រម | ទី១<br>ទី២<br>ទី៣<br>☐ ផ្សេងៗ សូមបញ្ជាក់៖ | | | |
